# ដៃគូដំណោះស្រាយ
# ហិរញ្ញវត្ថុផ្នែក
# លំនៅឋាន

របាយការណ៍ប្រចាំឆ្នាំ ២០២៥



# ពីចក្ខុវិស័យទៅជាតម្លៃពិត៖ របៀបដែល ហ្វីស ហ្វាយនែន ពង្រីកផលប័ត្រឥណទានដល់ ១០០ លានដុល្លារ ព្រមជាមួយការជំរុញផលប៉ះពាល់វិជ្ជមានដល់សង្គម

នៅក្នុងវិស័យហិរញ្ញវត្ថុ ការដែលសម្រេចបាននូវផលប័ត្រឥណទានចំនួន ១០០ លានដុល្លារ ជាញឹកញាប់ត្រូវបានគេមើលឃើញត្រឹមតែជាតារាងតុល្យការ និងប្រាក់ចំណេញប៉ុណ្ណោះ។ ប៉ុន្តែនៅ ហ្វីស ហ្វាយនែន សមិទ្ធផលដ៏សំខាន់នេះសម្រេចបានក្នុងរយៈពេលមិនដល់ ៣ ឆ្នាំផង ក្រោមការដឹកនាំរបស់គណៈគ្រប់គ្រងថ្មី វាបានបរិយាយនូវសាច់រឿងដ៏ស៊ីជម្រៅអំពីឥទ្ធិពលនៃការផ្តល់លទ្ធភាពទទួលបានកម្មសិទ្ធិផ្ទះសម្បែង និងភាពធន់នៃស្មារតីរបស់ប្រជាជនកម្ពុជា។

ក្នុងនាមជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុឯកទេសផ្តល់ហិរញ្ញប្បទានលំនៅឋានតម្លៃសមរម្យ ដែលមានអាជ្ញាប័ណ្ណតែមួយគត់នៅកម្ពុជា ហ្វីស ហ្វាយនែន បានបង្ហាញឱ្យឃើញថាប្រសិទ្ធភាពហិរញ្ញវត្ថុដែលមានកំណើនខ្ពស់ និងផលប៉ះពាល់សង្គមដ៏ស៊ីជម្រៅ មិនត្រឹមតែអាចដើរទន្ទឹមគ្នាបានប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជួយជំរុញគ្នាទៅវិញទៅមកយ៉ាងខ្លាំងក្លាទៀតផង។

## ការពង្រីកវិសាលភាពសម្រាប់អ្នកដែលមិនទាន់ទទួលបានសេវាគ្រប់គ្រាន់

ដំណើរឆ្ពោះទៅកាន់តួលេខ ១០០ លានដុល្លារ ត្រូវបានសម្រេចឡើងជាមួយនឹងគោលបំណងច្បាស់លាស់មួយ គឺការឈោងចាប់យកអ្នកដែលជារឿយៗ ត្រូវបានវិស័យធនាគារទូទៅ មើលរំលង។ សព្វថ្ងៃនេះ ផលប័ត្រឥណទានរបស់យើងខ្ញុំកំពុងគាំទ្រដល់គ្រួសារប្រមាណ ១២,០០០ គ្រួសារ ដែលភាគច្រើនក្នុងចំណោមពួកគេ កំពុងសម្រេចបាននូវក្តីស្រមៃក្នុងការមានផ្ទះជាកម្មសិទ្ធិផ្ទាល់ខ្លួនជាលើកដំបូង។

អ្វីដែលធ្វើឱ្យសមិទ្ធផលនេះគួរឱ្យកត់សម្គាល់បំផុតនោះគឺ "តួអង្គអ្នកទទួលផល" និង "ទីកន្លែង"៖

- **សេដ្ឋកិច្ចក្រៅប្រព័ន្ធ៖** ប្រមាណ ៨១% នៃអតិថិជនគឺជាអ្នកប្រកបរបរផ្ទាល់ខ្លួន កម្មករ ឬ អ្នកដែលមានប្រាក់ចំណូលមិនមានឯកសារបញ្ជាក់ច្បាស់លាស់ ដែលពួកគាត់គឺជាឆ្អឹងខ្នងនៃសេដ្ឋកិច្ចកម្ពុជា ប៉ុន្តែជាទូទៅខ្វះឯកសារហិរញ្ញវត្ថុផ្លូវការ។
- **ឫសគល់នៅជនបទ៖** ក្នុងគោលបំណងដើម្បីផ្សារភ្ជាប់គម្លាតរវាងទីក្រុង និងជនបទ ៩១% នៃអតិថិជនរបស់ស្ថាប័នរស់នៅតាមតំបន់ជនបទ ក្រោមការគាំទ្រដោយយុទ្ធសាស្ត្រពង្រីកសាខាទៅកាន់ខេត្តថ្មីចំនួន ៦ រួមមានខេត្តតាកែវ កំពង់ឆ្នាំង ពោធិសាត់ កំពង់ធំ ព្រៃវែង និងស្វាយរៀង។

## ការដឹកនាំដែលកំណត់ដោយសុចរិតភាព

ក្រោមអាណត្តិរបស់គណៈគ្រប់គ្រងថ្មី កំណើនមិនដែលត្រូវបានដោះដូរដោយការលះបង់នូវក្រមសីលធម៌ឡើយ។ នៅក្នុងឆ្នាំ ២០២៥ ហ្វីស ហ្វាយនែន ទទួលបានវិញ្ញាបនបត្រការពារអតិថិជនកម្រិតមាសជាលើកទីពីរជាប់ៗគ្នា ជាមួយនឹងពិន្ទុស្ទើរតែឥតខ្ចោះគឺ ៩៩,១%។ ការទទួលស្គាល់ជាលក្ខណៈអន្តរជាតិពីសំណាក់ស្ថាប័ន M-CRIL នេះ គឺជាការសន្យាចំពោះភាគទុនិកថា រាល់គ្រប់ប្រាក់ដុល្លារដែលបានកើន គឺមានឫសគល់ចេញពីការកំណត់តម្លៃដោយយុត្តិធម៌ ឯកជនភាពទិន្នន័យ និងការការពារការជំពាក់បំណុលលើសលប់។

"ការរក្សាបាននូវវិញ្ញាបនបត្រនេះ គឺជាការសន្យាចំពោះគ្រួសារទាំង ១១,៨៤៧ ដែលយើងបម្រើ" នេះជាការលើកឡើងរបស់ប្រធាននាយកប្រតិបត្តិ នៅក្នុងសារឆ្នាំ ២០២៥។ ការប្តេជ្ញាចិត្តក្នុង "ការធ្វើអ្វីដែលត្រឹមត្រូវ" នេះត្រូវបានបង្ហាញឱ្យឃើញកាន់តែច្បាស់តាមរយៈអត្រារក្សាអតិថិជនរហូតដល់ ៩៨% និងពិន្ទុសុច្ឆន្ទៈអតិថិជន (NPS) ដែលបានកើនឡើងដល់ ៦៨,៦%។

## ការប្រកាន់ខ្ជាប់នូវបេសកកម្ម៖ លើសពីឥណទានលំនៅឋាន

សម្រាប់គណៈគ្រប់គ្រងថ្មី ភាពជោគជ័យត្រូវបានវាស់វែងដោយគុណភាពជីវិតនៅក្នុងផ្ទះ មិនមែនត្រឹមតែទិន្នន័យកម្ចីនៅក្នុងបញ្ជីគណនេយ្យនោះទេ។

- **សុខភាព និងអាកាសធាតុ៖** អតិថិជនប្រហែល ៥១% បានប្រើប្រាស់កម្ចីដើម្បីកែលម្អប្រព័ន្ធទឹកស្អាត អនាម័យ និងបង្គន់ (WASH) ដែលជួយលើកកម្ពស់សុខភាពគ្រួសារ និងភាពធន់នឹងអាកាសធាតុនៅក្នុងសហគមន៍ដោយផ្ទាល់។
- **បណ្ដាញសុវត្ថិភាពក្នុងគ្រាមានអាសន្ន៖** ក្នុងអំឡុងពេលដែលមានភាពតានតឹងនៅព្រំដែន និងសម្ពាធថ្លៃចំណាយរស់នៅកន្លងមក ថ្នាក់គ្រប់គ្រងបានបង្ហាញពីស្មារតីទទួលខុសត្រូវសង្គម តាមរយៈការលើកលែងការប្រាក់ និងកម្រៃសេវាចំនួន ១១៨,០០០ ដុល្លារ និងផ្តល់ជំនួយដល់មនុស្សជាង ៥,៤០០ នាក់ រួមទាំងគ្រួសារកងទ័ពដែលបានពលីជីវិតផងដែរ។





## 2006 – 2009



### មូលដ្ឋានគ្រឹះ និងអាជ្ញាបណ្ណ

- ហ្វឺស ហូម ត្រូវបានបង្កើតឡើង ដែលមានម្ចាស់ភាគហ៊ុន First Home, Insitor Fund, និង Phillip Capital
- មានតម្រូវការលើផលិតផលកម្ចីទិញផ្ទះ
- ទទួលបានអាជ្ញាបណ្ណគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុក្នុងឆ្នាំ ២០០៩

## 2010 – 2013



### ចាប់ផ្តើមដំណើរការ និងរីកធំធាត់

- ទទួលបានភាគទុនពី CLDF, Norfund
- ទទួលបានហិរញ្ញប្បទានពី Oikocredit, Finnfund, Norfund និងធនាគារក្នុងស្រុក
- ពង្រីកប្រតិបត្តិការ ដោយបើកសាខាថ្មី រួមជាមួយអភិបាលកិច្ចសាជីវកម្ម និងគ្រប់គ្រងហានិភ័យ
- ទទួលបានពានរង្វាន់អាជីវកម្មឆ្នើមប្រចាំអាស៊ីក្នុងឆ្នាំ ២០១២

## 2014 – 2015



### ការកែប្រែលើហានិភ័យ

- ប្រឈមមុខការកើនឡើងកម្ចីមិនដំណើរការខ្ពស់ ដោយផ្តោតលើការដោះស្រាយ
- កែប្រែគោលនយោបាយឥណទាន
- បណ្តុះបណ្តាលលើការវាយតម្លៃឥណទាន និងកំហិតតឹងរ៉ឹងលើដំណើរការសិក្សាកម្ចី

## 2016 – 2019



### ការរីកធំធាត់ ប្រកបដោយការគ្រប់គ្រងត្រឹមត្រូវ

- ទទួលបានហិរញ្ញប្បទានពី Phillip, Norfund, Symbiotics, Triple Jump, Water Equity.
- ដាក់ឱ្យប្រើប្រាស់ប្រព័ន្ធព័ត៌មាន និងធនាគារស្នូលថ្មី
- ធ្វើឱ្យប្រសើរឡើងលើការត្រួតពិនិត្យហិរញ្ញវត្ថុ

## 2020 – 2021



### វិបត្តិកូវីដ និងការកើនឡើងកម្ចីមិនល្អ

- អនុគ្រោះកម្ចីដែលប៉ះពាល់ដោយកូវីដ រៀបចំកម្ចីឡើងវិញ រឹតបន្តឹងការត្រួតពិនិត្យហានិភ័យ
- ទាក់ទាញប្រភពហិរញ្ញប្បទានថ្មីៗ
- ពង្រីកកិច្ចសហការជាដៃគូជាមួយ អ្នកអភិវឌ្ឍន៍អចលនទ្រព្យ

## 2022 – 2024



### ភាគទុនិកថ្មី និងសន្ទុះនៃការរីកចម្រើន

- ផ្លាស់ប្តូរភាគទុនិកថ្មី (គ្រប់គ្រងដោយគណៈគ្រប់គ្រងថ្មី) ។ ចុះបញ្ជីបង្កើនដើមទុនបន្ថែម
- ធ្វើឱ្យប្រសើរឡើង ទៅលើប្រសិទ្ធភាព ផលិតភាព និងប្រាក់ចំណេញ ដោយបង្កើតសាខាថ្មី ត្រួតពិនិត្យគុណភាព និងបង្កើនផលបត្រឥណទាន
- ទទួលបានវិញ្ញាបនបត្រកម្រិតមាស សម្រាប់ការអនុវត្តលើកិច្ចការពារអតិថិជន
- ទទួលបានត្រាទឹកក្រូចពីដៃគូ (Stakeholder-Verified Orange Seal) សម្រាប់ការប្តេជ្ញាចិត្តក្នុងការលើកស្ទួយសមភាពយេនឌ័រ និងចីរភាពបរិស្ថាន ។

## 2025

100

### ការពង្រីកតំបន់ប្រតិបត្តិការ និងសន្ទុះនៃការរីកចម្រើន

- ពង្រីកតំបន់ប្រតិបត្តិការ ពង្រឹងគុណភាពកម្ចី និងកំណើនផលបត្រឥណទានរហូតដល់ ១០០លានដុល្លារ
- ទទួលបានវិញ្ញាបនបត្រលើកិច្ចការពារអតិថិជនកម្រិតមាសជាលើកទី ២ និងការវាយតម្លៃខ្ពស់លើការអនុវត្តប្រកបដោយក្រមសីលធម៌ខ្ពស់
- ទទួលបានត្រាទឹកក្រូចពីដៃគូ (Stakeholder-Verified Orange Seal) សម្រាប់ការប្តេជ្ញាចិត្តក្នុងការលើកស្ទួយសមភាពយេនឌ័រ និងចីរភាពបរិស្ថាន ។



ពួកគាត់បានផ្តល់តម្លៃដល់ពួកយើងខ្ញុំ និងមិនមានការរើសអើងចំពោះពួកយើងដែលជាស្ត្រីមានចំណូលទាបនោះឡើយ។ តាមរយៈកម្ចីលំនៅឋានដែលមានតម្លៃសមរម្យពី ហ្វីស ហ្វាយនែន យើងអាចសាងសង់ផ្ទះក្នុងក្តីស្រមៃសម្រាប់មនុស្សជាទីស្រឡាញ់របស់យើងបាន។

**កញ្ញា គាំ ធី**
កម្មការនីរោងចក្រ

# មាតិកា


## ពីចក្ខុវិស័យទៅជាតម្លៃពិត៖ របៀបដែល ហ្វីស ហ្វាយនែន ពង្រីកផលប័ត្រឥណទានដល់ ១០០ លានដុល្លារ ព្រមជាមួយការជំរុញផលប៉ះពាល់វិជ្ជមានដល់សង្គម

## ទិដ្ឋភាពទូទៅ

០៨. តួលេខសំខាន់ៗឆ្នាំ ២០២៥
១០. អំពីយើងខ្ញុំ

## សារទៅកាន់ភាគីពាក់ព័ន្ធ

១៤. សារពីប្រធានក្រុមប្រឹក្សាភិបាល
១៨. សារពីប្រធាននាយកប្រតិបត្តិ

## បរិយាកាសអាជីវកម្ម

២៤. តំបន់ប្រតិបត្តិការ
២៥. ផលិតផល និងដំណោះស្រាយ
២៦. ដៃគូផ្តល់ហិរញ្ញប្បទាន
២៧. ហេដ្ឋារចនាសម្ព័ន្ធអង្គភាព
២៨. ក្រុមប្រឹក្សាភិបាល
៣២. គណៈកម្មការនាយកប្រតិបត្តិ
៣៧. ការជម្រុញការកសាងទ្រព្យសម្បត្តិ និងសុខុមាលភាពសហគមន៍

## ការប្តេជ្ញាចំពោះនិរន្តរភាព

៤០. វិធីសាស្ត្ររបស់យើងក្នុងការរក្សាបាននូវនិរន្តរភាព
៤២. ក្របខណ្ឌនិរន្តភាព
៤៤. ការបន្តស្វែងរកភាពល្អឥតខ្ចោះនៃបទពិសោធន៍អតិថិជន
៤៥. ការពង្រឹងសមត្ថភាពហិរញ្ញវត្ថុសម្រាប់ការក្លាយជាម្ចាស់លំនៅឋាន
៤៧. ការផ្តល់ការគាំទ្រតាមលទ្ធភាពដែលយើងអាចធ្វើបាន
៤៩. ការជំរុញកន្លែងធ្វើការដែលមានសុវត្ថិភាព ការគោរព និងផ្តោតលើមនុស្ស
៥០. ការទាក់ទាញអ្នកមានសមត្ថភាព និងការកសាងបណ្តាញធនធានមនុស្សសំខាន់ៗ
៥២. ការគ្រប់គ្រងហានិភ័យអាកាសធាតុ និងការផ្តល់ឥណទានប្រកបដោយនិរន្តភាព
៥៣. ការគ្រប់គ្រងផលប៉ះពាល់បរិស្ថាននៃប្រតិបត្តិការ
៥៦. សមិទ្ធផល បរិស្ថាន សង្គម និងអភិបាលកិច្ច ESG
៦០. ការប្តេជ្ញាចិត្តចំពោះហិរញ្ញវត្ថុប្រកបដោយក្រមសីលធម៌ និងការទទួលខុសត្រូវ

## ការគ្រប់គ្រងហានិភ័យ

៦៤. ការគ្រប់គ្រងហានិភ័យ

## របាយការណ៍ហិរញ្ញវត្ថុ

៧០. របាយការក្រុមប្រឹក្សាភិបាល
៧៥. របាយការណ៍សវនកម្ម
៧៨. របាយការណ៍ហិរញ្ញវត្ថុ


សូមស្វាគមន៍មកកាន់របាយការណ៍ប្រចាំឆ្នាំ ២០២៥ របស់យើងខ្ញុំ ដែលជាប្រភេទអន្តរកម្ម PDF! ឯកសារនេះត្រូវបានបង្កើតឡើងដើម្បីផ្តល់ភាពងាយស្រួលដល់អ្នកអាន។ ដើម្បីងាយស្រួលក្នុងការអាន យើងណែនាំឱ្យប្រើ Adobe Reader។ លោកអ្នកអាចទៅកាន់ផ្នែកផ្សេងៗក្នុងរបាយការណ៍នេះបានយ៉ាងងាយស្រួល ដោយគ្រាន់តែចុចលើតំណភ្ជាប់នៅទៅកាន់ទំព័រនីមួយៗ ឬប្រើប៊ូតុងទំព័រដើម 🏠 ដែលមាននៅផ្នែកខាងក្រោម។

# តួលេខសំខាន់ៗ ឆ្នាំ ២០២៥

## សមិទ្ធផលហិរញ្ញវត្ថុ

ផលបត្រឥណទាន
**១០០,៤ លានដុល្លារ**
↑ ១១,៩១% ឆ្នាំ ២០២៤

ទ្រព្យសកម្មសរុប
**១០៧,៤ លានដុល្លារ**
↑ ១៥,២០% ឆ្នាំ ២០២៤

ផលលើទ្រព្យសកម្ម
**១,០៦%**
↓ ០,០៧% ឆ្នាំ ២០២៤

ផលលើមូលធន
**៦,០៦%**
↓ ០,១៣% ឆ្នាំ ២០២៤

ចំណូលក្រោយបង់ពន្ធ
**១,០៦ លានដុល្លារ**
↑ ៤,០៧% ឆ្នាំ ២០២៤





## សមិទ្ធផលមិនមែនហិរញ្ញវត្ថុ[១]

**១១.៨៤៧**
ចំនួនអតិថិជនសរុប

**៧៤%**
អតិថិជនដែលមានផ្ទះលើកដំបូង

**៥១%**
អតិថិជនបានប្រើប្រាស់កម្ចីដើម្បីកែលម្អបង្គន់អនាម័យ និងប្រព័ន្ធទឹកស្អាត

**៥១%**
អ្នកដែលមានលទ្ធភាពតិចតួចក្នុងការទទួលបានសេវាលំនៅឋានផ្លូវការ[២]

**មាស**
ទទួលស្គាល់កម្រិតខ្ពស់ លើគោលការណ៍ការពារអតិថិជន ជាលើកទីពីរ

**៩១%**
អតិថិជនជាស្ត្រី

**៨១%**
អតិថិជនជាស្វ័យនិយោជន៍ កម្មករចំណូលពីប្រាក់ខែ ដែលគ្មានលិខិតបញ្ជាក់

**៩១%**
អតិថិជនដែលមានលំនៅឋាន ក្នុងទីជនបទ

[១] តួលេខត្រូវបានបង្គត់ ការបូកសរុបចំនួន ឬជាភាគរយអាចលម្អៀងមិនត្រូវទៅតាមចំនួនពិតប្រាកដ

[២] ហ្វឺស ហ្វាយនែន បានចាត់ក្រុមអតិថិជនដែលមានចំណូលតិចជាង ៣០០ ដុល្លារក្នុងមួយខែ ជាប្រភេទអ្នកដែលត្រូវបានគេមើលរំលង ។ ពួកគាត់មានលទ្ធភាពតិចតួចក្នុងការទទួលបានសេវាកម្ចីលំនៅឋានខ្នាតតូចផ្លូវការ ដោយមូលហេតុស្ថានភាពប្រភពចំណូល។

# អំពីយើងខ្ញុំ

ហ្វឹស ហ្វាយនែន ជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនាំមុខគេមួយនៅកម្ពុជា និងមានឯកទេសក្នុងការផ្តល់កម្ចីលំនៅឋានខ្នាតតូចទៅដល់ប្រជាជនដែលមានចំណូលទាប និងមធ្យម។ ទីតាំងយុទ្ធសាស្ត្រនេះអនុញ្ញាតឱ្យ ហ្វឹស ហ្វាយនែន បំពេញចន្លោះទីផ្សារដែលត្រូវបានគេមើលរំលង ព្រោះធនាគារពាណិជ្ជស្ទើរតែទាំងអស់ ផ្តោតសំខាន់លើអតិថិជនគោលដៅដែលមានស្ថានភាពសេដ្ឋកិច្ចល្អ។ តាមរយៈការពង្រីកសេវាកម្មរបស់ខ្លួនទៅកាន់អ្នកដែលមានលទ្ធភាពតិចតួចក្នុងការទទួលបានសេវាកម្ចីលំនៅឋានផ្លូវការ ហ្វឹស ហ្វាយនែន បានដើរតួនាទីយ៉ាងសំខាន់ក្នុងការលើកស្ទួយបរិយាបន្នហិរញ្ញវត្ថុ និងពង្រីកវិសាលភាពសេវាកម្ចីលំនៅឋានខ្នាតតូចឱ្យកាន់តែទូលាយជាងមុន។

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ហ្វឹស ហ្វាយនែន ភីអិលស៊ី ធ្លាប់ជាក្រុមហ៊ុនដែលបណ្តាក់ទុនរួមគ្នារវាងក្រុមហ៊ុន ហ្វឹសហូម ភីអិលស៊ី ដែលមានទីតាំងក្នុងប្រទេសកម្ពុជា Phillip Capital ដែលមានទីតាំងក្នុងប្រទេសសិង្ហបុរី Insitor Fund ដែលមានទីតាំងក្នុងប្រទេសលុចសំបួរ មូលនិធិអភិវឌ្ឍន៍កម្ពុជាឡាវ (Cambodia-Laos Development Fund) និង Norfund ដែលមានទីតាំងក្នុងប្រទេសន័រវេស។ មកដល់ខែ មិថុនា ឆ្នាំ ២០២២ ភាគហ៊ុន ១០០% ត្រូវបានផ្ទេរដោយស្ថិតនៅក្រោមការគ្រប់គ្រងក្រុមហ៊ុនក្នុងស្រុក។



## ក្រុមការងាររបស់យើង និងវប្បធម៌បំពេញការងារ

ការកសាងក្រុមការងារដែលមានការចូលរួម មានជំនាញ និងមានទំនួលខុសត្រូវខ្ពស់ គឺសំខាន់ណាស់សម្រាប់ការសម្រេចយុទ្ធសាស្ត្ររបស់យើង និងផ្តល់លទ្ធផលវិជ្ជមានសម្រាប់អតិថិជន បុគ្គលិក សហគមន៍ និងម្ចាស់ភាគហ៊ុនរបស់យើង។

+ អានបន្ថែមទំព័រ ៤៨-៥០

ក្រមសីលធម៌ ជួយឱ្យក្រុមការងាររបស់យើងរក្សាជំហរបានត្រឹមត្រូវស្របតាមគោលបំណង និងយុទ្ធសាស្ត្ររបស់យើង ដោយវាបានគូសបញ្ជាក់ពីរបៀបដែលយើងគួរប្រព្រឹត្ត និងធ្វើការសម្រេចចិត្ត។ គ្រប់កិច្ចការដែលយើងខ្ញុំអនុវត្តគឺឈរលើគុណតម្លៃរបស់យើងជានិច្ច។

**. សុចរិតភាព** **. ភាពច្នៃប្រឌិតខ្ពស់** **. ឧត្តមភាព**
**. ការឆ្លើយតប** **. ភាពស្មើគ្នា**

→ ស្វែងយល់បន្ថែមពីគុណតម្លៃនៅលើ firstfinance.com.kh/about-us

គោលការណ៍ភាពជាអ្នកដឹកនាំរបស់យើង បានបង្ហាញផ្លូវដល់អ្នកដឹកនាំឱ្យយល់ពីអ្វីដែលត្រូវធ្វើ ដើម្បីដឹកនាំប្រកបដោយប្រសិទ្ធភាព និងអនុវត្តយុទ្ធសាស្ត្ររបស់យើងប្រកបដោយជោគជ័យ។ ទស្សនៈអាជីវកម្មរបស់យើងគឺសាមញ្ញណាស់៖ **យើងគិតដូចអតិថិជន និងដើរតួដូចម្ចាស់**។ វិធីសាស្ត្ររបស់យើងកាន់តែសាមញ្ញទៀត៖

- ផ្តល់សេវា និងផលិតផលដែលឆ្លើយតបទៅនឹងតម្រូវការទីផ្សារ
- ផ្តល់នូវនីតិវិធីដែលមានភាពរហ័ស និងងាយស្រួល
- ធ្វើប្រតិបត្តិការប្រកបដោយភាពបត់បែន និងមានតម្លាភាព
- បង្ហាញពីភាពសុចរិតទៀងត្រង់ និងសីលធម៌ក្នុងការអនុវត្តអាជីវកម្ម

## អាជីវកម្មរបស់យើង

យើងខ្ញុំផ្តល់ជូននូវជម្រើស សម្រាប់កម្ចីលំនៅឋានផ្ទះរយៈពេលវែងដូចជា កម្ចីទិញផ្ទះ សាងសង់ផ្ទះ កម្ចីកែលម្អផ្ទះ កម្ចីទិញដីលំនៅឋាន កម្ចីអចលនទ្រព្យធានា និងកម្ចីរយៈពេលមធ្យម កម្ចីបង្កើនចំណូល (កម្ចីអាជីវកម្មខ្នាតតូច)

- កម្ចីទិញផ្ទះ និងសាងសង់ផ្ទះ
- កម្ចីកែលម្អផ្ទះ
- កម្ចីទិញដីលំនៅឋាន
- កម្ចីអចលនទ្រព្យធានា
- កម្ចីបង្កើនចំណូល (កម្ចីអាជីវកម្មខ្នាតតូច)

## ដៃគូដែលពាក់ព័ន្ធ

នៅពេលបានស្វែងយល់ពីសេចក្តីត្រូវការ និងការរំពឹងទុករបស់ដៃគូដែលពាក់ព័ន្ធ នោះយើងនឹងកោតសរសើរ ចំពោះភាពចម្រុះផ្សេងៗគ្នារបស់ពួកគេ និងការផ្តល់លទ្ធផលដែលនាំមកនូវប្រយោជន៍សម្រាប់គ្រប់គ្នា។

គោលដៅរបស់យើងខ្ញុំ គឺកសាងទំនុកចិត្ត និងលើកកម្ពស់កេរ្តិ៍ឈ្មោះរបស់យើង ដោយផ្តល់អាទិភាពលើតម្រូវការរបស់អតិថិជន និងចូលរួមចំណែកជួយទៅដល់សហគមន៍។

- អតិថិជន
- ក្រុមការងាររបស់យើង
- សហគមន៍ ឧស្សាហកម្ម និងសង្គមស៊ីវិល
- វិនិយោគិន
- រដ្ឋាភិបាល និងនិយ័តករ
- អ្នកផ្គត់ផ្គង់



នៅ ហ្វីស ហ្វាយនែន យើងខ្ញុំជឿថាកម្មសិទ្ធិនៃផ្ទះសម្បែង គឺជាជំហានឆ្ពោះទៅរកជីវិតប្រសើរឡើង។ ការមានផ្ទះជាកម្មសិទ្ធិផ្ទាល់ខ្លួន បានផ្តល់នូវស្ថិរភាពដល់ក្រុមគ្រួសារ ដោយអនុញ្ញាតឱ្យពួកគេចំណាយពេលវេលា និងថាមពល ទៅលើផ្នែកសំខាន់ផ្សេងទៀតនៃជីវិត។ កុមារអាចផ្តោតលើការសិក្សារបស់ពួកគេ ស្ត្រីអាចបន្តអាជីពឬចាប់ផ្តើមអាជីវកម្ម ចំណែកឯគ្រួសារទាំងមូលក៏អាចកសាងទំនាក់ទំនងរឹងមាំជាមួយអ្នកជិតខាង និងសហគមន៍របស់ពួកគេ។ ទំនាក់ទំនងទាំងនេះបានលើកកម្ពស់ដល់ការលូតលាស់ ការគោរពខ្លួនឯង និងអារម្មណ៍ដ៏ជ្រាលជ្រៅដែលខ្លួនគេជាចំណែកមួយនៅក្នុងសហគមន៍ដែលពួកគេរស់នៅ។ លើសពីនេះទៀត ការមានផ្ទះជាកម្មសិទ្ធិផ្ទាល់ខ្លួន ក៏បានបង្កើតឱ្យមានអត្តសញ្ញាណប្រចាំគ្រួសារ សុវត្ថិភាពផ្ទាល់ខ្លួន និងសុខុមាលភាពគ្រួសារផងដែរ ដែលវាបង្កើតជាមូលដ្ឋានគ្រឹះសម្រាប់អនាគតដ៏ភ្លឺស្វាង។

# សារពីប្រធានក្រុមប្រឹក្សាភិបាល



**ការផ្តល់ជូនលំនៅឋានដែលមានតម្លៃសមរម្យ នៅតែជាបញ្ហាប្រឈមដ៏សំខាន់មួយនៅក្នុងប្រទេសកម្ពុជា។ យើងបន្តដើរតួជាស្ថានចម្លង ដើម្បីបំពេញតម្រូវការសម្រាប់ក្រុមគ្រួសារវ័យក្មេង និងម្ចាស់អាជីវកម្មខ្នាតតូច ដោយធានាថាពួកគាត់ទទួលបានការគាំទ្រផ្នែកហិរញ្ញវត្ថុដែលចាំបាច់ ដើម្បីកសាងអនាគតមួយដ៏រឹងមាំ។**

“

លោក Hanco Halbertsma
ប្រធានក្រុមប្រឹក្សាភិបាល



## សេដ្ឋកិច្ច និងប្រទេសជាតិបានជួបប្រទះនូវបញ្ហាប្រឈមក្នុងឆ្នាំ ២០២៥

សេដ្ឋកិច្ចរបស់ប្រទេសកម្ពុជានៅក្នុងឆ្នាំ ២០២៥ បានបង្ហាញនូវភាពធន់ ក្នុងអំឡុងពេលដែលមានភាពមិនប្រាកដប្រជានៃស្ថានភាពសកលលោក និងតំបន់។ ទោះបីជាសេដ្ឋកិច្ចបានបន្តរីកចម្រើនក្នុងរង្វង់ ៥% ក៏ដោយ ក៏វាបានរងផលប៉ះពាល់អវិជ្ជមានដោយសារជម្លោះព្រំដែនជាមួយប្រទេសថៃ ការដំឡើងពន្ធគយដោយសហរដ្ឋអាមេរិក និងការធ្លាក់ចុះនៃតម្រូវការសកលលើវិស័យកាត់ដេរ ទេសចរណ៍ និងផលិតផលកសិកម្ម។

ទោះបីជាមានកិច្ចខិតខំប្រឹងប្រែងក្នុងការដោះស្រាយជម្លោះព្រំដែនជាមួយប្រទេសថៃយ៉ាងណាក៏ដោយ ការប៉ះទង្គិចគ្នាបន្តិចបន្តួចបានរីករាលដាលទៅជាសមរភូមិ ដែលបណ្តាលឱ្យប្រជាពលរដ្ឋកម្ពុជារាប់ពាន់នាក់ត្រូវជម្លៀសខ្លួន។ កត្តានេះនាំឱ្យវិស័យទេសចរណ៍ក្នុងតំបន់ដែលរងផលប៉ះពាល់មានការធ្លាក់ចុះយ៉ាងខ្លាំង ហើយពលករចំណាកស្រុកកម្ពុជាមួយចំនួនធំមិនអាចផ្ញើថវិកាមកជួយគ្រួសាររបស់ពួកគេបានដូចមុន។ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ហ្វីស ហ្វាយនែន ភីអិលស៊ី មានការព្រួយបារម្ភចំពោះការវិវត្តទាំងនេះ ហើយបានចូលរួមជួយដល់ប្រជាពលរដ្ឋក្នុងតំបន់តាមដែលអាចធ្វើទៅបាន ប៉ុន្តែជាភ័ព្វសំណាង អតិថិជនរបស់យើងមិនមានការរងផលប៉ះពាល់ច្រើននោះទេ។

## វិស័យហិរញ្ញវត្ថុ ប្រឈមនឹងការកាត់បន្ថយកំណើន និងហានិភ័យខ្ពស់

ខណៈពេលដែលវិស័យហិរញ្ញវត្ថុបានរីកចម្រើនយ៉ាងឆាប់រហ័សក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងមក បច្ចុប្បន្នវិស័យនេះកំពុងប្រឈមមុខនឹងបញ្ហាសំខាន់ៗមួយចំនួន ដែលបញ្ហាមួយក្នុងចំណោមនោះគឺ អត្រាឥណទានមិនដំណើរការ មានកម្រិតខ្ពស់គួរឱ្យកត់សម្គាល់ និងបញ្ហាមួយទៀតគឺវិស័យអចលនទ្រព្យ។ មូលហេតុគឺដោយសារមានការសាងសង់ផ្ទះច្រើនហួសហេតុក្នុងគម្រោងអភិវឌ្ឍន៍ថ្មីៗ ខណៈដែលតម្រូវការនៅមានកម្រិតតិចតួចនៅឡើយ ហើយហានិភ័យសម្រាប់ស្ថាប័នដែលផ្តល់ហិរញ្ញប្បទានដល់អ្នកអភិវឌ្ឍន៍អចលនទ្រព្យ និងអ្នកទិញចុងក្រោយមានកម្រិតខ្ពស់។ ដោយសារមិនទាន់មានទីផ្សារសម្រាប់ផ្ទះដែលបានប្រើប្រាស់ហើយ ដូចនេះតម្លៃទ្រព្យបញ្ចាំមានឥទ្ធិពលតិចតួចក្នុងការកាត់បន្ថយហានិភ័យឥណទានសម្រាប់ធនាគារ។ ការរៀបចំឥណទានឡើងវិញនៅតែបន្តផ្តល់ជូនដល់អ្នកខ្ចីដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ប៉ុន្តែវាមិនប្រាកដថានឹងអាចកាត់បន្ថយហានិភ័យរបស់ពួកគេបានឡើយ ព្រោះជាទូទៅកម្រិតចំណូលរបស់គ្រួសារជាច្រើនមានការថយចុះ។ ហ្វីស ហ្វាយនែន បានធ្វើប្រតិបត្តិការក្នុងវិស័យលំនៅឋានដែលមានតម្លៃសមរម្យ ដែលជាផ្នែកមួយរងផលប៉ះពាល់តិចតួចបំផុតនៃវិស័យអចលនទ្រព្យ ទោះជាយ៉ាងណាក៏ដោយ យើងនៅតែប្រឈមមុខនឹងបញ្ហាឥណទានរៀបចំឡើងវិញចំពោះគ្រួសារដែលមានចំណូលធ្លាក់ចុះ និងឥណទានមួយចំនួនដែលបានផ្តល់តាមរយៈអ្នកអភិវឌ្ឍន៍អចលនទ្រព្យកាលពីអតីតកាល នៅតែស្ថិតក្នុងស្ថានភាពខកខានការបង់ប្រាក់។

## វិស័យមីក្រូហិរញ្ញវត្ថុ និងលំនៅឋានតម្លៃសមរម្យនៅតែជាឱកាសដ៏ធំ

វិស័យមីក្រូហិរញ្ញវត្ថុនៅតែបន្តដើរតួនាទីយ៉ាងសំខាន់ក្នុងការគាំទ្រដល់ការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយបរិយាបន្ននៅក្នុងប្រទេសកម្ពុជា។ ប្រសិនបើមិនរាប់បញ្ចូលផលប័ត្រមីក្រូហិរញ្ញវត្ថុរបស់ធនាគារដែលទើបតែបានបំប្លែងខ្លួនពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទេនោះ វិស័យនេះបានផ្តល់សេវាដល់អ្នកខ្ចីចំនួន ១,៥ លាននាក់ និងរក្សាបាននូវផលប័ត្រឥណទានចំនួន ៦,៥ ប៊ីលានដុល្លារអាមេរិក។ ចំណុចនេះសបញ្ជាក់ឱ្យឃើញពីសារៈសំខាន់នៃវិស័យនេះក្នុងការផ្តល់ឥណទានដល់គ្រួសារ និងអាជីវកម្មខ្នាតតូចដែលមិនទាន់ទទួលបានសេវាពេញលេញពីស្ថាប័នធនាគារពាណិជ្ជ។

លំនៅឋានតម្លៃសមរម្យនៅតែជាបញ្ហាប្រឈមដ៏ខ្លាំងក្លាមួយក្នុងចំណោមបញ្ហាប្រឈមនៃការអភិវឌ្ឍន៍ក្នុងសេដ្ឋកិច្ចកម្ពុជាដែលកំពុងមានការរីកសាយភាយនៃតំបន់ប្រជុំជនយ៉ាងឆាប់រហ័ស។ កំណើនប្រជាជន ជាមួយនឹងរចនាសម្ព័ន្ធប្រជាសាស្ត្រវ័យក្មេង ដែលភាគច្រើនចង់ចាប់ផ្តើមជីវិតគ្រួសារ និងផ្លាស់ទីមកកាន់រាជធានីភ្នំពេញ លទ្ធភាពក្នុងការទទួលបានហិរញ្ញប្បទានលំនៅឋានរយៈ

ពេលវែងរបស់ពួកគេនៅមានកម្រិត។ កត្តានេះបន្តបង្កើតឱ្យមានគម្លាតយ៉ាងខ្លាំងរវាងតម្រូវការ និងការផ្គត់ផ្គង់នៅក្នុងផ្នែកលំនៅឋានតម្លៃសមរម្យ ដែលបង្ហាញថាឆ្នាំខាងមុខនឹងនៅតែផ្ដល់ឱកាសទីផ្សារដ៏ធំសម្រាប់ ហ្វឺស ហ្វាយនែន។

## លទ្ធផលការងារដ៏រឹងមាំក្នុងឆ្នាំ ២០២៥

ក្រុមប្រឹក្សាភិបាលមានសេចក្ដីសោមនស្សរីករាយដែលបានឃើញថាគណៈគ្រប់គ្រងបានពង្រីកអាជីវកម្មដោយជោគជ័យក្នុងឆ្នាំ ២០២៥ តាមរយៈការបើកសាខាថ្មីចំនួន ៦ កន្លែង បម្រើអតិថិជនប្រមាណ ១២,០០០ នាក់ ដែលភាគច្រើនជាគ្រួសារដែលមានចំណូលទាប និងប្រកបអាជីវកម្មខ្នាតតូចផ្ទាល់ខ្លួន និងបានធ្វើឱ្យផលប័ត្រឥណទានកើនឡើងដល់ ១០០ លានដុល្លារអាមេរិក។ ការសម្រេចបាននូវទំហំផលប័ត្រនេះ គឺជាសមិទ្ធផលដ៏សំខាន់ក្នុងរយៈពេល ១៦ ឆ្នាំនៃប្រតិបត្តិការរបស់យើង។

នាយកគណៈគ្រប់គ្រងបានបន្តផ្ដោតការយកចិត្តទុកដាក់យ៉ាងខ្លាំងលើការគ្រប់គ្រងហានិភ័យ គោលដៅបរិស្ថាន សង្គម និងអភិបាលកិច្ច (ESG) នវានុវត្តន៍ឌីជីថល និងជាពិសេសលើសេវាកម្មអតិថិជន។ លើសពីនេះ បានបង្ហាញឱ្យឃើញពីការកែសម្រួល និងកែលម្អគំរូអាជីវកម្មដោយជោគជ័យ ដើម្បីរក្សាតុល្យភាពរវាងកំណើនផលប័ត្រ និងការត្រួតពិនិត្យហានិភ័យ។

ដោយពិចារណាពិនិត្យឃើញថា ក្នុងអំឡុងឆ្នាំ ២០២៥ សេដ្ឋកិច្ចត្រូវបានប្រឈមដោយព្រឹត្តិការណ៍ម៉ាក្រូសេដ្ឋកិច្ច ហើយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុផ្សេងទៀត ក៏ដូចជាគ្រឹះស្ថានមួយចំនួនដែលបានបំប្លែងខ្លួនជាធនាគារពាណិជ្ជរួចហើយនោះ ក៏មិនអាចពង្រីកអាជីវកម្មបានច្រើនដែរ ដូច្នេះការសម្រេចបាននូវសមិទ្ធផលក្នុងកម្រិតនេះរបស់ ហ្វឺស ហ្វាយនែន វាគឺជារឿងគួរឱ្យចាប់អារម្មណ៍ និងក្លាយជាមូលដ្ឋានគ្រឹះដ៏ល្អសម្រាប់ភាពជោគជ័យបន្តទៅមុខទៀត។

## ទស្សនវិស័យប្រកបដោយសុទិដ្ឋិនិយមសម្រាប់ឆ្នាំ ២០២៦

ក្រឡេកទៅមើលឆ្នាំ ២០២៦ ទស្សនវិស័យរបស់កម្ពុជានៅតែមានសុទិដ្ឋិនិយមប្រកបដោយការប្រុងប្រយ័ត្ន។ កំណើនសេដ្ឋកិច្ចត្រូវបានរំពឹងថានឹងមានស្ថិរភាព ខណៈដែលការកែទម្រង់រចនាសម្ព័ន្ធ ការបន្តវិនិយោគពីបរទេស និងការងើបឡើងវិញជាបណ្តើរៗនៃវិស័យទេសចរណ៍នឹងជួយគាំទ្រដល់តម្រូវការក្នុងស្រុក។ ទោះបីជាហានិភ័យនៅតែមាន ដូចជាកម្រិតហានិភ័យឥណទានខ្ពស់ និងការផ្គត់ផ្គង់លើសតម្រូវការក្នុងវិស័យអចលនទ្រព្យ ក៏ដូចជាពាណិជ្ជកម្មអន្តរជាតិដែលរងគ្រោះពីបញ្ហាប្រឈមក្នុងតំបន់ និងសកលលោក ប៉ុន្តែមូលដ្ឋានគ្រឹះដ៏រឹងមាំរបស់ប្រទេសនឹងជួយឱ្យសេដ្ឋកិច្ចមានកំណើនសមរម្យក្នុងឆ្នាំ ២០២៦។

តាងនាមឱ្យក្រុមប្រឹក្សាភិបាល ខ្ញុំសូមថ្លែងអំណរគុណដល់បុគ្គលិក និងក្រុមការងារគ្រប់គ្រងទាំងអស់ ក្រុមគ្រួសារអតិថិជន ដៃគូផ្ដល់មូលនិធិ និងធនាគារជាតិនៃកម្ពុជា ចំពោះការគាំទ្រជាបន្តបន្ទាប់ និងសូមជូនពរឱ្យ ហ្វឺស ហ្វាយនែន ទទួលបានជោគជ័យក្នុងឆ្នាំ ២០២៦!

**លោក Hanco Halbertsma**
ប្រធានក្រុមប្រឹក្សាភិបាល





# បរិយាបន្នហិរញ្ញវត្ថុ ដែលផ្តល់នូវជីវភាពដ៏ប្រសើរសម្រាប់គ្រួសារនៅតាមជនបទ

អ្នកស្រី ឃឹម គឹមហួយ គឺជាស្ត្រីមេម៉ាយដ៏តស៊ូ និងរឹងមាំម្នាក់នៅក្នុងខេត្តតាកែវ ដែលបានលះបង់កម្លាំងកាយចិត្តមើលថែកូនៗទាំងពីរតែម្នាក់ឯង។ ទោះបីជាកូនស្រីច្បងវ័យ ២២ឆ្នាំរបស់អ្នកស្រីមានពិការភាព (គ) ក្តី ប៉ុន្តែនាងគឺជាកម្លាំងដ៏សំខាន់ក្នុងការជួយជ្រោមជ្រែងអ្នកម្តាយប្រកបរបរត្បាញហូលផាមួង ដែលជាប្រភពចំណូលចម្បងរបស់គ្រួសារ ដោយគួបផ្សំនឹងការធ្វើស្រែបន្តិចបន្តួចផងនោះ។

បញ្ហាប្រឈមដ៏ធំមួយសម្រាប់គ្រួសារអ្នកស្រី គឺកង្វះខាតថវិកាមួយចំនួនក្នុងការបង្គ្រប់ការសាងសង់ផ្ទះឱ្យបានរួចរាល់ ជាពិសេសគឺកង្វះខាតទីតាំងសមរម្យសម្រាប់ដាក់កីតម្បាញ។ ដោយសារគ្មានសំយ៉ាបផ្ទះត្រឹមត្រូវ ការប្រកបរបរត្បាញហូលជួបការលំបាកយ៉ាងខ្លាំង ព្រោះត្រូវប្រឈមនឹងកម្ដៅថ្ងៃខ្លាំង និងក្តីបារម្ភនៅពេលមានភ្លៀងធ្លាក់ ម្ដងៗ ដែលអាចធ្វើឱ្យខូចខាតដល់សរសៃសូត្រ និងកីតម្បាញដែលជាឆ្នាំងបាយរបស់គ្រួសារ។

ថ្ងៃមួយ តាមរយៈការចុះផ្សព្វផ្សាយផ្ទាល់របស់បុគ្គលិកស្ថាប័ន ហ្វឺស ហ្វាយនែន ដល់មូលដ្ឋាន អ្នកស្រី គឹមហួយ បានស្វែងយល់ពីសេវាកម្មឥណទានដែលមានភាពបត់បែន និងស័ក្តិសមនឹងតម្រូវការរបស់គាត់។

ដោយមើលឃើញពីឱកាសក្នុងការដោះស្រាយបញ្ហា អ្នកស្រីបានសម្រេចចិត្តស្នើសុំកម្ចីពី ហ្វឺស ហ្វាយនែន ដើម្បីយកមក កែលម្អគេហដ្ឋាន និងបង្គ្រប់ការធ្វើផ្ទះ ឱ្យបានរួចរាល់ជាស្ថាពរ។ ក្រោយពីទទួលបានប្រាក់កម្ចី និងរៀបចំផ្ទះសម្បែងរួចរាល់ ជីវភាព និងការប្រកបរបររបស់អ្នកស្រី គឹមហួយ មានភាពងាយស្រួល ដោយសំយ៉ាបផ្ទះថ្មីបានផ្តល់ជាម្លប់ដ៏ត្រជាក់ត្រជុំ និងសុវត្ថិភាព ធ្វើឱ្យអ្នកស្រី និងកូនស្រីអាចរៀបចំកីតម្បាញបានយ៉ាងងាយស្រួល លែងព្រួយបារម្ភពីរឿងភ្លៀង ឬកំដៅថ្ងៃ ដែលជួយឱ្យការត្បាញហូលផាមួងប្រព្រឹត្តទៅបានរលូន និងអាចរក្សាចំណូលបានថេរ។

សាច់រឿងរបស់អ្នកស្រី ឃឹម គឹមហួយ បានសបញ្ជាក់ឱ្យឃើញថា ទោះបីជាស្ថិតក្នុងស្ថានភាពជាស្ត្រីមេម៉ាយ និងមានកូនពិការភាពក៏ដោយ តាមរយៈការព្យាយាម រួមផ្សំនឹងការគាំទ្រផ្នែកហិរញ្ញវត្ថុទាន់ពេលវេលា គាត់អាចរៀបចំទីជម្រកបានសមរម្យ និងពង្រឹងមុខរបរដើម្បីអនាគតដ៏ភ្លឺស្វាងសម្រាប់កូនៗរបស់គាត់បាន។

# សារពីប្រធាននាយកប្រតិបត្តិ

សមិទ្ធផលរបស់យើងក្នុងឆ្នាំ ២០២៥ បានបញ្ជាក់ឱ្យឃើញថា និរន្តរភាពហិរញ្ញវត្ថុ និងសុចរិតភាពសង្គម ត្រូវតែដើរទន្ទឹមគ្នា។ ការរក្សាបាននូវ "វិញ្ញាបនបត្រការពារអតិថិជនកម្រិតមាស" ជាមួយនឹងពិន្ទុរហូតដល់ ៩៩,១% គឺជាការប្តេជ្ញាចិត្តរបស់យើងចំពោះក្រុមគ្រួសារចំនួន ១១.៨៤៧ ដែលយើងកំពុងបម្រើសេវាកម្មជូន។

លោក ស៊ីម សេនាជាតិ
ប្រធាននាយកប្រតិបត្តិ





## គោរពជូនចំពោះភាគីពាក់ព័ន្ធទាំងអស់ជាទីរាប់អាន!

ឆ្នាំ ២០២៥ គឺជាទំព័រថ្មីដ៏សំខាន់មួយក្នុងដំណើររបស់ ហ្វីស ហ្វាយនែន។ ក្នុងឆ្នាំនេះ យើងសម្រេចបាននូវសមិទ្ធផលដ៏ធំធេងមួយ គឺការជំរុញផលប័ត្រឥណទានឱ្យហក់ហួស ១០០ លានដុល្លារអាមេរិក ព្រមទាំងបានបញ្ជាក់ជាថ្មីនូវការប្តេជ្ញាចិត្តរបស់យើងចំពោះកំណើនប្រកបដោយការទទួលខុសត្រូវ បរិយាបន្នហិរញ្ញវត្ថុ និងផលប៉ះពាល់សង្គមដែលអាចវាស់វែងបាន។ នៅពីក្រោយសមិទ្ធផលនេះ គឺមានគ្រួសារកម្ពុជាចំនួន ១១,៨៤៧ គ្រួសារ ដែលបច្ចុប្បន្នកំពុងរីករាយជាមួយស្ថិរភាព សេចក្តីថ្លៃថ្នូរ និងឱកាសកាន់តែប្រសើរតាមរយៈការមានផ្ទះជាកម្មសិទ្ធផ្ទាល់ខ្លួន។

## កំណើនប្រកបដោយភាពធន់ក្នុងទីផ្សារដែលមានការកែសម្រួល

ទោះបីជាមានការកែសម្រួលជាបន្តបន្ទាប់នៅក្នុងទីផ្សារអចលនទ្រព្យក៏ដោយ សេដ្ឋកិច្ចកម្ពុជាក្នុងឆ្នាំ ២០២៥ នៅតែរក្សាបាននូវស្ថិរភាព ដោយទទួលបានការគាំទ្រពីការងើបឡើងវិញនៃវិស័យសំខាន់ៗ។ ក្នុងបរិបទនេះ ហ្វីស ហ្វាយនែន បានបង្ហាញពីកំណើនប្រកបដោយវិន័យ និងប្រតិបត្តិការដែលមានភាពធន់។

ផលប័ត្រឥណទានសរុបរបស់យើងខ្ញុំបានកើនឡើងដល់ ១០០,៤ លានដុល្លារអាមេរិក ដែលឆ្លុះបញ្ចាំងពីការកើនឡើង ១១,៩% ធៀបនឹងឆ្នាំមុន ខណៈដែលទ្រព្យសកម្មសរុបបានកើនឡើងដល់ ១០៧,៤ លានដុល្លារអាមេរិក។ យើងខ្ញុំសម្រេចបាននូវប្រាក់ចំណេញក្រោយបង់ពន្ធចំនួន ១,០៦ លានដុល្លារអាមេរិក ដោយផ្តល់នូវអនុបាតចំណេញលើទ្រព្យសកម្ម (ROA) ១,០៦% និងអនុបាតចំណេញលើមូលធន (ROE) ៦,០៦%។ លទ្ធផលទាំងនេះសបញ្ជាក់ថា និរន្តរភាពហិរញ្ញវត្ថុ និងសុចរិតភាពសង្គម គឺជាកត្តាដែលជួយជំរុញគ្នាទៅវិញទៅមក។

អ្វីដែលសំខាន់នោះគឺ ៩១% នៃអតិថិជនរបស់យើងខ្ញុំរស់នៅក្នុងតំបន់ជនបទ ហើយ ៨១% គឺជាស្វ័យនិយោជន៍ ឬអ្នកមានចំណូលតែមិនមានឯកសារបញ្ជាក់ច្បាស់លាស់ ហើយពួកគាត់ជារឿយៗមិនសូវទទួលបានសេវាពេញលេញពីគ្រឹះស្ថានហិរញ្ញវត្ថុផ្លូវការ។ ប្រហែល ៧៤% គឺជាអ្នកដែលមានផ្ទះជាលើកដំបូង។ នេះគឺជាការវាស់វែងពិតប្រាកដនៃជោគជ័យរបស់យើងខ្ញុំ។

## ការពង្រីកវិសាលភាព និងការពង្រឹងសហគមន៍

ក្នុងឆ្នាំ ២០២៥ យើងខ្ញុំបានពង្រីកខ្លួនទៅកាន់ខេត្តចំនួន ៦ បន្ថែមទៀត រួមមាន៖ តាកែវ ព្រៃវែង ស្វាយរៀង កំពង់ធំ ពោធិ៍សាត់ និងកំពង់ឆ្នាំង ដែលធ្វើឱ្យបណ្តាញការិយាល័យទូទាំងប្រទេសកើនដល់ ២០ សាខា។ ការពង្រីកនេះអនុញ្ញាតឱ្យយើងខ្ញុំផ្តល់ហិរញ្ញប្បទានលំនៅដ្ឋានតម្លៃសមរម្យដល់គ្រួសារដែលត្រូវការបំផុត។

ក្រៅពីការផ្តល់ឥណទានលំនៅឋាន យើងខ្ញុំបន្តគាំទ្រដល់លក្ខខណ្ឌរស់នៅប្រកបដោយសុខភាពល្អ។ អតិថិជនប្រហែល ៥១% បានប្រើប្រាស់ឥណទានរបស់ពួកគេដើម្បីកែលម្អប្រព័ន្ធទឹកស្អាត បង្គន់អនាម័យ (WASH) ដែលរួមចំណែកដោយផ្ទាល់ដល់ការលើកកម្ពស់សុខភាពគ្រួសារ និងភាពធន់នឹងការប្រែប្រួលអាកាសធាតុ។

វិធីសាស្ត្រដែលផ្តោតលើអតិថិជនជាចម្បងរបស់យើងខ្ញុំនៅតែរឹងមាំ ដែលអាចឆ្លុះបញ្ចាំងតាមរយៈអត្រារក្សាអតិថិជនបានរហូតដល់ ៩៨% និងពិន្ទុសុច្ឆន្ទៈអតិថិជន (NPS) កើនឡើងដល់ ៦៨.៦% ដែលនេះបង្ហាញពីទំនុកចិត្ត និងការពេញចិត្តប្រកបដោយនិរន្តរភាពក្នុងចំណោមសហគមន៍ដែលយើងខ្ញុំបម្រើ។

## អភិបាលកិច្ច សុចរិតភាព និងហិរញ្ញវត្ថុប្រកបដោយការទទួលខុសត្រូវ

សុចរិតភាពនៅតែជាស្នូលនៃយុទ្ធសាស្ត្រកំណើនរបស់យើងខ្ញុំ។ ក្នុងឆ្នាំ ២០២៥ ហ្វីស ហ្វាយនែន បានទទួលវិញ្ញាបនបត្រកម្រិតមាសលើកិច្ចការពារអតិថិជន ជាលើកទីពីរជាប់គ្នា ដោយសម្រេចបានពិន្ទុយ៉ាងខ្ពស់រហូតដល់ ៩៩.១%។ ការទទួលស្គាល់នេះសង្កត់ធ្ងន់លើការប្តេជ្ញាចិត្តរបស់យើងខ្ញុំចំពោះការកំណត់តម្លៃប្រកបដោយយុត្តិធម៌ ការការពារការជាប់បំណុលលើសលប់ ឯកជនភាពទិន្នន័យ និងការប្រព្រឹត្តចំពោះអតិថិជនប្រកបទៅដោយក្រមសីលធម៌។

យើងខ្ញុំក៏បានរក្សានូវស្លាកសញ្ញាពណ៌ទឹកក្រូច (Orange Seal) ដែលឆ្លុះបញ្ចាំងពីវឌ្ឍនភាពបន្តបន្ទាប់របស់យើងខ្ញុំលើសមភាពយេនឌ័រ និងនិរន្តរភាពបរិស្ថាន។ ការទទួលស្គាល់ទាំងនេះបញ្ជាក់ថា អភិបាលកិច្ចរឹងមាំ និងហិរញ្ញវត្ថុប្រកបដោយការទទួលខុសត្រូវ គឺជាមូលដ្ឋានគ្រឹះនៃនិរន្តរភាពរយៈពេលវែងរបស់យើងខ្ញុំ។

## នវានុវត្តន៍ឌីជីថល និងចំណេះដឹងហិរញ្ញវត្ថុ

យើងខ្ញុំបានបន្តពង្រឹងសមត្ថភាពឌីជីថល ដើម្បីបង្កើនប្រសិទ្ធភាពសុវត្ថិភាពប្រព័ន្ធ និងបទពិសោធន៍អតិថិជន ដោយសម្រេចបាននូវស្ថិរភាពប្រព័ន្ធប្រតិបត្តិការ ៩៩.៩% និងបានភ្ជាប់ជាមួយថ្នាលរបស់ដៃគូតាមរយៈប្រព័ន្ធ KHQR ដើម្បីផ្តល់នូវជម្រើសនៃការទូទាត់សងប្រាក់ដែលលឿន មានសុវត្ថិភាព និងកាន់តែងាយស្រួលសម្រាប់អតិថិជន។

ក្នុងឆ្នាំ ២០២៥ យើងក៏បានពង្រឹងគំនិតផ្តួចផ្តើមពាក់ព័ន្ធចំណេះដឹងហិរញ្ញវត្ថុ ដោយប្រើប្រាស់មាតិកាជាវីដេអូដែលបង្កើតដោយបញ្ញាសិប្បនិម្មិត ផ្សព្វផ្សាយនៅលើបណ្តាញឌីជីថលរបស់យើងខ្ញុំ។ តាមរយៈវីដេអូអប់រំដែលទាក់ទាញ និងងាយយល់ យើងបានជំរុញការយល់ដឹងអំពីការខ្ចីប្រាក់ប្រកបដោយការទទួលខុសត្រូវ ការគ្រប់គ្រងហិរញ្ញវត្ថុគ្រួសារបានល្អ និងវិន័យហិរញ្ញវត្ថុរយៈពេលវែង។ ការមានផ្ទះជាកម្មសិទ្ធិផ្ទាល់ខ្លួនប្រកបដោយនិរន្តរភាព ចាប់ផ្តើមពីការសម្រេចចិត្តដែលមានព័ត៌មានច្បាស់លាស់ ហើយយើងនៅតែប្តេជ្ញាចិត្តក្នុងការផ្តល់ជូនគ្រួសារទាំងនោះ នូវចំណេះដឹង និងឧបករណ៍អនុវត្តន៍ជាក់ស្តែងដែលចាំបាច់ដើម្បីទទួលបានជោគជ័យផ្នែកហិរញ្ញវត្ថុ។

## ទស្សនវិស័យទៅថ្ងៃអនាគត

មូលដ្ឋានគ្រឹះរបស់យើងខ្ញុំ គឺមានលក្ខណៈរឹងមាំ បើទោះបីជាលក្ខខណ្ឌទីផ្សារនៅតែមានការប្រែប្រួល ហើយថ្លៃដើមហិរញ្ញប្បទានតម្រូវឱ្យមានការគ្រប់គ្រងប្រកបដោយការប្រុងប្រយ័ត្នក៏ដោយ។ យើងខ្ញុំនឹងបន្តការពង្រីកខ្លួនប្រកបដោយវិន័យ ពង្រឹងការគ្រប់គ្រងហានិភ័យ និងការបញ្ជ្រាបបរិស្ថាន សង្គម និងអភិបាលកិច្ច (ESG) ឱ្យកាន់តែស៊ីជម្រៅ ព្រមទាំងជំរុញនវានុវត្តន៍ឌីជីថល ដើម្បីបម្រើអតិថិជនឱ្យកាន់តែប្រសើរឡើង។

សមិទ្ធផលជាផលប័ត្រឥណទាន ១០០ លានដុល្លារ មិនមែនជាទីបញ្ចប់នោះទេ ប៉ុន្តែវាគឺជាមូលដ្ឋានគ្រឹះសម្រាប់ផលប៉ះពាល់ដែលនឹងរីកចម្រើនកាន់តែធំធេងជាងនេះ។ នៅពេលយើងខ្ញុំឆ្ពោះទៅកាន់ឆ្នាំ ២០២៦ បេសកកម្មរបស់យើងខ្ញុំនៅតែច្បាស់លាស់៖ គឺការកសាងស្ថិរភាពសេដ្ឋកិច្ចនៃគ្រួសារកម្ពុជាដែលមានចំណូលទាបតាមរយៈការពង្រីកលទ្ធភាពទទួលបានកម្មសិទ្ធិលើលំនៅដ្ឋានដែលមានសុវត្ថិភាព និងតម្លៃសមរម្យ។

ក្នុងនាមគណៈគ្រប់គ្រង ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះក្រុមប្រឹក្សាភិបាលសម្រាប់ការណែនាំជាយុទ្ធសាស្ត្រ ចំពោះបុគ្គលិកទាំងអស់សម្រាប់ការពុះពារ និងប្រកបការងារដោវិជ្ជាជីវៈ ចំពោះដៃគូផ្តល់ហិរញ្ញប្បទានសម្រាប់ទំនុកចិត្តជាបន្តបន្ទាប់ និងចំពោះនិយ័តករទាំងអស់ សម្រាប់ការគ្រប់គ្រង និងផ្តល់ការណែនាំ។ លើសពីនេះ ខ្ញុំសូមអរគុណដល់អតិថិជនសម្រាប់ទំនុកចិត្តដែលបានផ្តល់ជូន ហ្វឺស ហ្វាយណាន់ ជារៀងរាល់ថ្ងៃ។

យើងរួមគ្នា កសាងលើសពីផ្ទះសម្បែង គឺយើងកំពុងកសាងគ្រួសារឱ្យកាន់តែរឹងមាំ សហគមន៍ដែលមានភាពធន់ និងអនាគតដែលពោរពេញដោយបរិយាបន្នសម្រាប់កម្ពុជា។

សូមទទួលការគោរពរាប់អានអំពីខ្ញុំបាទ




**លោក ស៊ឹម សេនាជាតិ**
ប្រធាននាយកប្រតិបត្តិ





# កូនសោរឆ្ពោះទៅរកការរស់នៅប្រកបដោយសុខមាលភាព

ក្នុងនាមជាស្ត្រីមេមាយដ៏រឹងមាំម្នាក់ អ្នកស្រី ឡៅ ផល្លា បានខិតខំប្រឹងប្រែងយ៉ាងខ្លាំងក្នុងការទូលរែកបន្ទុកគ្រួសារ និងចិញ្ចឹមបីបាច់កូនៗទាំង ៤នាក់តែម្នាក់ឯង។ អ្នកស្រីប្រកបរបរតាមជំនាញប្រពៃណី គឺការត្បាញហូល និងចិញ្ចឹមគោមួយចំនួន ដើម្បីរកចំណូលផ្គត់ផ្គង់ជីវភាពគ្រួសារ ដោយកូនៗមានការងារប្រចាំថ្ងៃធ្វើការនៅរោងចក្រ ។

ទោះបីជាគ្រួសារអ្នកស្រីមានចំណូលសរុបគួរសមដែលអាចដោះស្រាយជីវភាពបានក្តី ប៉ុន្តែក្តីកង្វល់ដ៏ធំបំផុតរបស់អ្នកស្រីគឺ "ទីជម្រកសមរម្យ" សម្រាប់កូនៗរបស់គាត់។ ពីមុន គ្រួសារដែលមានសមាជិក ៥នាក់មួយនេះ ត្រូវរស់នៅយ៉ាងចង្អៀតណែនក្នុងផ្ទះឈើចាស់តូចមួយ។ ទំហំផ្ទះដ៏តូចចង្អៀតនេះ បានបង្កការលំបាកយ៉ាងខ្លាំងដល់ការរស់នៅប្រចាំថ្ងៃ ទាំងការសម្រាក និងជាពិសេសទីធ្លាសម្រាប់ដាក់កីតម្បាញហូលរបស់អ្នកស្រី។

ដោយក្តីស្រមៃចង់ឃើញកូនៗ មានផ្ទះរស់នៅដ៏សមរម្យ និងមានសុវត្ថិភាព អ្នកស្រី ផល្លា បានរៀបចំផែនការហិរញ្ញវត្ថុគ្រួសារយ៉ាងច្បាស់លាស់ និងសម្រេចចិត្តស្វែងរកដំណោះស្រាយតាមរយៈការប្រើប្រាស់សេវាកម្មកម្ចីសាងសង់ផ្ទះពី ហ្វឺស ហ្វាយនែន តាមរយៈការចុះផ្សព្វផ្សាយផ្ទាល់របស់បុគ្គលិក។

តាមរយៈប្រវត្តិហិរញ្ញវត្ថុល្អ និងប្រភពចំណូលច្បាស់លាស់ អ្នកស្រីទទួលបានប្រាក់កម្ចីសម្រាប់យកមកសាងសង់ផ្ទះថ្មី មួយខ្នង។ មិនត្រឹមតែប៉ុណ្ណោះ បន្ទាប់ពីការសាងសង់តួផ្ទះបានរួចរាល់ ដោយមើលឃើញពីតម្រូវការចាំបាច់ក្នុងការការពារសុវត្ថិភាពគ្រួសារ អ្នកស្រីក៏បានសម្រេចចិត្តស្នើសុំយកកម្ចីបន្ថែមមួយកម្រិតទៀត ដើម្បីសាងសង់របងព័ទ្ធជុំវិញផ្ទះឱ្យបានរឹងមាំ។

សាច់រឿងរបស់អ្នកស្រី ឡៅ ផល្លា គឺជាសក្ខីភាពមួយបង្ហាញពីការខិតខំប្រឹងប្រែង ការរៀបចំផែនការហិរញ្ញវត្ថុបានត្រឹមត្រូវ និងការប្រើប្រាស់ឥណទានចំគោលដៅ ដើម្បីកសាងអនាគតដ៏រឹងមាំសម្រាប់គ្រួសារ ។



# បរិយាកាស អាជីវកម្មរបស់ យើងខ្ញុំ

# តំបន់ប្រតិបត្តិការ




**២០**
ការិយាល័យ
↑ កើនពី ១៩ ឆ្នាំ ២០២៤

**៤៩៧**
បុគ្គលិកសរុប
↑ កើនពី ៣៧២ ឆ្នាំ ២០២៤



# ផលិតផល និងដំណោះស្រាយ

**កម្ចីទិញផ្ទះ និងសាងសង់ផ្ទះ**
ជាប្រភេទកម្ចីរយៈពេលវែង ប្រើប្រាស់ដើម្បីយកទៅទិញ ផ្ទះ ឬសាងសង់ផ្ទះនៅលើដីដែលមានស្រាប់
**១៥%** នៃផលប័ត្រឥណទានសរុប
**១.៨០១** អតិថិជន

**កម្ចីកែលម្អផ្ទះ**
ជាប្រភេទកម្ចីរយៈពេលវែង ប្រើប្រាស់ដើម្បីយកទៅ កែលម្អ និងជួសជុលផ្ទះ
**៦៤%** នៃផលប័ត្រឥណទានសរុប
**៧.៥៥៧** អតិថិជន

**កម្ចីទិញដីលំនៅឋាន**
ជាប្រភេទកម្ចីរយៈពេលវែង ប្រើប្រាស់ដើម្បីយកទៅទិញដីលំនៅឋាន ដើម្បីទុកសាងសង់ផ្ទះ
**៨%** នៃផលប័ត្រឥណទានសរុប
**៩៩១** អតិថិជន

**កម្ចីបង្កើនទ្រព្យ**
ជាប្រភេទកម្ចីរយៈពេលមធ្យម ដែលប្រើប្រាស់អចលនទ្រព្យបញ្ចាំ ដើម្បីយកធ្វើជា ដើមទុនបង្កើត ឬពង្រីក អាជីវកម្ម
**៩%** នៃផលប័ត្រឥណទានសរុប
**១.២០៩** អតិថិជន

**កម្ចីអចលនទ្រព្យធានា**
ជាប្រភេទកម្ចីរយៈពេលមធ្យម ដែលប្រើប្រាស់អចលនទ្រព្យបញ្ចាំ ដើម្បីទិញរបស់ប្រើប្រាស់ក្នុងផ្ទះ ឬសម្ភារប្រើប្រាស់ក្នុងផ្ទាល់ខ្លួន
**៥%** នៃផលប័ត្រឥណទានសរុប
**៥៣៣** អតិថិជន



# នាមស្ថាប័នផ្តល់ហិរញ្ញប្បទាន



# រចនាសម្ព័ន្ធ ហ្វីស ហ្វាយនែន



# គុណវុឌ្ឍិ បទពិសោធន៍ និងភារកិច្ច ពិសេសរបស់សមាជិកក្រុមប្រឹក្សាភិបាល

គិតត្រឹមថ្ងៃចេញរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលរួមមានសមាជិកឯករាជ្យពីររូប សមាជិកមិនមែននាយកប្រតិបត្តិមួយរូប និងសមាជិកជានាយកប្រតិបត្តិចំនួនពីររូប រួមមាន អនុប្រធាននាយកប្រតិបត្តិ និងប្រធាននាយកប្រតិបត្តិ។

- គណៈកម្មការគ្រប់គ្រងហានិភ័យ
- គណៈកម្មការតែងតាំង និងវាយតម្លៃ
- គណៈកម្មការសវនកម្ម



## លោក ស៊ូ វណ្ណថន

អភិបាលឯករាជ្យ

**ប្រធាន**: គណៈកម្មការតែងតាំង និងវាយតម្លៃ, គណៈកម្មការសវនកម្ម

**សមាជិក**: គណៈកម្មការគ្រប់គ្រងហានិភ័យ

**គុណវុឌ្ឍិ**
បរិញ្ញាបត្រជាន់ខ្ពស់ផ្នែករដ្ឋបាលសាធារណៈ និងបញ្ចប់ការសិក្សាផ្នែកធនាគារ

**ទំនួលខុសត្រូវ**
អភិបាល

**អាជីពការងារ**
លោក វណ្ណថន ត្រូវបានទទួលស្គាល់ដោយស្ថាប័ន CGAP & EDA Rural Systems Pty Ltd ជាគ្រូបង្គោលលើការបណ្តុះបណ្តាលផ្នែកគោលការណ៍គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងផ្នែកគ្រប់គ្រងការដោះស្រាយបំណុល ។ ចាប់តាំងពីឆ្នាំ ១៩៨២ មក លោកបានចូលរួមវគ្គសិក្សាជាច្រើន ដែលពាក់ពន្ធ័ការគ្រប់គ្រងប្រតិបត្តិការធនាគារ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងការគ្រប់គ្រងធនធានមនុស្ស ។ លោកមានបទពិសោធន៍ច្រើនជាង ៣០ឆ្នាំ ក្នុងតួនាទីជាច្រើនជាមួយប្រាសាក់ ធនាគារជាតិ ក៏ដូចជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ក្នុងនោះមានដូចជាមន្ត្រីឥណទាន អ្នកសម្របសម្រួលឥណទានថ្នាក់ខេត្ត អនុប្រធានផ្នែកឥណទាន ប្រធានសាខា ប្រធានតំបន់ និងប្រធានភូមិភាគ ។ លោកបានបម្រើការនៅប្រាសាក់ម្តងទៀត ជាប្រធានផ្នែកធនធានមនុស្សក្នុងឆ្នាំ ២០០៩។ លោកត្រូវបានដំឡើងតំណែងជានាយកប្រតិបត្តិ គ្រប់គ្រងធនធានមនុស្សក្នុងឆ្នាំ ២០១០ ហើយបានចូលនិវត្តន៍ក្នុងឆ្នាំ ២០១៧។ បច្ចុប្បន្ន លោកកាន់តួនាទីជាអភិបាលឯករាជ្យរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ហ្វីស ហ្វាយនែន ភីអិលស៊ី។



## Hanco Halbertsma

អភិបាលឯករាជ្យ / ប្រធានក្រុមប្រឹក្សាភិបាល

**ប្រធាន**: គណៈកម្មការគ្រប់គ្រងហានិភ័យ

**សមាជិក**: គណៈកម្មការតែងតាំង និងវាយតម្លៃ, គណៈកម្មការសវនកម្ម

**គុណវុឌ្ឍិ**
អនុបណ្ឌិតផ្នែកគ្រប់គ្រងអាជីវកម្ម

**ទំនួលខុសត្រូវ**
ប្រធានក្រុមប្រឹក្សាភិបាល

**អាជីពការងារ**
លោក Hanco Halbertsma គឺជាទីប្រឹក្សាផ្នែកយុទ្ធសាស្ត្រសម្រាប់ធនាគារ ស្ថាប័នហិរញ្ញវត្ថុ និងស្ថាប័នមីក្រូហិរញ្ញវត្ថុក្នុងប្រទេសកំពុងអភិវឌ្ឍន៍ និងសម្រាប់អ្នកដែលចង់វិនិយោគលើស្ថាប័នហិរញ្ញវត្ថុ ។ ក្នុងរយៈពេលជាង ២៥ឆ្នាំកន្លងទៅនេះ លោកបានធ្វើការក្នុងគម្រោងជាច្រើន ជាអ្នកជំនាញវិស័យហិរញ្ញវត្ថុ ដែលរួមមាន ផ្នែកមីក្រូហិរញ្ញវត្ថុ ផ្នែកធនាគារសម្រាប់អាជីវកម្ម និងបុគ្គល ហិរញ្ញវត្ថុសហគ្រាសខ្នាតតូច ការគ្រប់គ្រងហានិភ័យឥណទាន អភិបាលកិច្ចសាជីវកម្ម និងផ្នែកហិរញ្ញប្បទាន។ ក្នុងតួនាទីជាប្រធានក្រុមប្រឹក្សាភិបាលរបស់ ហ្វីស ហ្វាយ នែន លោក Hanco ផ្តល់ការគាំទ្រផ្នែកយុទ្ធសាស្ត្រ ផ្នែកស្វែងរកមូលនិធិ ផ្នែកគ្រប់គ្រងហានិភ័យឥណទាន ផ្នែកហិរញ្ញវត្ថុ និងផ្នែកកសាងសមត្ថភាពបុគ្គលិក។

មុនពេលចាប់ផ្តើមជាមួយ ហ្វីស ហ្វាយនែន លោកមានបទពិសោធន៍ក្នុងប្រទេសកម្ពុជា ចំនួន ៦ឆ្នាំមកហើយក្នុងនាមជាអភិបាល នៃគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រាសាក់ ដែលជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុធំជាងគេក្នុងប្រទេសកម្ពុជា។ លោកក៏ធ្លាប់ដើរតួនាទីជាអភិបាល របស់ក្រុមហ៊ុនមួយចំនួននៅក្នុងទីក្រុងហុងកុង ឥណ្ឌា និងស្រីលង្ការ។

លោក Hanco គឺជាស្ថាបនិកក្រុមហ៊ុន Priority Project Limited (PPL) ដែលជាក្រុមហ៊ុនជំនាញក្នុងការប្រឹក្សាយោបល់ផ្នែកយុទ្ធសាស្ត្រ និង ផ្នែកប្រតិបត្តិការសម្រាប់ស្ថាប័នហិរញ្ញវត្ថុ និងវិនិយោគិនក្នុងតំបន់អាស៊ី។ក្រុមហ៊ុននេះត្រូវបានបង្កើតឡើង បន្ទាប់ពីលោកបានធ្វើការក្នុងក្រុមហ៊ុន ING Group អស់រយៈពេល១៦ឆ្នាំ ដែលក្នុងនោះរយៈពេល៨ឆ្នាំ គឺលោកបានធ្វើក្នុងក្រុមហ៊ុន ING-IGA ដែលជាក្រុមហ៊ុនពិគ្រោះយោបល់ក្នុងបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ ។



## លោក អ៊ុំ សូផន

អភិបាល

**សមាជិក**: គណៈកម្មការតែងតាំង និងវាយតម្លៃ, គណៈកម្មការសវនកម្ម, គណៈកម្មការគ្រប់គ្រងហានិភ័យ

**គុណវុឌ្ឍិ**
បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអាជីវកម្ម និងថ្នាក់បរិញ្ញាបត្រសេដ្ឋកិច្ច ជំនាញធនាគារ និងហិរញ្ញវត្ថុ

**ទំនួលខុសត្រូវ**
អភិបាល

**អាជីពការងារ**
មុនពេលបម្រើការងារនៅប្រាសាក់ លោក សូផន មានបទពិសោធន៍ជាច្រើនឆ្នាំ ក្នុងការគ្រប់គ្រងគណនេយ្យ គ្រប់គ្រងហិរញ្ញវត្ថុ និងធនាគារ និងធ្លាប់បម្រើការងារក្នុងឋានៈជា នាយកប្រតិបត្តិគ្រប់គ្រងហិរញ្ញវត្ថុ នៅគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ធនាគារពាណិជ្ជ ធនាគារជាតិនៃកម្ពុជា និងក្រុមហ៊ុនឯកជននានា។ លោកបានចូលបម្រើការងារនៅប្រាសាក់ ក្នុងតួនាទីជាអគ្គនាយករងទទួលបន្ទុកហិរញ្ញវត្ថុ នៅក្នុងឆ្នាំ ២០០៧ រហូតមកដល់ដើមឆ្នាំ ២០២២។ បច្ចុប្បន្នលោកមានតួនាទីជាអភិបាលគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ហ្វីស ហ្វាយនែន ភីអិលស៊ី។



## លោក ស៊ឹម សេនាជាតិ

អភិបាល និងប្រធាននាយកប្រតិបត្តិ

**សមាជិក**

**គុណវុឌ្ឍិ**

បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអាជីវកម្ម និង បញ្ចប់ការសិក្សាផ្នែកគណនេយ្យ និងហិរញ្ញវត្ថុ

**ទំនួលខុសត្រូវ**

អភិបាល និងប្រធាននាយកប្រតិបត្តិ

**អាជីពការងារ**

ចាប់តាំងពីឆ្នាំ ១៩៩៥ មក លោក សេនាជាតិ បាន ចូលរួមវគ្គបណ្តុះបណ្តាលជាច្រើន ពាក់ពន្ធ័ការ គ្រប់គ្រង និងប្រតិបត្តិការមីក្រូហិរញ្ញវត្ថុ ។ លោក ក៏ត្រូវបានទទួលស្គាល់ជាគ្រូបង្គោលមីក្រូហិរញ្ញវត្ថុ ដោយ ADBI និង TDLC របស់ធានាគារពិភព លោក និង UNCDF ។

លោកធ្លាប់បានធ្វើការងារជាច្រើន ក្នុងវិស័យ ធនាគារ និងបានចាប់ផ្តើមបំពេញការងារជាមួយ ប្រាសាក់ចាប់តាំងពីឆ្នាំ ១៩៩៥ ក្នុងតួនាទីជាម ន្ត្រីឥណទាន និងត្រូវបានដំឡើងឋានៈ ក្នុងមុខ តំណែងផ្សេងៗជាច្រើន ដូចជា គណនេយ្យករ នាយកសាខា គ្រូបង្គោលផ្នែកកម្មវិធី MB អ្នក ត្រួតពិនិត្យ និងនាយកហិរញ្ញវត្ថុ ។ ចាប់ពីពាក់ កណ្តាលឆ្នាំ ២០០២ មកលោកបម្រើការងារ ក្នុងតួនាទីជានាយកសាខា នាយកប្រតិបត្តិការ និងជាអនុប្រធាន នាយកប្រតិបត្តិនៅ គ្រឹះស្ថាន មួយផ្សេងទៀត មុននឹងចូលមកបម្រើការងារ ជា ប្រធាននាយកប្រតិបត្តិ គ្រឹះស្ថាន មីក្រូហិរញ្ញវត្ថុ ប្រាសាក់នៅចុងឆ្នាំ ២០០៣ រហូតមកដល់ ដើមឆ្នាំ ២០២២។ បច្ចុប្បន្នលោកមានតួនាទីជា អភិបាល និងជាប្រធាននាយកប្រតិបត្តិគ្រឹះស្ថាន មីក្រូហិរញ្ញវត្ថុ ហ្វឹស ហ្វាយនែន ភីអិលស៊ី។



## លោក ជា ហាង

អភិបាល និងអនុប្រធាននាយកប្រតិបត្តិ

**សមាជិក**

**គុណវុឌ្ឍិ**

បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអាជីវកម្ម និង បញ្ចប់ថ្នាក់បរិញ្ញាបត្រគណនេយ្យ និងហិរញ្ញវត្ថុ

**ទំនួលខុសត្រូវ**

អភិបាល និងអនុប្រធាននាយកប្រតិបត្តិ

**អាជីពការងារ**

លោក ជា ហាង មានបទពិសោធន៍ជាច្រើនខាង ផ្នែកហិរញ្ញវត្ថុ គណនេយ្យ លទ្ធកម្ម ការគ្រប់គ្រង ធនធានមនុស្ស ឥណទាន សេវាធនាគារ គោល-នយោបាយអង្គភាព ច្បាប់ អភិបាលកិច្ចអាជីវកម្ម យុទ្ធសាស្ត្រអាជីវកម្ម ផែនការអាជីវកម្ម និង ការគ្រប់គ្រងគម្រោង។ លោកធ្លាប់បានបម្រើ ការងារក្នុងតួនាទីជាច្រើន ដូចជា ប្រធានផ្នែក ហិរញ្ញវត្ថុ និងរដ្ឋបាល អ្នកប្រឹក្សាជាន់ខ្ពស់ផ្នែក លទ្ធកម្មហិរញ្ញវត្ថុ និងរដ្ឋបាល ប្រធានក្រុមប្រឹក្សា ភិបាលរបស់គ្រឹះស្ថាន មីក្រូហិរញ្ញវត្ថុប្រាសាក់ នាយកប្រតិបត្តិ និងប្រធាននាយកដ្ឋានជាន់ខ្ពស់ ផ្នែកយុទ្ធសាស្ត្រ និងផែនការអាជីវកម្ម ហើយ លោកត្រូវបានដំឡើងតំណែង ជាប្រធាននាយក ប្រតិបត្តិទទួលបន្ទុកផ្នែកយុទ្ធសាស្ត្រ និងផែនការ អាជីវកម្ម។ លោកក៏ជាប្រធានក្រុមប្រឹក្សាភិបាល របស់ក្រុមហ៊ុនបុគ្គលិកប្រាសាក់ (PSCo) និង ជាប្រធានក្រុមប្រឹក្សាភិបាលរបស់បរធនបាលកិច្ច ហិរញ្ញវត្ថុប្រាសាក់។ បច្ចុប្បន្នលោកកាន់តួនាទីជា អនុប្រធាននាយកប្រតិបត្តិ និងជាអភិបាលរបស់ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ហ្វឹស ហ្វាយនែន ភីអិលស៊ី។







# គុណវុឌ្ឍិ បទពិសោធន៍ និងភារកិច្ច ពិសេសរបស់សមាជិកនាយក ប្រតិបត្តិ

**ពីឆ្វេងទៅស្តាំ៖** លោក ជួប វាសនា លោក ជា ហាង លោក ស៊ឹម សេនាជាតិ លោក សាយ សូនី លោក នាង សុខឃីម លោក យ៉ាង គឹមស្រេង



ទិដ្ឋភាពទូទៅ
សារទៅកាន់ភាគីពាក់ព័ន្ធ
បរិយាកាសអាជីវកម្ម
ការប្តេជ្ញារបស់យើងចំពោះនិរន្តរភាព
ការគ្រប់គ្រងហានិភ័យ
របាយការណ៍ហិរញ្ញវត្ថុ



## លោក ស៊ឹម សេនាជាតិ

អភិបាល និងប្រធាននាយកប្រតិបត្តិ

**គុណវុឌ្ឍិ**

បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអាជីវកម្ម និង បញ្ចប់ការសិក្សាផ្នែកគណនេយ្យ និងហិរញ្ញវត្ថុ

**ទំនួលខុសត្រូវ**

អភិបាល និងប្រធាននាយកប្រតិបត្តិ

**អាជីពការងារ**

ចាប់តាំងពីឆ្នាំ ១៩៩៥ មក លោក សេនាជាតិ បាន ចូលរួមវគ្គបណ្តុះបណ្តាលជាច្រើន ពាក់ពន្ធ័ការ គ្រប់គ្រង និងប្រតិបត្តិការមីក្រូហិរញ្ញវត្ថុ ។ លោក ក៏ត្រូវបានទទួលស្គាល់ជាគ្រូបង្គោលមីក្រូហិរញ្ញវត្ថុ ដោយ ADBI និង TDLC របស់ធានាគារពិភព លោក និង UNCDF ។

លោកធ្លាប់បានធ្វើការងារជាច្រើន ក្នុងវិស័យ ធនាគារ និងបានចាប់ផ្តើមបំពេញការងារជាមួយ ប្រាសាក់ចាប់តាំងពីឆ្នាំ ១៩៩៥ ក្នុងតួនាទីជាម ន្ត្រីឥណទាន និងត្រូវបានដំឡើងឋានៈ ក្នុងមុខ តំណែងផ្សេងៗជាច្រើន ដូចជា គណនេយ្យករ នាយកសាខា គ្រូបង្គោលផ្នែកកម្មវិធី MB អ្នក ត្រួតពិនិត្យ និងនាយកហិរញ្ញវត្ថុ ។ ចាប់ពីពាក់ កណ្តាលឆ្នាំ ២០០២ មកលោកបម្រើការងារ ក្នុងតួនាទីជានាយកសាខា នាយកប្រតិបត្តិការ និងជាអនុប្រធាន នាយកប្រតិបត្តិនៅ គ្រឹះស្ថាន មួយផ្សេងទៀត មុននឹងចូលមកបម្រើការងារ ជា ប្រធាននាយកប្រតិបត្តិគ្រឹះស្ថាន មីក្រូហិរញ្ញវត្ថុ ប្រាសាក់នៅចុងឆ្នាំ ២០០៣ រហូតមកដល់ ដើមឆ្នាំ ២០២២។ បច្ចុប្បន្នលោកមានតួនាទីជា អភិបាល និងជាប្រធាននាយកប្រតិបត្តិគ្រឹះស្ថាន មីក្រូហិរញ្ញវត្ថុ ហ្វីស ហ្វាយនែន ភីអិលស៊ី។



## លោក ជា ហាង

អភិបាល និងអនុប្រធាននាយកប្រតិបត្តិ

**គុណវុឌ្ឍិ**

បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអាជីវកម្ម និង បញ្ចប់ថ្នាក់បរិញ្ញាបត្រគណនេយ្យ និងហិរញ្ញវត្ថុ

**ទំនួលខុសត្រូវ**

អភិបាល និងអនុប្រធាននាយកប្រតិបត្តិ

**អាជីពការងារ**

លោក ជា ហាង មានបទពិសោធន៍ជាច្រើនខាង ផ្នែកហិរញ្ញវត្ថុ គណនេយ្យ លទ្ធកម្ម ការគ្រប់គ្រង ធនធានមនុស្ស ឥណទាន សេវាធនាគារ គោល-នយោបាយអង្គភាព ច្បាប់ អភិបាលកិច្ចអាជីវកម្ម យុទ្ធសាស្ត្រអាជីវកម្ម ផែនការអាជីវកម្ម និង ការគ្រប់គ្រងគម្រោង។ លោកធ្លាប់បានបម្រើ ការងារក្នុងតួនាទីជាច្រើន ដូចជា ប្រធានផ្នែក ហិរញ្ញវត្ថុ និងរដ្ឋបាល អ្នកប្រឹក្សាជាន់ខ្ពស់ផ្នែក លទ្ធកម្មហិរញ្ញវត្ថុ និងរដ្ឋបាល ប្រធានក្រុមប្រឹក្សា ភិបាលរបស់គ្រឹះស្ថាន មីក្រូហិរញ្ញវត្ថុប្រាសាក់ នាយកប្រតិបត្តិ និងប្រធាននាយកដ្ឋានជាន់ខ្ពស់ ផ្នែកយុទ្ធសាស្ត្រ និងផែនការអាជីវកម្ម ហើយ លោកត្រូវបានដំឡើងតំណែង ជាប្រធាននាយក ប្រតិបត្តិទទួលបន្ទុកផ្នែកយុទ្ធសាស្ត្រ និងផែនការ អាជីវកម្ម។ លោកក៏ជាប្រធានក្រុមប្រឹក្សាភិបាល របស់ក្រុមហ៊ុនបុគ្គលិកប្រាសាក់ (PSCo) និង ជាប្រធានក្រុមប្រឹក្សាភិបាលរបស់បរធនបាលកិច្ច ហិរញ្ញវត្ថុប្រាសាក់។ បច្ចុប្បន្នលោកកាន់តួនាទីជា អនុប្រធាននាយកប្រតិបត្តិ និងជាអភិបាលរបស់ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ហ្វីស ហ្វាយនែន ភីអិលស៊ី។



## លោក នាង សុខឃីម

នាយកប្រតិបត្តិគ្រប់គ្រងហានិភ័យ

**គុណវុឌ្ឍិ**
ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រង និង
បរិញ្ញាបត្រវិទ្យាសាស្ត្រក្សេត្រសាស្ត្រ

**ទំនួលខុសត្រូវ**
នាយកប្រតិបត្តិគ្រប់គ្រងហានិភ័យ

**អាជីពការងារ**
លោក នាង សុខឃីម គឺជាគ្រូបង្គោល ផ្នែកមីក្រូហិរញ្ញវត្ថុ ដែលទទួលស្គាល់ដោយ ADBI, TLDC របស់ធនាគារពិភពលោក និង UNCDF។ លោកបានបញ្ចប់ថ្នាក់បរិញ្ញាបត្រវិទ្យាសាស្ត្រ ក្សេត្រសាស្ត្រនៅឆ្នាំ ១៩៩៧ ។ លោកបានចូលរួមវគ្គបណ្តុះបណ្តាលជាច្រើន ទាក់ទងនឹងប្រតិបត្តិការមីក្រូហិរញ្ញញវត្ថុ និងវគ្គបណ្តុះបណ្តាលផ្សេងៗទៀតផងដែរ។

លោកមានបទពិសោធន៍ច្រើនជាង ២០ឆ្នាំ ក្នុងវិស័យមីក្រូហិរញ្ញវត្ថុ ដោយចាប់ផ្តើមពីតួនាទីជាមន្ត្រីឥណទាន ក្នុងឆ្នាំ ១៩៩៨ ហើយត្រូវបានដំឡើងតួនាទីជាបន្តបន្ទាប់ ជាសវនករផ្ទៃក្នុង សវនករផ្ទៃក្នុងជាន់ខ្ពស់ នាយករងប្រតិបត្តិការ នាយករងឥណទាន និងជានាយកឥណទាន ។ លោកត្រូវបានដំឡើងតួនាទី ជានាយកប្រតិបត្តិទទួលបន្ទុកអាជីវកម្មចាប់តាំងពីឆ្នាំ ២០១០ រហូតមកដល់ដើមឆ្នាំ ២០២២។ បច្ចុប្បន្ននេះ លោកមានតួនាទីជានាយកប្រត្តិបត្តិគ្រប់គ្រង ហានិភ័យនៃគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ហ្វឹស ហ្វាយនែន ភីអិលស៊ី។



## លោក យ៉ាង គឹមស្រេង

នាយកប្រតិបត្តិគ្រប់គ្រងហិរញ្ញវត្ថុ

**គុណវុឌ្ឍិ**
បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអាជីវកម្ម
ឯកទេសធនាគារ និងហិរញ្ញវត្ថុ និងបរិញ្ញាបត្រ
គណនេយ្យ និងប្រកាសនីយបត្រជាន់ខ្ពស់
បច្ចេកទេសធនាគារ

**ទំនួលខុសត្រូវ**
នាយកប្រតិបត្តិគ្រប់គ្រងហិរញ្ញវត្ថុ

**អាជីពការងារ**
លោក គឹមស្រេង មានបទពិសោធន៍ ច្រើនឆ្នាំ ក្នុងផ្នែកហិរញ្ញវត្ថុ គណនេយ្យ ហិរញ្ញកិច្ច លទ្ធកម្ម និងសេវាកម្មធនាគារ។ លោកបានចូលរួមក្នុងវគ្គបណ្តុះបណ្តាលជាច្រើន ដែលទាក់ទងនឹងវិស័យមីក្រូហិរញ្ញវត្ថុទាំងនៅក្នុងស្រុក និងអន្តរជាតិ ទាំងតំបន់អាស៊ី និងអឺរ៉ុប។

លោកមានបទពិសោធន៍ច្រើនជាង ២៨ឆ្នាំ នៅក្នុងវិស័យ ធនាគារ និងមីក្រូហិរញ្ញវត្ថុ ។ លោកបានចំណាយពេលជាង ១៦ឆ្នាំ ក្នុងតួនាទីជាមន្ត្រីជាន់ខ្ពស់ ។ លោកចាប់ផ្តើមពីតួនាទីជាគណនេយ្យករនៅប្រាសាក់ ក្នុងឆ្នាំ ១៩៩៨ ហើយត្រូវបានដំឡើងតំណែងជាបន្តបន្ទាប់ ពីប្រធានគណនេយ្យ ប្រធានផ្នែកគាំទ្រមីក្រូប៉ែងឃឺ អនុ-ប្រធាននាយកដ្ឋានហិរញ្ញវត្ថុ នាយកនាយកដ្ឋានហិរញ្ញវត្ថុ ។ លោកត្រូវបានដំឡើងតួនាទី ជានាយកជាន់ខ្ពស់នាយកដ្ឋានហិរញ្ញវត្ថុ ចាប់ពីឆ្នាំ ២០១៧ ដល់ដើមឆ្នាំ ២០២២ ។ បច្ចុប្បន្នលោកកាន់តួនាទីជានាយកប្រតិបត្តិគ្រប់គ្រងហិរញ្ញវត្ថុ នៃគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ហ្វឹស ហ្វាយនែន ភីអិលស៊ី។





## លោក សាយ សូនី

នាយកប្រតិបត្តិគ្រប់គ្រងទីផ្សារ

**គុណវុឌ្ឍិ**
បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអាជីវកម្ម និង បរិញ្ញាបត្រសេដ្ឋកិច្ច ឯកទេសហិរញ្ញវត្ថុ និង ធនាគារ

**ទំនួលខុសត្រូវ**
នាយកប្រតិបត្តិគ្រប់គ្រងទីផ្សារ និងជាប្រធានគណៈកម្មការគ្រប់គ្រងកិច្ចការនិរន្តភាព

**អាជីពការងារ**
លោក សូនី មានបទពិសោធន៍ជាង ២០ឆ្នាំ លើការគ្រប់គ្រងគម្រោង ការគ្រប់គ្រងទីផ្សារ ការអភិវឌ្ឍផលិតផល និងការគ្រប់គ្រងទាំងក្នុងវិស័យឯកជន ការងារសង្គម និងមីក្រូហិរញ្ញវត្ថុ ។ លោកបានចូលរួមបម្រើការងារនៅប្រាសាក់ក្នុងដើមឆ្នាំ ២០០៥ ក្នុងតួនាទីជាប្រធានផ្នែកទីផ្សារ និងត្រូវបានដំឡើងតួនាទីជានាយកគ្រប់គ្រងទីផ្សារ ក្នុងឆ្នាំ ២០០៧ ។ លោកត្រូវបានដំឡើងតួនាទីជានាយកប្រតិបត្តិទទួលបន្ទុកទីផ្សារ ចាប់ពីឆ្នាំ ២០១០ រហូតមកដល់ដើមឆ្នាំ ២០២២ ។ បច្ចុប្បន្នលោកកាន់តួនាទីជានាយកប្រតិបត្តិគ្រប់គ្រងទីផ្សារ នៃគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ហ្វឹស ហ្វាយនែន ភីអិលស៊ី។



## លោក ជួប វាសនា

នាយកប្រតិបត្តិគ្រប់គ្រងប្រតិបត្តិការ

**គុណវុឌ្ឍិ**
ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអាជីវកម្ម និង ថ្នាក់បរិញ្ញាបត្រគ្រប់គ្រងទីផ្សារ

**ទំនួលខុសត្រូវ**
នាយកប្រតិបត្តិគ្រប់គ្រងប្រតិបត្តិការ

**អាជីពការងារ**
លោក វាសនា មានបទពិសោធន៍ជាង ២០ ឆ្នាំ ក្នុងវិស័យធនាគារ និងមីក្រូហិរញ្ញវត្ថុ។ លោកបានចូលរួមបម្រើការងារនៅប្រាសាក់ក្នុងឆ្នាំ ២០០២ ក្នុងតួនាទីជាមន្ត្រីឥណទាន។ ជាបន្តបន្ទាប់ លោកត្រូវបានដំឡើងតួនាទី ជានាយកអនុសាខា នាយកសាខា និងជាប្រធានផ្នែកឥណទាន។ ក្នុងឆ្នាំ ២០១០ លោកត្រូវបានដំឡើងតួនាទីជានាយកនាយកដ្ឋានគ្រប់គ្រង និងអភិវឌ្ឍផលិតផល។ លោកត្រូវបានដំឡើងតួនាទី ជាអនុប្រធាននាយកប្រតិបត្តិទទួលបន្ទុកធនធានមនុស្ស ចាប់ពីឆ្នាំ ២០២០ រហូតមកទល់ដើមឆ្នាំ ២០២២ ។ បច្ចុប្បន្នលោកកាន់តួនាទី ជានាយកប្រតិបត្តិគ្រប់គ្រងប្រតិ-បត្តិការនៃគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ហ្វឹស ហ្វាយនែន ភីអិលស៊ី។



# លើកកម្ពស់ បរិយាបន្នហិរញ្ញវត្ថុ និងសេដ្ឋកិច្ចរុងរឿង សម្រាប់គ្រប់គ្នា



## ការជំរុញការកសាងទ្រព្យសម្បត្តិ និងសុខុមាលភាពសហគមន៍

គ្រួសារកម្ពុជាដែលមានចំណូលទាប និងមធ្យមជាច្រើន កំពុងប្រឈមមុខនឹងបញ្ហាកង្វះខាតលំនៅឋាន និងការទទួលបានសេវាមូលដ្ឋាននៅមានកម្រិត។ ផ្ទះប្រមាណ ២ លានខ្នង[១] ត្រូវការការកែលម្អដើម្បីឱ្យស្របតាមស្តង់ដារអប្បបរមា ខណៈដែលផ្ទះប្រមាណ ០,១៧ លានខ្នង[២] នៅតំបន់ទីប្រជុំជន ស្ថិតក្នុងស្ថានភាពបណ្តោះអាសន្ន/ប្រក់ស្លឹក ឬមានលក្ខណៈចង្អៀត។ ឥណទានលំនៅឋានដែលមានតម្លៃសមរម្យ បានជួយបំពេញចន្លោះប្រហោងនេះ ដោយអនុញ្ញាតឱ្យគ្រួសារទាំងនោះអាចទិញ ឬសាងសង់ផ្ទះដែលមានសុវត្ថិភាព និងជាប់លាប់។

ក្រៅពីការផ្តល់ជម្រក ឥណទានទាំងនេះជួយពង្រឹងស្ថិរភាពហិរញ្ញវត្ថុ បង្កើតទ្រព្យសម្បត្តិរយៈពេលវែង និងលើកកម្ពស់គុណភាពជីវិត រួមទាំងសុខភាព ការអប់រំ និងសុខុមាលភាពសហគមន៍ឱ្យកាន់តែប្រសើរឡើង។ តាមរយៈការពង្រីកលទ្ធភាពទទួលបានលំនៅឋានតម្លៃសមរម្យ ហ្វឹស ហ្វាយនែន បានគាំទ្រដល់កំណើនប្រកបដោយបរិយាប័ន្ន និងសហគមន៍ប្រកបដោយចីរភាពនៅទូទាំងប្រទេសកម្ពុជា។

នៅដើមឆ្នាំ ២០២៥ ការបើកសម្ពោធសាខាថ្មីចំនួន ៦ នៅក្នុងខេត្តតាកែវ ព្រៃវែង ស្វាយរៀង កំពង់ធំ ពោធិ៍សាត់ និងកំពង់ឆ្នាំង បានពង្រីកវិសាលភាពរបស់យើងខ្ញុំទៅដល់គ្រួសារប្រមាណ ៥,៦០០ បន្ថែមទៀត ។ គិតត្រឹមខែធ្នូ ឆ្នាំ ២០២៥ ផលប័ត្រឥណទានរបស់ ហ្វឹស ហ្វាយនែន បានកើនឡើងដល់ ១០០,៤ លានដុល្លារអាមេរិក ដែលឆ្លុះបញ្ចាំងពីការកើនឡើង ១១,៩១% ធៀបនឹងឆ្នាំមុន ខណៈដែលចំនួនអតិថិជនបានកើនឡើង ២៨,១៤% បើធៀបនឹងឆ្នាំ ២០២៤ ដែលមានអតិថិជនសរុបចំនួន ១១,៨៤៧ នាក់។ អតិថិជនរបស់យើងប្រមាណ ៨១% គឺជាស្វ័យនិយោជន៍ អ្នកដែលមានចំណូលគ្មានឯកសារបញ្ជាក់ច្បាស់លាស់ ឬជាកម្មករ។ លើសពីនេះ ៩០,៥% នៃអតិថិជនរស់នៅតំបន់ជនបទ ហើយ ៥១% បានប្រើប្រាស់ឥណទានរបស់ពួកគេ ដើម្បីកែលម្អស្ថានភាពទឹកស្អាត បង្គន់ និងអនាម័យ (WASH)។

បន្ថែមលើការផ្តល់ហិរញ្ញប្បទានសម្រាប់ភាពជាម្ចាស់ផ្ទះ ហ្វឹស ហ្វាយនែន មានគោលបំណងរួមចំណែកដល់ការអភិវឌ្ឍជារួមនៃសហគមន៍មូលដ្ឋាន ដោយផ្តល់ឱកាសដល់គ្រួសារនានាក្នុងការបង្កើតបរិយាកាសរស់នៅដែលមានសុវត្ថិភាព និងមានភាពងាយស្រួលជាងមុន។

> លំនៅឋានប្រកបដោយសុវត្ថិភាព គឺជាគ្រឹះក្នុងការកសាងសហគមន៍ឱ្យរឹងមាំ។ ចាប់ពីការពង្រីកវិសាលភាពទៅកាន់តំបន់ជនបទ រហូតដល់ការលើកកម្ពស់ប្រព័ន្ធទឹកស្អាត បង្គន់ និងអនាម័យ (WASH) យើងមានមោទនភាពក្នុងការផ្តល់លទ្ធភាពជូនដល់គ្រួសារចំនួនប្រមាណ ១២,000 ក្នុងការផ្លាស់ប្តូរពីភាពមិនច្បាស់លាស់នៃជម្រក មកជាការទទួលបាននូវសុខុមាលភាព និងស្ថិរភាពហិរញ្ញវត្ថុរយៈពេលវែង។



**លោក ជួប វិសនា**
នាយកប្រតិបត្តិគ្រប់គ្រងប្រតិបត្តិការ

### ការលើកកម្ពស់សន្តិសុខ ប្រសិទ្ធភាព និងសមត្ថភាពឌីជីថល

នៅក្នុងឆ្នាំ ២០២៥ ហ្វឹស ហ្វាយនែន បានពង្រឹងសមត្ថភាពឌីជីថលរបស់ខ្លួន ដោយផ្តោតសំខាន់លើការគ្រប់គ្រងហានិភ័យ សន្តិសុខទិន្នន័យ និងប្រសិទ្ធភាពប្រតិបត្តិការ។ ក្រុមការងារបច្ចេកវិទ្យាព័ត៌មាន (IT) បានធានានូវដំណើរការប្រព័ន្ធបានរហូតដល់ ៩៩,៩% ដោយគ្មានឧប្បត្តិហេតុធ្ងន់ធ្ងរកើតឡើងឡើយ តាមរយៈការតាមដានសកម្មភាពជាប់ជាប្រចាំ ការស្វែងរកបញ្ហាឱ្យបានទាន់ពេលវេលា និងការថែទាំហេដ្ឋារចនាសម្ព័ន្ធឱ្យបានរឹងមាំ។ ប្រព័ន្ធធនាគារស្នូលត្រូវបានពង្រឹងបន្ថែម ជាមួយនឹងការធ្វើបច្ចុប្បន្នភាពសន្តិសុខលើប្រព័ន្ធប្រតិបត្តិការ Ubuntu និង PostgreSQL ដែលជួយបង្កើនកិច្ចការពារប្រឆាំងនឹងភាពងាយរងគ្រោះ និងការពារទិន្នន័យហិរញ្ញវត្ថុដ៏សំខាន់ៗ។

តាមរយៈការកែលម្អប្រព័ន្ធគ្រប់គ្រងធនធានមនុស្ស (HRM) និងការអនុវត្តការត្រួតពិនិត្យសុខភាពប្រព័ន្ធធនាគារស្នូល ដែលអនុញ្ញាតឱ្យក្រុមការងារហិរញ្ញវត្ថុអាចកំណត់អត្តសញ្ញាណ និងដោះស្រាយភាពមិនស៊ីសង្វាក់គ្នានៃទិន្នន័យបានយ៉ាងរហ័ស បានធ្វើឱ្យដំណើរការផ្ទៃក្នុងមានភាពប្រសើរឡើង។ ការកែលម្អផ្នែកឌីជីថលក៏បានលើកកម្ពស់បទពិសោធន៍នៃការទូទាត់សងប្រាក់របស់អតិថិជនផងដែរ តាមរយៈការដាក់បញ្ចូលប្រព័ន្ធ KHQR របស់ធនាគារដៃគូ ដែលផ្តល់នូវជម្រើសទូទាត់ប្រាក់កាន់តែលឿន និងមានសុវត្ថិភាពជាងមុន។ សរុបរួមមក គំនិតផ្តួចផ្តើមទាំងនេះបានពង្រឹងភាពធន់ សន្តិសុខ និងការត្រៀមខ្លួនជាស្រេចផ្នែកឌីជីថលរបស់ ហ្វឹស ហ្វាយនែន ដើម្បីគាំទ្រដល់កំណើនប្រកបដោយចីរភាព។

---

១. Habitat Cambodia (country profile)
២. Overview of Urban Housing for Low-Income Households in Cambodia-2024



# ការប្តេជ្ញារបស់យើងខ្ញុំចំពោះកិច្ចការនិរន្តរភាព



ទិដ្ឋភាពទូទៅ
សារទៅកាន់ភាគីពាក់ព័ន្ធ
បរិយាកាសអាជីវកម្ម
ការប្តេជ្ញារបស់យើងខ្ញុំចំពោះនិរន្តរភាព
ការគ្រប់គ្រងហានិភ័យ
របាយការណ៍ហិរញ្ញវត្ថុ



# វិធីសាស្ត្ររបស់យើងក្នុង ការរក្សាបាននូវនិរន្តរភាព

នៅហ្វឹស ហ្វាយនែន និរន្តរភាពចាប់ផ្តើមចេញពីមនុស្ស ពោលគឺក្រុមគ្រួសារដែលសមនឹងទទួលបានលំនៅឋានដែលមានសុវត្ថិភាព សន្តិសុខហិរញ្ញវត្ថុ និងសហគមន៍ដែលមានភាពធន់។ ក្នុងនាមជាគ្រឹះស្ថានជំនាញក្នុងការផ្តល់ឥណទានលំនៅឋានតម្លៃសមរម្យនៅកម្ពុជា របៀបវារៈនិរន្តរភាពរបស់យើងត្រូវបានផ្អែកលើផលប៉ះពាល់ជាក់ស្តែង រួមមាន៖ ការលើកកម្ពស់លក្ខខណ្ឌរស់នៅ ការអនុញ្ញាតឱ្យមានការកសាងទ្រព្យសម្បត្តិរយៈពេលវែង និងការជំរុញកំណើនប្រកបដោយបរិយាប័ន្នសម្រាប់គ្រួសារដែលមានចំណូលទាប និងមធ្យម។

យើងប្តេជ្ញាក្នុងការបញ្ចូលបរិស្ថាន សង្គម និងអភិបាលកិច្ច (ESG) ទៅក្នុងយុទ្ធសាស្ត្រ ប្រតិបត្តិការ និងការគ្រប់គ្រងហានិភ័យរបស់យើង។ កិច្ចការនេះរួមបញ្ចូលទាំងការធ្វើឱ្យប្រសើរឡើងជាបន្តបន្ទាប់នូវគោលនយោបាយ ប្រព័ន្ធ និងដំណើរការនានា ដើម្បីឆ្លុះបញ្ចាំងពីហានិភ័យដែលកំពុងកើតមាន ការរំពឹងទុករបស់អ្នកពាក់ព័ន្ធ និងអាទិភាពអភិវឌ្ឍន៍ជាតិ ខណៈពេលដែលស្របតាមឧត្តមានុវត្តន៍អន្តរជាតិ។ ការពង្រឹងការរាយការណ៍អំពី បរិស្ថាន សង្គម និងអភិបាលកិច្ច ធានានូវតម្លាភាព ភាពអាចប្រៀបធៀបបាន និងគណនេយ្យភាពសម្រាប់ដៃគូរបស់យើង រួមទាំងស្ថាប័នហិរញ្ញវត្ថុអភិវឌ្ឍន៍ និងវិនិយោគិនផងដែរ។

ការប្តេជ្ញាចិត្តចំពោះនិរន្តរភាពរបស់យើង គឺស្របតាមគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព (SDGs) របស់អង្គការសហប្រជាជាតិ ដោយផ្តោតជាសំខាន់លើបរិយាប័ន្នហិរញ្ញវត្ថុ លំនៅឋានប្រកបដោយចីរភាព និងសុខុមាលភាពសហគមន៍។ ការប្តេជ្ញាចិត្តទាំងនេះ គឺជាការនាំផ្លូវដល់ការរចនាផលិតផល ការវាយតម្លៃហានិភ័យ និងការវាស់វែងផលប៉ះពាល់ ដែលអនុញ្ញាតឱ្យយើងផ្តល់នូវអត្ថប្រយោជន៍ជាក់ស្តែងដល់អតិថិជន និងសហគមន៍។

គណៈកម្មការដឹកនាំកិច្ចការនិរន្តរភាព ដែលគាំទ្រដោយអភិបាលកិច្ចច្បាស់លាស់ និងទំនួលខុសត្រូវជាក់លាក់ បានតាមដានយ៉ាងសកម្មនូវប្រតិបត្តិការ បរិស្ថាន សង្គម និងអភិបាលកិច្ច និងហានិភ័យដែលកំពុងកើតមាន។ ក្នុងឆ្នាំនេះ យើងបានបញ្ចូលការពិចារណាលើផ្នែកបរិស្ថាន និងសង្គមបន្ថែមទៀត ទៅក្នុងដំណើរការឥណទាន និងប្រតិបត្តិការរបស់យើង រួមទាំងការពិនិត្យហានិភ័យសម្រាប់ឥណទានថ្មី និងការតាមដានប្រចាំឆ្នាំចំពោះការបញ្ចេញឥណទានដែលមានទំហំធំ។ វិធានការទាំងនេះពង្រឹងភាពធន់នៃផលប័ត្រឥណទាន និងធានាថាការផ្តល់កម្ចីរបស់យើង គាំទ្រដល់លទ្ធផលវិជ្ជមានផ្នែកសង្គម និងបរិស្ថាន។

យើងផ្តល់ជូននូវបច្ចុប្បន្នភាព បរិស្ថាន សង្គម និងអភិបាលកិច្ចប្រចាំត្រីមាសជូនដល់ក្រុមប្រឹក្សាភិបាល ដែលគ្របដណ្តប់លើវង្វាស់នៃប្រតិបត្តិការ មតិត្រឡប់របស់អតិថិជន និងលទ្ធផលនៃផលប៉ះពាល់សង្គម។ ការត្រួតពិនិត្យជាប្រព័ន្ធនេះ ធានាថាការពិចារណាលើនិរន្តរភាពត្រូវបានបញ្ចូលទៅក្នុងការសម្រេចចិត្ត ហើយប្រតិបត្តិការរបស់យើងនៅតែមានតម្លាភាព គណនេយ្យភាព និងស្របតាមការរំពឹងទុករបស់វិនិយោគិនអន្តរជាតិ។

ឆ្ពោះទៅមុខ ហ្វឹស ហ្វាយនែន នៅតែបន្តប្តេជ្ញាចិត្តក្នុងការពង្រីកផលប៉ះពាល់របស់យើង ពង្រឹងភាពធន់ និងផ្តល់នូវតម្លៃជាក់ស្តែងសម្រាប់អតិថិជន សហគមន៍ និងដៃគូអភិវឌ្ឍន៍ ខណៈពេលដែលកំពុងជំរុញហិរញ្ញប្បទានលំនៅឋានប្រកបដោយបរិយាប័ន្ន និងធន់នឹងការប្រែប្រួលអាកាសធាតុនៅទូទាំងប្រទេសកម្ពុជា។

---

លោក **សាយ សូនី** នាយកប្រតិបត្តិគ្រប់គ្រងទីផ្សារ និងជាប្រធានគណៈកម្មការដឹកនាំកិច្ចការនិរន្តរភាព

នៅក្នុងឆ្នាំ ២០២៥ ហ្វឹស ហ្វាយនែន ទទួលបានត្រាពណ៌ទឹកក្រូច Orange Seal ដែលត្រូវបានបញ្ជាក់ដោយដៃគូ ក្នុងការទទួលស្គាល់នូវការប្តេជ្ញាចិត្តរបស់យើងចំពោះសមភាពយេនឌ័រ និងនិរន្តរភាពបរិស្ថាន។ ត្រាពណ៌ទឹកក្រូច ដែលគាំទ្រដោយ IIX Values™ គឺជាការវាយតម្លៃកម្រិតអន្តរជាតិ ដែលវាស់វែងពីវឌ្ឍនភាពលើសមភាពយេនឌ័រ និងសកម្មភាពទាកទងនឹងអាកាសធាតុ ដែលនេះសបញ្ជាក់ឱ្យឃើញពីការយកចិត្តទុកដាក់ឥតឈប់ឈររបស់យើងលើកំណើនប្រកបដោយបរិយាប័ន្ន និងការទទួលខុសត្រូវ។

→ ស្វែងយល់បន្ថែមពី orange seal: www.orangemovement.global

ត្រាពណ៌ទឹកក្រូច Orange Seal មានសុពលភាពរយៈពេលមួយឆ្នាំគិតចាប់ពីកាលបរិច្ឆេទដែលបានទទួលស្គាល់ទៅលើគុណវឌ្ឍិ ។ ដើម្បីរក្សាបាននូវត្រានេះ ក្រុមហ៊ុន ហ្វឹស ហ្វាយនែន ភីអិលស៊ី ត្រូវតែធ្វើការវាយតម្លៃឡើងវិញនូវគោលនយោបាយ និងការអនុវត្តរបស់ខ្លួនធៀបនឹងគុណតម្លៃរបស់ IIX Values ជារៀងរាល់ឆ្នាំ ដើម្បីបន្តសុពលភាពនៃស្ថានភាព Orange Seal ក៏ដូចជាដើម្បីរក្សានូវភាពជឿជាក់នៃផលប៉ះពាល់លើផ្នែកយេនឌ័រ និងអាកាសធាតុរបស់ខ្លួន។

ពិន្ទុ ESG+
**៩,០០**
លើ ១០

ពិន្ទុផលប៉ះពាល់
**៧,៣៦**
លើ ១០

កម្រិតផ្ទៀងផ្ទាត់*
★★★★½

* កម្រិតនៃការផ្ទៀងផ្ទាត់នេះ តំណាងឱ្យសំឡេងរបស់អតិថិជន និងឆ្លុះបញ្ចាំងពីកម្រិតដែលអតិថិជនយល់ស្របចំពោះពិន្ទុនៃផលប៉ះពាល់របស់ស្ថាប័ន។

## ក្របខណ្ឌនិរន្តរភាព

**ទស្សនៈវិស័យ**

ជួយឱ្យក្រុមគ្រួសារ នៅក្នុងប្រទេសកម្ពុជាដែលមាន ចំណូលមធ្យមកម្រិតទាប បានរស់នៅក្នុង សេចក្តីថ្លៃថ្នូរសុវត្ថិភាព សុភមង្គល និងមានស្ថេរភាព តាមរយៈការផ្តល់លទ្ធភាពឱ្យពួកគាត់មានផ្ទះជាកម្មសិទ្ធិផ្ទាល់ខ្លួន

**បេសកកម្ម/គោលបំណង**

បង្កើតស្ថេរភាពសេដ្ឋកិច្ចនៃគ្រួសារកម្ពុជាដែលមានចំណូលមធ្យមកម្រិតទាប តាមរយៈការផ្តល់សេវាឥណទានដើម្បីឱ្យពួកគាត់ក្លាយជាម្ចាស់កម្មសិទ្ធិនៃផ្ទះសម្បែង

**ការអភិវឌ្ឍដោយចីរភាព**

លើសពីសេវាហិរញ្ញវត្ថុ (បរិស្ថាន សង្គម អភិបាលកិច្ច និងនវានុវត្តន៍)

**គោលការណ៍ ESG**

| | | | |
|---|---|---|---|
| តែងតែគិតគូរពីផលប៉ះពាល់សង្គម និងបរិស្ថាននៅ គ្រប់សេចក្តីសម្រេចចិត្ត ដោយរួមបញ្ចូលការគ្រប់គ្រង ធនធានមនុស្ស និងផលប៉ះពាល់ ពីប្រតិបត្តិការ ហិរញ្ញប្បទាន និងលទ្ធកម្ម | អនុលោមតាមច្បាប់ទាំងឡាយ ទាក់ទងទៅនឹងបរិស្ថាន រួមមានបទបញ្ញត្តិរបស់ប្រទេសកម្ពុជា ច្បាប់អន្តរជាតិ និងការអនុវត្តន៍ ផ្សេងៗ ដើម្បីធានានិរន្តភាព ប្រតិបត្តិការ កំណើនអតិថិជន និងកាត់បន្ថយហានិភ័យ | ធ្វើប្រតិបត្តិការដោយប្រុងប្រយ័ត្ន ដោយមានការយកចិត្តទុកដាក់ត្រឹមត្រូវ និងមានការត្រួតពិនិត្យយ៉ាង ទៀងទាត់ក្នុងការវាយតម្លៃ និងចាប់យកគោលការណ៍នោះ មកអនុវត្តន៍ ដើម្បីការពារ និងកាត់បន្ថយគ្រោះថ្នាក់ទៅដល់បរិស្ថាន ក៏ដូចជាលើកតម្កើង សមភាព និងសមធម៌សង្គម | ចូលរួមជាមួយភាគីពាក់ពន្ធ័ក្នុងការគ្រប់គ្រងហានិភ័យ សង្គម និងបរិស្ថាន និងកំណត់ ឱ្យបាននូវឱកាស ដើម្បីធ្វើឱ្យមានភាពប្រសើរឡើង |

**សសរស្តម្ភយុទ្ធសាស្ត្រ ESG** / **គោលដៅយុទ្ធសាស្ត្រ**

| **បរិស្ថាន**<br>ជាស្ថាប័នដែលមានទំនួលខុសត្រូវក្នុងការលើកស្ទួយកិច្ចការពារបរិស្ថាន | **សង្គម**<br>ជាស្ថាប័នដែលមានទំនួលខុសត្រូវ ក្នុងការលើកស្ទួយសុខមាលភាពសង្គម | **អភិបាលកិច្ច/សេដ្ឋកិច្ច**<br>ជាគ្រឹះស្ថានដែលមាននិរន្តភាព ប្រកបដោយការទទួលខុសត្រូវ និងគណនេយ្យភាព |
|---|---|---|
| • កាត់បន្ថយផលប៉ះពាល់ដល់បរិស្ថានតាមរយៈការសន្សំសំចៃការប្រើប្រាស់ថាមពល ធនធានធម្មជាតិ និងការគ្រប់គ្រងកាកសំណល់<br>• ជាស្ថាប័នដែលនាំមុនគេលើនវានុវត្តន៍ " **ឥណទានលំនៅឋានបៃតង**" ក្នុងប្រទេសកម្ពុជា | • ធានាឱ្យមានបរិយាបន្នហិរញ្ញវត្ថុ និង ចំណេះដឹងផ្នែកហិរញ្ញវត្ថុ និងផ្នែកវិនិយោគលើផ្ទះដំបូង<br>• ប្តេជ្ញាក្លាយជាស្ថាប័នដែលគ្រប់គ្នាចង់ធ្វើការជាមួយ<br>• លើកស្ទួយសុខមាលភាពសង្គម ការការយល់ដឹងអំពីកិច្ចការពារបរិស្ថាន និងកិច្ចការងារសង្គម<br>• គោរពសិទ្ធិមនុស្ស និងភាពចម្រុះ | • ប្រកាន់ខ្ជាប់អតិថិជនជាគោលដោយផ្តល់នូវសេវាដែលមានគុណភាពទៅដល់អតិថិជន<br>• ធានាថាប្រតិបត្តិការអាជីវកម្មស្ថិត នៅក្រោមការអនុវត្តអភិបាលកិច្ចល្អ ព្រមជាមួយការពង្រឹងលើកិច្ចការពារអតិថិជន<br>• ធានាថាហានិភ័យដែលពាក់ព័ន្ធបរិស្ថាន សង្គម និងអភិបាលកិច្ចត្រូវបានគ្រប់គ្រងប្រកបដោយប្រសិទ្ធភាព |

**ចូលរួមចំណែកក្នុងគោលដៅអភិវឌ្ឍប្រកបដោយចីរភាព**








# បទពិសោធន៍អតិថិជន ការគាំទ្រ និងផលប៉ះពាល់សហគមន៍

យើងនៅតែបន្តប្តេជ្ញាចិត្តក្នុងការផ្តល់ជូននូវបទពិសោធន៍ដ៏ល្អប្រសើរជូនដល់អតិថិជនរបស់យើង ព្រមទាំងគាំទ្រដល់សហគមន៍ដែលយើងបម្រើតាមគ្រប់មធ្យោបាយដែលយើងអាចធ្វើបាន។



# ការបន្តស្វែងរកភាពល្អឥតខ្ចោះនៃបទពិសោធន៍អតិថិជន

ហ្វឹស ហ្វាយនែន ប្រើប្រាស់ការយល់ដឹងពីប្រភពចម្រុះ ដើម្បីស្វែងយល់ពីអ្វីដែលកំពុងផ្តល់ផលល្អដល់អតិថិជនរបស់យើង និងដើម្បីកំណត់រកឱកាសសម្រាប់ការកែលម្អបន្ថែម។ យើងធ្វើការអង្កេតលើបទពិសោធន៍អតិថិជន ដើម្បីប្រមូលមតិកែលម្អ តាមដាននិន្នាការ និងវាយតម្លៃពីរបៀបដែលអតិថិជនប្រើប្រាស់ផលិតផល និងសេវាកម្មរបស់យើង។ រង្វាស់នៃប្រតិបត្តិការ ដែលរួមមាន៖ បណ្តឹងតវ៉ា វិវាទ រយៈពេលនៃការផ្តល់សេវា ការជួយយកអាសារសមត្ថភាព និងភាពឆ្លើយតបបានរហ័សនិងទាន់ពេលវេលា ក៏ជាសូចនាករដ៏មានតម្លៃក្នុងការបង្ហាញពីចំណុចដែលត្រូវការការយកចិត្តទុកដាក់ផងដែរ។ ជាមួយគ្នានឹងពិន្ទុសុច្ឆន្ទៈអតិថិជន (Net Promoter Score - NPS) ដែលជារង្វាស់ខាងក្រៅនៃកម្រិតដែលអតិថិជនណែនាំបន្ត ការយល់ដឹងទាំងនេះជួយយើងក្នុងការកំណត់គោលដៅនៃប្រតិបត្តិការ និងជំរុញការកែលម្អជាបន្តបន្ទាប់។

យើងកំពុងផ្តល់អាទិភាពលើបទពិសោធន៍សំខាន់ៗរបស់អតិថិជន និងដាក់បញ្ចូលនូវវិធីសាស្ត្រថ្មីក្នុងការប្រមូលមតិកែលម្អដោយផ្ទាល់ ដែលមានគោលបំណងផ្តល់នូវការយល់ដឹងកាន់តែពេញលេញ និងស៊ីសង្វាក់គ្នាអំពីតម្រូវការរបស់អតិថិជន។ កិច្ចការនេះអនុញ្ញាតឱ្យយើងអាចផ្តោតកាន់តែច្បាស់លើលទ្ធផលដែលសំខាន់បំផុតសម្រាប់អតិថិជនរបស់យើង។

លើសពីនេះ យើងបានឈានចូលដល់ឆ្នាំទីបីនៃកម្មវិធី "ការអង្កេតពីទស្សនៈយល់ឃើញដោយខ្លួនឯងរបស់អតិថិជន" (Client Self-Perception Survey) ដែលផ្តល់នូវការយល់ដឹងកាន់តែស៊ីជម្រៅអំពីតម្រូវការហិរញ្ញប្បទានលំនៅឋាន។ របកគំហើញដំបូងបានបង្ហាញថា អតិថិជនជាច្រើនអាចនឹងត្រូវការឥណទានកែលម្អលំនៅឋានច្រើនលើក ដើម្បីសម្រេចបាននូវគោលដៅលំនៅឋានរបស់ពួកគេ ដែលនេះឆ្លុះបញ្ចាំងពីសមត្ថភាពហិរញ្ញវត្ថុដែលមានកម្រិតក្នុងការស្នើសុំទឹកប្រាក់សរុបក្នុងពេលតែមួយ។ ការយល់ដឹងទាំងនេះជួយយើងក្នុងការកែលម្អការរចនាផលិតផល និងការផ្តល់សេវាកម្មឱ្យកាន់តែប្រសើរ ដើម្បីឆ្លើយតបទៅនឹងតម្រូវការដែលកំពុងវិវឌ្ឍរបស់អតិថិជន។

**៦៨,៦**

កម្រិតពិន្ទុសុច្ឆន្ទៈអតិថិជន

កើនពី ៦៤ ឆ្នាំ ២០២៤

**៩៨%**

អត្រាការរក្សាអតិថិជន

កើនពី ៩៥% ឆ្នាំ ២០២៤

**០,២%**

អនុបាតបញ្ហា និងបណ្តឹងតវ៉ាធៀបនឹងប្រតិបត្តិការសរុប

ថយពី ០,៣% ឆ្នាំ ២០២៤




សូមស្វែងយល់បន្ថែមអំពី Client Self-Perception Survey Repot 2025 at www.firstfinance.com.kh/reports




# ការពង្រឹងសមត្ថភាពហិរញ្ញវត្ថុសម្រាប់ការក្លាយជាម្ចាស់លំនៅឋាន

ក្នុងនាមជាគ្រឹះស្ថានឯកទេសក្នុងការផ្តល់ឥណទានលំនៅឋានតម្លៃសមរម្យនៅកម្ពុជា ហ្វឹស ហ្វាយនែន បន្តពង្រឹងចំណេះដឹងផ្នែកហិរញ្ញវត្ថុក្នុងចំណោមគ្រួសារដែលមានចំណូលទាប និងមធ្យម តាមរយៈការអប់រំតាមប្រព័ន្ធឌីជីថលដែលងាយស្រួលក្នុងការទទួលបាន។ យើងផ្តល់ជូននូវខ្លឹមសារអប់រំផ្នែកហិរញ្ញវត្ថុនៅលើបណ្តាញសង្គមរបស់យើង រួមមានហ្វេសប៊ុក (Facebook) និងយូធូប (YouTube) ដើម្បីពង្រីកវិសាលភាពនៃការផ្សព្វផ្សាយ និងគាំទ្រដល់ការសម្រេចចិត្តផ្នែកហិរញ្ញវត្ថុប្រកបដោយការយល់ដឹងច្បាស់លាស់។

នៅក្នុងឆ្នាំ ២០២៥ យើងបានធ្វើឱ្យសម្ភារអប់រំរបស់យើងកាន់តែប្រសើរឡើង ដោយបញ្ចូលនូវការរចនាក្រាហ្វិក សៀវភៅរឿងនិទានខ្លីៗ និងវីដេអូខ្លីៗដែលផលិតដោយបច្ចេកវិទ្យាបញ្ញាសិប្បនិម្មិត (AI) ដើម្បីធ្វើឱ្យការសិក្សាកាន់តែមានភាពទាក់ទាញ និងងាយស្រួលយល់។ ធនធានទាំងនេះគ្របដណ្តប់លើប្រធានបទសំខាន់ៗ ដូចជា ការគ្រប់គ្រងលុយកាក់ក្នុងគ្រួសារ ការខ្ចីប្រាក់ប្រកបដោយការទទួលខុសត្រូវ ការជ្រើសរើសគ្រឹះស្ថានហិរញ្ញវត្ថុដែលមានអាជ្ញាប័ណ្ណត្រឹមត្រូវ និងការបង្កើនការប្រុងប្រយ័ត្នចំពោះការឆបោកតាមប្រព័ន្ធអនឡាញ។

រាល់សម្ភារអប់រំទាំងអស់ត្រូវបានដាក់បញ្ចូលទៅក្នុងប្រព័ន្ធអនឡាញ ដែលអនុញ្ញាតឱ្យអ្នកប្រើប្រាស់អាចទាញយក និងមើលឡើងវិញបានតាមតម្រូវការ។ ឆ្នាំ ២០២៥ គឺជាឆ្នាំទី ៥ ដែល ហ្វឹស ហ្វាយនែន បានផលិតខ្លឹមសារអប់រំផ្នែកហិរញ្ញវត្ថុ និងសិទ្ធិអចលនទ្រព្យ ដែលនេះឆ្លុះបញ្ចាំងពីការប្តេជ្ញាចិត្តរយៈពេលវែងរបស់យើងក្នុងការផ្តល់អំណាចដល់អតិថិជន និងសហគមន៍ឱ្យកាន់តែទូលំទូលាយ។

យើងនៅតែបន្តផ្តោតលើការពង្រីក និងបង្កើនខ្លឹមសារនៃធនធានទាំងនេះ ដើម្បីបម្រើសាធារណជន និងអតិថិជនរបស់យើងឱ្យកាន់តែប្រសើរឡើង។ យើងជឿជាក់យ៉ាងមុតមាំថា ចំណេះដឹងផ្នែកហិរញ្ញវត្ថុគឺជាគ្រឹះដ៏សំខាន់សម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុទាំងក្នុងគ្រួសារ និងអាជីវកម្ម ជាពិសេសសម្រាប់គ្រួសារដែលប្រើប្រាស់ឥណទានលំនៅឋានរយៈពេលវែង។ ជាចុងក្រោយ ភាពជាម្ចាស់ផ្ទះប្រកបដោយចីរភាព ទាមទារឱ្យមានវិន័យហិរញ្ញវត្ថុរឹងមាំ ហើយយើងប្តេជ្ញានឹងគាំទ្រអតិថិជនរបស់យើងក្នុងដំណើរដ៏វែងមួយនេះ។

សូមស្វែងយល់បន្ថែមអំពី "ផ្ទះកក់ក្តៅ គ្រួសារសុខសាន្ត" នៅលើ www.firstfinance.com.kh/financial-tip-in-comic-book

## ការលើកកម្ពស់ចំណេះដឹងផ្នែកហិរញ្ញវត្ថុតាមរយៈកម្មវិធី AI Kids Podcast “នាទីជួបជាមួយ អូន នែន”

ហ្វឹស ហ្វាយនែន បានដាក់សម្ពោធកម្មវិធី Podcast សម្រាប់កុមារដែលផលិតដោយបច្ចេកវិទ្យា អេអាយ (AI) ក្រោមចំណងជើងថា "**នាទីជួបជាមួយ អូន នែន**" ដើម្បីលើកកម្ពស់ចំណេះដឹងផ្នែកហិរញ្ញវត្ថុក្នុងទម្រង់មួយដែលទាក់ទាញ និងងាយស្រួលយល់។ កម្មវិធីនេះត្រូវបានសម្របសម្រួលដោយតួអង្គដែលបង្កើតឡើងដោយ AI ដ៏រួសរាយម្នាក់ ដោយគ្របដណ្តប់លើប្រធានបទសំខាន់ៗ ដូចជា ទម្លាប់នៃការសន្សំ ការខ្ចីប្រាក់ប្រកបដោយការទទួលខុសត្រូវ និងការយល់ដឹងអំពីការឆបោកតាមប្រព័ន្ធអនឡាញ។ល។

នៅក្នុងឆ្នាំ ២០២៥ វីដេអូសរុបចំនួន ១៨ ភាគត្រូវបានផលិតឡើង ដោយក្នុងមួយភាគទទួលបានការចូលទស្សនាជាមធ្យមប្រមាណ ១,០០០ ដង ដែលបង្ហាញឱ្យឃើញពីអន្តរកម្មកាន់តែខ្លាំង បើធៀបនឹងខ្លឹមសារដែលជារូបភាពក្រាហ្វិកបែបប្រពៃណី។ កម្មវិធីនេះបានទាក់ទាញទាំងកុមារ និងមនុស្សពេញវ័យ ដែលជួយពង្រីកការយល់ដឹងផ្នែកហិរញ្ញវត្ថុនៅគ្រប់វ័យ។

តាមរយៈគំនិតផ្តួចផ្តើមនេះ ហ្វឹស ហ្វាយនែន បន្តធ្វើនវានុវត្តន៍ក្នុងការអប់រំតាមប្រព័ន្ធឌីជីថល ដើម្បីគាំទ្រដល់ការសម្រេចចិត្តផ្នែកហិរញ្ញវត្ថុប្រកបដោយភាពឆ្លាតវៃ និងភាពជាម្ចាស់លំនៅឋានប្រកបដោយចីរភាព។




សូមស្វែងយល់បន្ថែមអំពី "នាទីជួបជាមួយ អូន នែន" នៅលើ www.facebook.com/FirstFinance/reels/








# ការផ្តល់ការគាំទ្រតាមគ្រប់លទ្ធភាពដែលយើងអាចធ្វើបាន

សម្ពាធលើថ្លៃចំណាយនៃការរស់នៅដែលកំពុងបន្តកើតមាន និងភាពតានតឹងនៅតាមព្រំដែនរវាងកម្ពុជា និងថៃ បានបន្តដាក់បន្ទុកយ៉ាងខ្លាំងដល់អតិថិជន និងសហគមន៍ដែលយើងបម្រើក្នុងអំឡុងឆ្នាំនេះ។ ក្នុងនាមជាស្ថាប័នដែលប្តេជ្ញាចិត្តចំពោះហិរញ្ញវត្ថុប្រកបដោយការទទួលខុសត្រូវ និងបរិយាប័ន្ន ហ្វឹស ហ្វាយនែន នៅតែរក្សាជំហររឹងមាំក្នុងការគាំទ្រដល់គ្រួសារដែលរងផលប៉ះពាល់ តាមរយៈវិធានការជំនួយដល់អតិថិជនជាច្រើន រួមមាន៖ ការរៀបចំឥណទានឡើងវិញ ការលើកលែងការប្រាក់ និងការផ្តល់រយៈពេលអនុគ្រោះ។ ក្នុងករណីពិសេស និងស្របតាមការអំពាវនាវរបស់ធនាគារជាតិនៃកម្ពុជា ស្ថាប័នក៏បានសម្រេចអនុម័តការលុបចោលឥណទាន (write-offs) សម្រាប់គ្រួសារកងទ័ពដែលបានពលីជីវិតក្នុងជម្លោះព្រំដែន ដើម្បីធានាថាគ្រួសារដែលងាយរងគ្រោះមិនត្រូវបានដាក់បន្ទុកបន្ថែមដោយកាតព្វកិច្ចហិរញ្ញវត្ថុ ក្នុងអំឡុងពេលដ៏លំបាកបំផុតនោះឡើយ។

ទន្ទឹមនឹងនោះ ហ្វឹស ហ្វាយនែន បានផ្តើមអនុវត្តកម្មវិធីមនុស្សធម៌ និងការគាំទ្រសហគមន៍ជាបន្តបន្ទាប់ ដែលជាផ្នែកមួយនៃរបៀបវារៈទំនួលខុសត្រូវសង្គមដ៏ទូលំទូលាយរបស់ខ្លួន។ គំនិតផ្តួចផ្តើមទាំងនេះ រួមមាន៖ ការផ្តល់ជំនួយស្បៀងអាហារដល់ជនភៀសខ្លួន ការសាងសង់ផ្ទះជូនគ្រួសារកងទ័ពដែលបានពលី និងការផ្តល់ជំនួយមនុស្សធម៌ដោយផ្ទាល់ដល់កងទ័ពនៅជួរមុខ។ ជាសមិទ្ធផល កម្មវិធីទាំងនេះបានផ្តល់អត្ថប្រយោជន៍ដល់មនុស្សជាង ៥,៤០០ នាក់ ដែលជួយពង្រឹងតួនាទីរបស់ ហ្វឹស ហ្វាយនែន មិនត្រឹមតែជាអ្នកផ្តល់ហិរញ្ញប្បទានលំនៅឋានប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជាស្ថាប័នគំរូដែលមានការទទួលខុសត្រូវ និងប្តេជ្ញាចិត្តចំពោះស្ថិរភាពសង្គម និងភាពធន់របស់សហគមន៍។

ហ្វឹស ហ្វាយនែន ក៏សូមទទួលស្គាល់ និងវាយតម្លៃខ្ពស់ចំពោះក្តីមេត្តា និងទឹកចិត្តសប្បុរសរបស់បុគ្គលិកទាំងអស់ ដែលបានរួមចំណែកទាំងពេលវេលា និងធនធានហិរញ្ញវត្ថុ ដើម្បីធ្វើឱ្យគំនិតផ្តួចផ្តើមទាំងនេះអាចលេចរូបរាងឡើងបាន។ ដោយឆ្លុះបញ្ចាំងពីវប្បធម៌ស្ម័គ្រចិត្ត និងគោលបំណងរួមដ៏រឹងមាំរបស់ស្ថាប័ន បុគ្គលិកចំនួន ១០ នាក់ បានចូលរួមក្នុងកម្មវិធីបរិច្ចាគឈាមដែលរៀបចំដោយសមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា (CMA) និងសមាគមធនាគារនៅកម្ពុជា (ABC) ដែលនេះជាការបង្ហាញកាន់តែច្បាស់អំពីការប្តេជ្ញាចិត្តរបស់ ហ្វឹស ហ្វាយនែន ចំពោះសុខុមាលភាពសហគមន៍ និងការទទួលខុសត្រូវរួម។

**រូបភាពខាងលើ និងខាងក្រោម៖** អ្នកគ្រប់គ្រងសាខាខេត្តកំពង់ស្ពឺ និងសាខាខេត្តកំពត កំពុងប្រគល់ស្បៀងអាហារជូនអាជ្ញាធរខេត្ត ដើម្បីចែកចាយបន្តជូនដល់ជនភៀសខ្លួន។

**៥,៤០០**

បានទទួលប្រយោជន៍ដោយផ្ទាល់ពីកម្មវិធីទំនួលខុសត្រូវសង្គម

**១,៥០០**

ម៉ោង ដែលបុគ្គលិកចំណាយធ្វើលើកិច្ចការងារស្ម័គ្រចិត្ត*

**១០៨**

ចំនួនអតិថិជនជាទាហានឬជនភៀសសឹកដែលរងផលប៉ះពាល់ពីជម្លោះព្រំដែន

**១១៨ម៉ឺន**

ទឹកប្រាក់ដែលលើកលែង (គិតជាដុល្លារ)

* បំប្លែងការបរិច្ចាគជាសាច់ប្រាក់របស់បុគ្គលិកឱ្យទៅជាម៉ោងការងារស្ម័គ្រចិត្ត (ការបរិច្ចាគសាច់ប្រាក់សរុប ចែកនឹង កម្រៃពលកម្មមធ្យមសរុបក្នុងមួយម៉ោង





# ការចូលរួម និងការគាំទ្រដល់បុគ្គលិក

យើងកំពុងពង្រឹងវប្បធម៌ដែលផ្តោតលើគោលបំណងច្បាស់លាស់ គណនេយ្យភាព និងការរៀនសូត្រជាបន្តបន្ទាប់ ដើម្បីជំរុញការចូលរួមពីបុគ្គលិករបស់យើង លើកកម្ពស់បទពិសោធន៍អតិថិជន និងសម្រេចឱ្យបាននូវយុទ្ធសាស្ត្ររបស់យើង ក្នុងនាមជាគ្រឹះស្ថានឯកទេសក្នុងការផ្តល់ហិរញ្ញប្បទានលំនៅឋានតម្លៃសមរម្យនៅកម្ពុជា។





## ការជំរុញកន្លែងធ្វើការដែលមានសុវត្ថិភាព ការគោរព និងផ្តោតលើមនុស្សជាចម្បង

ហ្វឺស ហ្វាយនែន ប្តេជ្ញាផ្តល់ជូននូវបរិយាកាសការងារដែលវិជ្ជមាន និងមានការគាំទ្រ ដែលបុគ្គលិករបស់យើងមានអារម្មណ៍ថាមានសុវត្ថិភាព ទទួលបានការគោរព និងត្រូវបានផ្តល់តម្លៃ។ យើងយកចិត្តទុកដាក់ខ្ពស់លើការទទួលខុសត្រូវចំពោះសុខភាព សុវត្ថិភាព និងសុខុមាលភាពរបស់បុគ្គលិក ហើយយើងបន្តពង្រឹងគោលនយោបាយ និងការអនុវត្តរបស់យើងឱ្យកាន់តែប្រសើរឡើងស្របតាមស្មារតីនេះ។

ដោយសារគំរូសេវាកម្មរបស់យើងតម្រូវឱ្យចុះទៅដល់ទីកន្លែងផ្ទាល់ គ្រោះថ្នាក់ចរាចរណ៍គឺជាហានិភ័យចម្បងសម្រាប់បុគ្គលិកផ្នែកឥណទាន ។ ដើម្បីកាត់បន្ថយបញ្ហានេះ យើងបានអនុវត្តនីតិវិធីសុវត្ថិភាពគ្រប់ជ្រុងជ្រោយ ការបណ្តុះបណ្តាលជាចាំបាច់ និងការរំលឹកប្រចាំខែ ដើម្បីពង្រឹងការអនុវត្តប្រកបដោយសុវត្ថិភាព ដែលជាផ្នែកមួយនៃក្របខ័ណ្ឌការងារកាន់តែទូលំទូលាយ ក្នុងការរក្សាកន្លែងធ្វើការដែលមានសុវត្ថិភាព និងបរិយាប័ន្ន។

វិធីសាស្ត្រដែលផ្តោតលើមនុស្សជាចម្បងរបស់យើង ត្រូវបានដឹកនាំដោយទិន្នន័យ និងការតាមដានជាប្រចាំ។ យើងធ្វើការវាយតម្លៃលើសុខភាព សុវត្ថិភាព និងសុខុមាលភាពឱ្យបានទៀងទាត់ រួមទាំងការពិនិត្យឡើងវិញលើបរិយាកាសការងារដែលមានហានិភ័យខ្ពស់ ដើម្បីគាំទ្រដល់ការកំណត់អត្តសញ្ញាណហានិភ័យឱ្យបានទាន់ពេលវេលា និងការចាត់វិធានការបង្ការទុកជាមុន។

ថ្នាក់ដឹកនាំដើរតួនាទីយ៉ាងសំខាន់ក្នុងសុវត្ថិភាពនៅកន្លែងធ្វើការ។ យើងបន្តពង្រឹងសមត្ថភាពដឹកនាំ ដោយជំរុញឱ្យមានការពិភាក្សាជាប្រចាំអំពីសុខុមាលភាព ការសន្ទនាដោយបើកចំហ និងការផ្តល់ការណែនាំច្បាស់លាស់ក្នុងការលើកឡើងអំពីកង្វល់ផ្សេងៗ ដើម្បីជំរុញកន្លែងធ្វើការទៅជាកន្លែងដែលបុគ្គលិកមានអារម្មណ៍ថាទទួលបានការគាំទ្រ និងអាចបំពេញការងារបានល្អបំផុត។

“

នៅ ហ្វឺស ហ្វាយនែន សុវត្ថិភាព និងសុខុមាលភាពរបស់បុគ្គលិក គឺជាអាទិភាពចម្បងរបស់យើង។ តាមរយៈគោលនយោបាយដ៏រឹងមាំ ការបណ្តុះបណ្តាលជាបន្តបន្ទាប់ និងការដឹកនាំប្រកបដោយការគាំទ្រ យើងកំពុងកសាងបរិយាកាសការងារមួយ ដែលបុគ្គលិកមានអារម្មណ៍ថាត្រូវបានផ្តល់តម្លៃ និងផ្តល់អំណាច ដើម្បីបញ្ចេញសមត្ថភាពឱ្យអស់ពីលទ្ធភាព។



**កញ្ញា ង៉ែត សុគន្ធ**
នាយិកានាយកដ្ឋានធនធានមនុស្ស

**១,0%** — បុគ្គលិកមានពិការភាព
→ រក្សាមួយតាំងពីឆ្នាំ ២០២៤

**0%** — គ្រោះថ្នាក់ដល់ជីវិត
→ រក្សាសូន្យតាំងពីឆ្នាំ ២០២៤

**៣** — រងរបួសមិនអាចមកធ្វើការ
↓ ថយពី ៧ ករណីឆ្នាំ ២០២៤




## ការទាក់ទាញអ្នកមានសមត្ថភាព និងការកសាងបណ្តាញធនធានមនុស្សសំខាន់ៗ

ដើម្បីសម្រេចបាននូវគោលដៅយុទ្ធសាស្ត្រ និងរក្សាកំណើនរយៈពេលវែង ហ្វីស ហ្វាយនែន បន្តផ្តល់អាទិភាពលើការទាក់ទាញ ការរក្សាទុក និងការអភិវឌ្ឍអ្នកមានសមត្ថភាព ដោយផ្តោតជាសំខាន់លើក្រុមការងារជួរមុខ ដែលជាតួអង្គដ៏សំខាន់ក្នុងការបម្រើអតិថិជនកម្ពុជាដែលមានចំណូលទាប និងមធ្យម។ យើងប្តេជ្ញាជំរុញវប្បធម៌នៃការរៀនសូត្រ និងការអភិវឌ្ឍជាបន្តបន្ទាប់ ដើម្បីអនុញ្ញាតឱ្យបុគ្គលិករបស់យើងអាចកសាងអាជីពដ៏មានអត្ថន័យ ស្របពេលជាមួយគ្នាគឺត្រូវធានាថា ហ្វីស ហ្វាយនែន នៅតែជាជម្រើសការងារដ៏ល្អបំផុត នៅក្នុងវិស័យហិរញ្ញវត្ថុនៅកម្ពុជា។ យុទ្ធសាស្ត្រធនធានមនុស្សរបស់យើង សង្កត់ធ្ងន់លើការរៀបចំផែនការអភិវឌ្ឍន៍បុគ្គលសម្រាប់ការបង្កើនជំនាញ ការបណ្តុះបណ្តាលជំនាញថ្មី និងការរីកចម្រើនក្នុងអាជីព ដែលជួយពង្រឹងបណ្តាញអ្នកមានសមត្ថភាពផ្ទៃក្នុង និងធ្វើឱ្យបទពិសោធន៍ការងាររបស់បុគ្គលិកមានភាពលេចធ្លោ។

នៅក្នុងឆ្នាំ ២០២៥ ក្រោមការគាំទ្រផ្នែកហិរញ្ញប្បទានពីដៃគូរយៈពេលវែងរបស់យើង គឺ Norfund យើងបានជួលទីប្រឹក្សាធនធានមនុស្សឯករាជ្យ ដើម្បីធ្វើសវនកម្មការងារ និងការវាយតម្លៃតម្រូវការធនធានមនុស្សឱ្យបានគ្រប់ជ្រុងជ្រោយ លើប្រព័ន្ធគ្រប់គ្រងធនធានមនុស្សរបស់ ហ្វីស ហ្វាយនែន ។ ការពិនិត្យឡើងវិញនេះ បានធ្វើការប្រៀបធៀបគោលនយោបាយ និងការអនុវត្តរបស់យើង ធៀបនឹងច្បាប់ស្តីពីការងារនៃព្រះរាជាណាចក្រកម្ពុជា និងស្តង់ដារអន្តរជាតិដែលពាក់ព័ន្ធ ដើម្បីកំណត់រកចំណុចដែលត្រូវកែលម្អ និងរៀបចំផែនទីបង្ហាញផ្លូវសម្រាប់សកម្មភាពកែតម្រូវ សំដៅលើកកម្ពស់អនុលោមភាព អភិបាលកិច្ច និងការគ្រប់គ្រងកម្លាំងពលកម្ម។

គំនិតផ្តួចផ្តើមនេះ ជួយពង្រឹងសមត្ថភាពរបស់ ហ្វីស ហ្វាយនែន ក្នុងការទាក់ទាញ អភិវឌ្ឍ និងរក្សាទុកបុគ្គលិកដែលមានសមត្ថភាពខ្ពស់ ព្រមទាំងពង្រឹងកន្លែងធ្វើការឱ្យមានអនុលោមភាព សុវត្ថិភាព និងប្រសិទ្ធភាពការងារខ្ពស់។ តាមរយៈការធ្វើបែបនេះ វានឹងជួយគាំទ្រដល់និរន្តរភាពរយៈពេលវែងរបស់ស្ថាប័ន និងជំរុញបេសកកម្មរបស់យើងក្នុងការពង្រីកលទ្ធភាពទទួលបានហិរញ្ញប្បទានលំនៅឋានប្រកបដោយបរិយាប័ន្ន និងតម្លៃសមរម្យ សម្រាប់គ្រួសារដែលមានចំណូលទាប និងមធ្យមនៅទូទាំងប្រទេសកម្ពុជា។

## ការស្តាប់មតិយោបល់របស់បុគ្គលិកយើង

នៅហ្វីស ហ្វាយនែន យើងស្វែងរកវិធីសាស្ត្រនានាជាបន្តបន្ទាប់ ដើម្បីលើកកម្ពស់បទពិសោធន៍របស់បុគ្គលិក និងផ្តល់អំណាចដល់ក្រុមការងាររបស់យើង ក្នុងការសម្រេចបាននូវលទ្ធផលដ៏រឹងមាំជូនដល់អតិថិជន សហគមន៍ និងភាគទុនិក។

បណ្តាញដ៏សំខាន់មួយសម្រាប់ការទទួលបាននូវការយល់ដឹងទាំងនេះ គឺតាមរយៈការស្ទង់មតិបុគ្គលិកប្រចាំឆ្នាំ ដែលផ្តល់ឱ្យថ្នាក់ដឹកនាំនូវទិដ្ឋភាពច្បាស់លាស់អំពីវប្បធម៌ស្ថាប័ន បទពិសោធន៍របស់បុគ្គលិក និងឥរិយាបថនានាដែលជំរុញឱ្យមានប្រសិទ្ធភាពការងារ និងផលប៉ះពាល់ជាវិជ្ជមានដល់អតិថិជន។

នៅក្នុងការស្ទង់មតិចុងក្រោយបង្អស់របស់យើង កម្រិតនៃការពេញចិត្តរបស់បុគ្គលិកបានហក់ឡើងដល់ ៨០% ដែលរក្សានូវកម្រិតដដែលបើធៀបនឹងខែសីហា ឆ្នាំ ២០២៤។ លទ្ធផលនេះបានឆ្លុះបញ្ចាំងពីសន្ទុះវិជ្ជមាននៃគំនិតផ្តួចផ្តើមនានារបស់យើង ដែលផ្តោតលើបុគ្គលិកជាចម្បង។

សន្ទស្សន៍លើភាពពេញចិត្តរបស់បុគ្គលិក (%)




**៥៣ម៉** បណ្តុះបណ្តាលបុគ្គលិកម្នាក់ក្នុង១ឆ្នាំ
ចុះពី ៦៣ម៉ ក្នុងឆ្នាំ២០២៤

**២៣%** តួនាទីដែលត្រូវបំពេញដោយបុគ្គលិកខាងក្នុង
កើនពី ៧% ក្នុងឆ្នាំ២០២៤

**៨%** បុគ្គលិកស្ត្រីដែលត្រូវបានតម្លើងតំណែង
កើនពី ៧% ក្នុងឆ្នាំ២០២៤





## យុទ្ធសាស្ត្របម្រែបម្រួលអាកាសធាតុ

យើងប្តេជ្ញាចិត្តក្នុងការគាំទ្រដល់ការផ្លាស់ប្តូររបស់កម្ពុជា ទៅកាន់សេដ្ឋកិច្ចអព្យាក្រិតកាបូន នៅឆ្នាំ ២០៥០។ កិច្ចការនេះរួមបញ្ចូលទាំងការគ្រប់គ្រងហានិភ័យ និងឱកាសដែលកើតចេញពីការប្រែប្រួលអាកាសធាតុ ការលើកកម្ពស់ការយល់ដឹងដល់អតិថិជនរបស់យើង និងការតស៊ូមតិ ដើម្បីឱ្យមានការផ្លាស់ប្តូរមួយប្រកបដោយបរិយាប័ន្ន។

# ការគ្រប់គ្រងហានិភ័យអាកាសធាតុ និងការផ្តល់ឥណទានប្រកបដោយនិរន្តរភាព

ការប្រែប្រួលអាកាសធាតុ កំពុងបង្កឱ្យមានហានិភ័យរូបវន្ត និងហានិភ័យនៃការផ្លាស់ប្តូរកាន់តែខ្លាំងឡើងសម្រាប់ ហ្វឹស ហ្វាយនែន និងសហគមន៍ដែលយើងបម្រើ។ គ្រោះទឹកជំនន់ កម្តៅខ្លាំង និងព្រឹត្តិការណ៍អាកាសធាតុធ្ងន់ធ្ងរផ្សេងៗ អាចប៉ះពាល់ដល់ទ្រព្យសម្បត្តិលំនៅឋាន និងភាពធន់របស់គ្រួសារ ជាពិសេសនៅតាមតំបន់ជនបទ និងតំបន់ជាយក្រុង ដែលជាកន្លែងអតិថិជនរបស់យើងភាគច្រើនរស់នៅ។ ទន្ទឹមនឹងនេះដែរ ការរំពឹងទុកលើនិរន្តរភាពដែលកំពុងរីកឡូតាល់ បានបង្កើតឱកាសក្នុងការគាំទ្រដល់ដំណោះស្រាយលំនៅឋានដែលមានភាពធន់ជាងមុន និងមានការទទួលខុសត្រូវចំពោះបរិស្ថាន។

ហ្វឹស ហ្វាយនែន គ្រប់គ្រងហានិភ័យពាក់ព័ន្ធនឹងអាកាសធាតុ និងបរិស្ថាន តាមរយៈការពង្រឹងភាពធន់នៃផលប័ត្រឥណទាន ការបញ្ជ្រាបការពិចារណាលើនិរន្តរភាពទៅក្នុងសេចក្តីសម្រេចចិត្តផ្តល់កម្ចី និងការកែលម្អប្រសិទ្ធភាពប្រតិបត្តិការ។ សកម្មភាពទាំងនេះជួយគាំទ្រដល់គុណភាពទ្រព្យសម្បត្តិក្នុងរយៈពេលវែង ស្ថិរភាពហិរញ្ញវត្ថុ និងកំណើនប្រកបដោយបរិយាប័ន្ន និងភាពធន់នឹងអាកាសធាតុនៅទូទាំងប្រទេសកម្ពុជា។

សកម្មភាពផ្តល់ឥណទានរបស់យើង ត្រូវបានដឹកនាំដោយក្របខណ្ឌ ESG ដ៏ទូលំទូលាយ គោលនយោបាយគ្រប់គ្រងសមិទ្ធផលបរិស្ថាន និងសង្គម ប្រព័ន្ធគ្រប់គ្រងបរិស្ថាន និងសង្គម (ESMS) និងគោលនយោបាយឥណទានដទៃទៀត។ ទោះបីជាផលប័ត្ររបស់យើងមានផលប៉ះពាល់បរិស្ថានដោយផ្ទាល់ក្នុងកម្រិតមានដែនកំណត់ក៏ដោយ ក៏យើងបានកំណត់ប្រមាណ ៧៦% នៃកម្ចីសរុប រួមមាន៖ កម្ចីជួសជុលលំនៅឋាន កម្ចីអចលនទ្រព្យធានា កម្ចីទិញដី និងកម្ចីអាជីវកម្មខ្នាតតូចក្នុងចំណាត់ថ្នាក់ថាជាប្រភេទដែលមានហានិភ័យបរិស្ថានទាប។ ការវាយតម្លៃហានិភ័យបរិស្ថាន ត្រូវបានអនុវត្តសម្រាប់រាល់កម្ចីថ្មីទាំងអស់ ព្រមទាំងមានការតាមដានជាទៀងរាល់ឆ្នាំសម្រាប់ទំហំឥណទានដែលលើសពី ៣០,០០០ ដុល្លារអាមេរិក។

ក្នុងឆ្នាំ ២០២៥ ២៩% នៃផលប័ត្រឥណទានសរុប ត្រូវបានវាយតម្លៃឡើងវិញ ដើម្បីពិនិត្យលើហានិភ័យបរិស្ថាន និងអាកាសធាតុ ដែលប៉ះពាល់ដល់ប្រភពចំណូល និងទ្រព្យបញ្ចាំជាលំនៅឋានរបស់អតិថិជន រួមទាំងការពិនិត្យថា តើសកម្មភាពបង្កើតចំណូលទាំងនោះអាចមានផលប៉ះពាល់អវិជ្ជមានដល់បរិស្ថានដែរឬទេ។ ការពិនិត្យឡើងវិញនេះ បានរកឃើញថាមិនមានហានិភ័យរូបវន្តពីអាកាសធាតុណាមួយ ដែលជះឥទ្ធិពលជាដុំកំភួនដល់ចំណូល ឬទ្រព្យសម្បត្តិរបស់អតិថិជននោះទេ។ ទន្ទឹមនឹងនេះ ហ្វឹស ហ្វាយនែន នៅតែបន្តតាមដានការប្រើប្រាស់ថាមពលផ្ទៃក្នុង ធៀបនឹងមូលដ្ឋានដែលបានកំណត់ ដើម្បីតាមដានវឌ្ឍនភាពឆ្ពោះទៅរកគោលដៅនិរន្តរភាពរបស់ខ្លួន។

### ផលប៉ះពាល់អវិជ្ជមានដល់បរិស្ថាន ដែលបណ្តាលមកពីការប្រើប្រាស់ប្រាក់កម្ចី

| គោលបំណងកម្ចី | ចំនួនកម្ចី | ផលប៉ះពាល់បរិស្ថានពីការប្រើប្រាស់កម្ចី |
|---|---|---|
| កម្ចីលំនៅឋាន (កម្ចីយកសាងសង់ផ្ទះ) | ១.៨០១ | ស្ថិតក្នុងហានិភ័យកម្រិតមធ្យម ពាក់ព័ន្ធនឹងកាកសំណល់ពីការងារសំណង់ ការប្រើថាមពល បរិយាកាសការងារ គ្រោះថ្នាក់បុគ្គល |
| កម្ចីកែលម្អរលំនៅឋាន<br>កម្ចីទ្រព្យធានា<br>កម្ចីទិញដៅលំនៅឋាន<br>កម្ចីបង្កើនចំណូល (កម្ចីអាជីវកម្មខ្នាតតូច) | ១០.៣០៨ | ហានិភ័យកម្រិតទាប |

### ផលប៉ះពាល់អវិជ្ជមានដល់បរិស្ថាន ដែលបណ្តាលមកពីប្រភពចំណូល

| ផលប៉ះពាល់ | ចំនួនកម្ចី | កម្រិតហានិភ័យ |
|---|---|---|
| បរិស្ថាន | ១១ | ត្រូវបានកំណត់ស្ថិតក្នុងហានិភ័យកម្រិតទាប |
| បរិស្ថាន និងសុខភាព | ៥ | ត្រូវបានកំណត់ស្ថិតក្នុងហានិភ័យកម្រិតទាប |












## ការគ្រប់គ្រងផលប៉ះពាល់បរិស្ថាននៃប្រតិបត្តិការរបស់យើង

ហ្វឹស ហ្វាយនែន បន្តកាត់បន្ថយផលប៉ះពាល់ដល់បរិស្ថាន តាមរយៈការដាក់បញ្ចូលនូវការអនុវត្តប្រកបដោយចីរភាពទៅក្នុងប្រតិបត្តិការស្នូលរបស់ខ្លួន។ ដើម្បីកាត់បន្ថយការបំភាយឧស្ម័ន និងកាកសំណល់ យើងបានអនុវត្តការកែច្នៃសំណល់អេឡិចត្រូនិកជាប្រព័ន្ធ រួមមានសម្ភារចំនួន ៧៩ ឯកតា ដូចជាអាគុយ UPS អេក្រង់កុំព្យូទ័រ ម៉ាស៊ីនបោះពុម្ព និង CPU ជាដើម។ នៅក្នុងឆ្នាំ ២០២៥ យើងក៏បានបោះជំហានមួយទៀតឆ្ពោះទៅរកការដឹកជញ្ជូនដែលកាន់តែមានភាពបៃតង ដោយបានបន្ថែមរថយន្តអគ្គិសនី (EV) ដំបូងគេមួយទៅក្នុងបញ្ជីយានយន្តរបស់គ្រឹះស្ថាន ព្រមទាំងបន្តរក្សានូវវិន័យក្នុងការកម្រិតការធ្វើដំណើរតាមផ្លូវអាកាសដែលមិនចាំបាច់។

ក្រៅពីប្រតិបត្តិការផ្ទាល់ខ្លួន យើងក៏បានលើកកម្ពស់ការយល់ដឹងអំពីបរិស្ថានក្នុងចំណោមបុគ្គលិក និងអតិថិជនផងដែរ។ តាមរយៈបណ្តាញឌីជីថលរបស់យើង យើងបានចែករំលែកមាតិកាអប់រំស្តីពីការគ្រប់គ្រងកាកសំណល់ក្នុងគ្រួសារ និងការសន្សំសំចៃថាមពល។ ការផ្សព្វផ្សាយនេះត្រូវបានពង្រឹងបន្ថែមទៀតតាមរយៈការចែកជូននូវស្ទីគ័រណែនាំចំនួន ១០,០០០ សន្លឹកដល់អតិថិជន និងការរៀបចំវគ្គបណ្តុះបណ្តាលស្តីពីចីរភាពប្រចាំឆ្នាំជាកាតព្វកិច្ចសម្រាប់បុគ្គលិកទាំងអស់ ដែលជួយបណ្តុះស្មារតីទទួលខុសត្រូវចំពោះបរិស្ថាននៅទូទាំងបណ្តាញប្រតិបត្តិការរបស់យើង។

ទោះបីជាការប្រើប្រាស់ថាមពលសរុបមានការកើនឡើង ស្របទៅនឹងការរីកចម្រើនយ៉ាងឆាប់រហ័សនៃអាជីវកម្មក្នុងចន្លោះឆ្នាំ ២០២២ ដល់ ២០២៥ ក៏ដោយ ក៏យើងនៅតែរក្សាការយកចិត្តទុកដាក់ខ្ពស់លើប្រសិទ្ធភាពនៃការប្រើប្រាស់។ សន្ទស្សន៍អាំងតង់ស៊ីតេថាមពលរបស់យើងនៅតែមានស្ថិរភាព ឬមានភាពប្រសើរឡើង ដែលធានាបានថាការប្រើប្រាស់ថាមពលក្នុងមួយផលិតផល និងសេវាកម្ម ត្រូវបានធ្វើឱ្យប្រសើរឡើងបំផុតតាមបទដ្ឋានដែលបានកំណត់។

→ សូមស្វែងយល់បន្ថែមអំពីអត្ថបទលើការយល់ដឹងពីបរិស្ថានលើ www.firstfinance.com.kh/resources-tips

## សកម្មភាពនៃការប្រើប្រាស់ថាមពល

| សមាសធាតុ | ខ្នាត | ២០២៥ | ២០២៤ | ២០២៣ |
|---|---|---|---|---|
| ការប្រើប្រាស់ថាមពលដោយផ្ទាល់ | | | | |
| សាំង | លីត្រ | ២២១.៧៣៥ | ១៥៦.៩២១ | ១២៦.៨៦៦ |
| ម៉ាស៊ូត (ម៉ាស៊ីនភ្លើង) | លីត្រ | ០ | ០ | ០ |
| ការប្រើប្រាស់ថាមពលតាមរយៈការទិញបន្ត | | | | |
| ការទិញអគ្គីសនីប្រើប្រាស់ | គីឡូវ៉ាត់ម៉ោង | ២៨៥.១១១ | ២៥៩.២៣៨ | ២៣៧.៦៤២ |
| ការទិញទឹកប្រើប្រាស់ | ម៉ែត្រគូប | ១៣.៤៦៤ | ៤.៧១២ | ៣.៣១២ |
| ការទិញក្រដាស់ប្រើប្រាស់ | គក | ២.៨២៥ | ១.៦៨៧ | ៣.៣១២ |
| ការប្រើប្រាស់ថាមពលដោយប្រយោល | | | | |
| ការធ្វើដំណើរធុរកិច្ច - តាមម៉ូតូ | គម | មិនបានវាស់វែង | មិនបានវាស់វែង | មិនបានវាស់វែង |
| ការធ្វើដំណើរធុរកិច្ច - តាមរថយន្ត | គម | មិនបានវាស់វែង | មិនបានវាស់វែង | មិនបានវាស់វែង |
| ការធ្វើដំណើរធុរកិច្ច - តាមយន្តហោះ | គម | ០ | ០ | ១,០៨៨ |
| បុគ្គលិកធ្វើដំណើរទៅធ្វើការ | គម | ២.២៧៣.៥៥០ | មិនបានវាស់វែង | មិនបានវាស់វែង |

## ការបញ្ចេញឧស្ម័នផ្ទះកញ្ចក់សរុប

| វិសាលភាព | ខ្នាត | ២០២៥ | ២០២៤ | ២០២៣ |
|---|---|---|---|---|
| ការប្រើប្រាស់ថាមពលដោយផ្ទាល់ | តោន | ៣៨៧,០០ | ២៧៤,០០ | ២២១,០០ |
| សាំង | តោន | ៣៨៧,០០ | ២៧៤,០០ | ២២១,០០ |
| ម៉ាស៊ូត (ម៉ាស៊ីនភ្លើង) | តោន | ០ | ០ | ០ |
| ការប្រើប្រាស់ថាមពលតាមរយៈការទិញបន្ត | តោន | ១៧២,៦៩ | ១៥៣,៤១ | ១៤២,២៥ |
| ការទិញអគ្គីសនីប្រើប្រាស់ | តោន | ១៦៥,៤៥ | ១៥០,២៤ | ១៣៧,៩១ |
| ការទិញទឹកប្រើប្រាស់ | តោន | ៤,៦៣ | ១,៦២ | ១,៣០ |
| ការទិញក្រដាស់ប្រើប្រាស់ | តោន | ២,៦០ | ១,៥៥ | ៣,០៤ |
| ការប្រើប្រាស់ថាមពលដោយប្រយោល | តោន | ១៩១ | - | ០,០៧៥ |
| ការធ្វើដំណើរធុរកិច្ច - តាមម៉ូតូ | តោន | មិនបានវាស់វែង | មិនបានវាស់វែង | មិនបានវាស់វែង |
| ការធ្វើដំណើរធុរកិច្ច - តាមរថយន្ត | តោន | មិនបានវាស់វែង | មិនបានវាស់វែង | មិនបានវាស់វែង |
| ការធ្វើដំណើរធុរកិច្ច - តាមយន្តហោះ | តោន | 0 | 0 | ០,០៧៥ |
| បុគ្គលិកធ្វើដំណើរទៅធ្វើការ | តោន | ១៩១ | មិនហានវាស់វងៃ | មិនហានវាស់វងៃ |
| **បរិមាណឧស្ម័នផ្ទះកញ្ចក់សរុប** | | **៧៥០,៦៩** | **៤២៧,៤១** | **៣៦៣,៣២** |



## ការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ក្នុងមួយអតិថិជន

| វិសាលភាព | ខ្នាត | ២០២៥ | ២០២៤ | ២០២៣ |
|---|---|---|---|---|
| | ចំនួនអតិថិន | **១១.៨៤៧** | **៩.២៤៥** | **៦.៥៧៨** |
| ការប្រើប្រាស់ថាមពលដោយផ្ទាល់ | តោន | ០,០៣២៧ | ០,០២៩៦ | ០,០៣៣៦ |
| សាំង | តោន | ០,០៣២៧ | ០,០២៩៦ | ០,០៣៣៦ |
| ម៉ាស៊ូត (ម៉ាស៊ីនភ្លើង) | តោន | ០ | ០ | ០ |
| ការប្រើប្រាស់ថាមពលតាមរយៈការទិញបន្ត | តោន | ០,០១៤៦ | ០,០១៦៦ | ០,០២១៦ |
| ការទិញអគ្គីសនីប្រើប្រាស់ | តោន | ០,០១៤០ | ០,០១៦៣ | ០,០២១០ |
| ការទិញទឹកប្រើប្រាស់ | តោន | ០,០០០៤ | ០,០០០២ | ០,០០០២ |
| ការទិញក្រដាស់ប្រើប្រាស់ | តោន | ០,០០០២ | ០,០០០២ | ០,០០០៥ |
| ការប្រើប្រាស់ថាមពលដោយប្រយោល | តោន | ០,០១៦១ | - | - |
| ការធ្វើដំណើរធុរកិច្ច - តាមម៉ូតូ | តោន | មិនបានវាស់វែង | មិនបានវាស់វែង | មិនបានវាស់វែង |
| ការធ្វើដំណើរធុរកិច្ច - តាមរថយន្ត | តោន | មិនបានវាស់វែង | មិនបានវាស់វែង | មិនបានវាស់វែង |
| ការធ្វើដំណើរធុរកិច្ច - តាមយន្តហោះ | តោន | 0 | 0 | ០ |
| បុគ្គលិកធ្វើដំណើរទៅធ្វើការ | តោន | ០,០១៦១ | មិនបានវាស់វែង | មិនបានវាស់វែង |
| **បរិមាណឧស្ម័នផ្ទះកញ្ចក់សរុប** | | **០,០៦៣** | **០,០៤៦** | **០,០៥៥** |

ធៀបនឹងឆ្នាំ ២០២៤ ការបញ្ចេញឧស្ម័នផ្ទះកញ្ចក់សរុប ក្នុងអតិថិជនម្នាក់ក្នុងឆ្នាំ ២០២៥ មានការកើនឡើង។ ការកើនឡើងនេះកើតឡើងដោយសារតែយើងបានពង្រីកវិសាលភាពនៃការគណនា ដោយរួមបញ្ចូលទាំងការធ្វើដំណើររបស់បុគ្គលិកមករកកន្លែងការងារផងដែរ។

# របាយការណ៍បរិស្ថាន សង្គម និងអភិបាលកិច្ច

## ផ្នែកសង្គម

| UN SDGs ដែលពាក់ព័ន្ធ | ការវាស់វែង | សមិទ្ធផលឆ្នាំ ២០២៥ |
|---|---|---|
| | **បរិយាបន្នហិរញ្ញវត្ថុ/ចំណេះដឹងហិរញ្ញវត្ថុ និងចំណេះលើសិទ្ធិអចលនទ្រព្យសម្រាប់អ្នកមានផ្ទះជាកម្មសិទ្ធិលើកដំបូង** | • ៥១,១% នៃអតិថិជនមានចំណូលក្រោម ៣០០ដុល្លារ ក្នុង១ខែ<br>• ៩០,៩% នៃអតិថិជនគឺជាស្ត្រី<br>• ៧៤,៣% នៃអតិថិជន គឺអ្នកដែលមានផ្ទះដំបូង<br>• ៥០,៦% នៃអតិថិជនដែលប្រើកម្ចីកែលម្អលំនៅឋានមានលទ្ធភាពទទួលបានទឹកស្អាតប្រើ និងមានអនាម័យក្នុងការរស់នៅ<br>• អត្ថបទខ្លីៗ ចំនួន ៣៥៩ ស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុផ្ទាល់ខ្លួន និងសិទ្ធិក្នុងការគ្រប់គ្រងអចលនទ្រព្យត្រូវបានផ្សាយលើបណ្តាញសង្គម |
| | **ប្តេជ្ញាក្លាយជាក្រុមហ៊ុនដែលគេចង់ធ្វើការជាមួយ**<br>ការងារបុគ្គលិក | • កម្រិតពេញចិត្តបុគ្គលិក៖ ៨០%<br>• បណ្តឹងតវ៉ាពាក់ពន្ធ័ការរើសអើងពលកម្ម ផ្តល់តម្លៃបុគ្គលិក ឬហឹង្សាដែលនាំឱ្យមានបណ្តឹង៖០<br>• កម្រិតរក្សាបុគ្គលិក៖ ៦៥%<br>• ជ្រើសរើសបុគ្គលិកខាងក្នុង៖ ២៦%<br>• ចំនួនម៉ោងបណ្តុះបណ្តាលសម្រាប់បុគ្គលិកម្នាក់ក្នុងមួយឆ្នាំ ៖ ៥៣,២ម៉ោង |
| | សុវត្ថិភាព និងសុខមាលភាព | • ស្លាប់៖ ០<br>• សម្រាកក្នុងមន្ទីរពេទ្យ៖ ៣<br>• ព្យាបាលដោយថ្នាំ៖ ០<br>• សង្គ្រោះបឋម៖ ០<br>• អាទិភាពគ្រោះថ្នាក់ខ្ពស់៖ គ្មានកំណត់ត្រា |
| | **លើកស្ទួយសុខមាលភាពសង្គមការយល់ដឹងអំពីកិច្ចការពារបរិស្ថាន និងកិច្ចការងារសង្គម** | • ចំនួនគម្រោង៖ ៨<br>• អ្នកទទួលផលពីគម្រោង៖ ៥,៤៤១<br>• ចំនួនម៉ោងបុគ្គលិកស្ម័គ្រចិត្ត[១]៖ ១.៤៩៦ |
| | **គោរពសិទ្ធិមនុស្ស និងភាពចម្រុះ** | • ស្ត្រីក្នុងតំណែងគណៈគ្រប់គ្រង៖ ១១%<br>• ស្ត្រីក្នុងតំណែងក្រុមប្រឹក្សាភិបាល៖ ០%<br>• កម្ចីថ្មីដែលបានវាយតម្លៃអំពីពលកម្មកុមារ និងធ្វើការដោយបង្ខំ ធៀបបញ្ជីមុខរបរដែលមិនផ្តល់កម្ចី៖ ១០០% |



## ផ្នែកបរិស្ថាន

| UN SDGs ដែលពាក់ព័ន្ធ | ការវាស់វែង | សមិទ្ធផលឆ្នាំ ២០២៥ |
|---|---|---|
| | **បម្រែបម្រួលបរិយាកាស[២]**<br>ការប្រើប្រាស់ថាមពលដោយផ្ទាល់ | • ចំណុះសាំង៖ ១៧.៩លីត្រ |
| | ការប្រើប្រាស់ថាមពលដោយប្រយោល | • ថាមពលអគ្គីសនី៖ ២២,៦គីឡូវ៉ាត់ម៉ោង<br>• ទឹក៖ ០,៩៣ ម៉ែត្រគូប<br>• ក្រដាស៖ ០,២២ គីឡូក្រាម |
| | ការប្រើប្រាស់ថាមពលដោយប្រយោល | • ការធ្វើដំណើរតាមយន្តហោះ៖ ០<br>• បុគ្គលិកធ្វើដំណើរមកកន្លែងធ្វើការ៖ ១៩២គីឡូម៉ែត្រ |

## ផ្នែកអភិបាលកិច្ច/សេដ្ឋកិច្ច

| UN SDGs ដែលពាក់ព័ន្ធ | ការវាស់វែង | សមិទ្ធផលឆ្នាំ ២០២៥ |
|---|---|---|
| | **ប្រកាន់ខ្ជាប់អតិថិជនជាគោល ដោយផ្តល់នូវសេវាដែលមាន គុណភាពទៅដល់អតិថិជន** | • កម្រិតសុទ្ធៈអតិថិជន[៣]៖ ៦៨,៦%<br>• រក្សាអនុបាតបញ្ហានិងបណ្តឹងធៀបនឹងប្រតិបត្តិការរបស់អតិថិជន៖ ០,២%<br>• កម្រិតថែរក្សាអតិថិជន៖ ៩៨,៦% |
| | **ធានាថាប្រតិបត្តិការអាជីវកម្ម ស្ថិត នៅក្រោមការអនុវត្តអភិបាលកិច្ចល្អ ព្រមជាមួយការពង្រឹងលើកិច្ចការពារអតិថិជន** | • មិនមានការព្រមានគួរឱ្យកត់សម្គាល់ពីនិយ័តករ[៤]៖ ០<br>• មិនមានសញ្ញាបង្ហាញពីភាពមិនអនុលោម៖ ០<br>• វិញ្ញាបនបត្រកម្រិតខ្ពស់ស្តីពីគោលការណ៍ការពារអតិថិជន៖ កម្រិតមាស<br>• វិញ្ញាបនបត្រអនុលោមភាពសារពើរពន្ធ៖ កម្រិតមាស |

១ * បំប្លែងការបរិច្ចាគជាសាច់ប្រាក់របស់បុគ្គលិក ឱ្យទៅជាម៉ោងការងារស្ម័គ្រចិត្ត (ការបរិច្ចាគសាច់ប្រាក់សរុប ចែកនឹង កម្រៃពលកម្មមធ្យមសរុបក្នុងមួយម៉ោង

២ រូបមន្តនេះត្រូវបានផ្លាស់ប្តូរពីការប្រើប្រាស់វត្ថុធាតុដើម ឬថាមពលក្នុងបុគ្គលិកម្នាក់ មកបរិមាណប្រើប្រាស់ក្នុងការទទួលបាន/ថែរក្សាអតិថិជនម្នាក់ ក្នុងមួយឆ្នាំ ។ ហេតុដូចនេះលោក លោកស្រី អាចមើលឃើញខុសគ្នាធៀបនឹងរបាយការណ៍ឆ្នាំមុនៗ

៣ ពិន័យគួរឱ្យកត់សម្គាល់គឺជាការពិន័យ ឬដាក់ទោសទណ្ឌដែលចេញដោយធនាគារជាតិ ឬនិយ័តដែលពាក់ព័ន្ធផ្សេងទៀត

## ផ្នែកអភិបាលកិច្ច/សេដ្ឋកិច្ច

| UN SDGs ដែលពាក់ព័ន្ធ | ការវាស់វែង | សមិទ្ធផលឆ្នាំ ២០២៥ |
|---|---|---|
| 16 PEACE, JUSTICE AND STRONG INSTITUTIONS; 12 RESPONSIBLE CONSUMPTION AND PRODUCTION; 13 CLIMATE ACTION | **មានគោលនយោបាយដើម្បីគាំពារដល់កិច្ចការនិរន្តរភាព និងអាជីវកម្ម** | **ធ្វើបច្ចុប្បន្នភាព**<br>• គោលនយោបាយ បរិស្ថាន សង្គម និង អភិបាលកិច្ច<br>• គោលនយោបាយគ្រប់គ្រងបណ្តឹងអតិថិជន<br>**គោលនយោបាយថ្មី**<br>• គោលនយោបាយប្រព័ន្ធគ្រប់គ្រង បរិស្ថាន និង សង្គម<br>• គោលនយោបាយសេវាកម្មអតិថិជន<br>• នីតិវិធីលទ្ធកម្ម<br>• គោលនយោបាយ និងនីតិវិធីជ្រើសរើសភាគីទីបី |
| | **ធានាថាហានិភ័យដែលពាក់ព័ន្ធ បរិស្ថាន សង្គម និងអភិបាលកិច្ច ត្រូវបានគ្រប់គ្រងប្រកបដោយប្រសិទ្ធភាព** | • កម្ចីថ្មីដែលត្រូវបានវាយតម្លៃអំពីផលប៉ះពាល់ បរិស្ថាន និងសង្គមយោងតាមបញ្ជីលើកលែងការផ្តល់កម្ចី៖ ១០០%<br>• %កម្ចីដែលមានស្រាប់ត្រូវបានវាយតម្លៃឡើងវិញលើចំណូលរបស់អតិថិជនពីផលប៉ះពាល់ បរិស្ថាន និងសង្គម៖ ២៩%<br>• %នៃអ្នកផ្គត់ផ្គង់ដែលបានទទួលដឹងលឺពីក្រមសីលធម៌របស់អ្នកផ្គត់ផ្គង់ពាក់ព័ន្ធនឹងបញ្ហាសង្គមដូចជាពលកម្ម និងសិទ្ធិមនុស្ស៖ ១០០%[៤] |

៤ ការប្តេជ្ញាលើកិច្ចការប្រឆាំងនឹងពលកម្មកុមារ ការធ្វើការដោយបង្ខំ និងការប្រើប្រាស់សារធាតុ អាសបេស្ទ ត្រូវបានបញ្ចូលទៅក្នុងកិច្ចសន្យារវាងអ្នកម៉ៅការសំណង់ និងក្រុមហ៊ុនតុបតែងលម្អ





# អភិបាលកិច្ច វប្បធម៌ និងគណនេយ្យភាព

យើងមានគោលដៅគ្រប់គ្រងអាជីវកម្មរបស់យើងប្រកបដោយការទទួលខុសត្រូវជាមួយនឹងវប្បធម៌ដែលតម្រូវឱ្យយើងធ្វើនូវអ្វីដែលត្រឹមត្រូវ ដើម្បីឆ្លើយតបទៅនឹងការរំពឹងទុករបស់អតិថិជន និងសហគមន៍ ព្រមទាំងកាតព្វកិច្ចផ្នែកបទប្បញ្ញត្តិផងដែរ។

# ការប្តេជ្ញាចិត្តចំពោះហិរញ្ញវត្ថុប្រកបដោយក្រមសីលធម៌ និងការទទួលខុសត្រូវ



នៅក្នុងឆ្នាំ ២០២៥ ហ្វឹស ហ្វាយនែន បានពង្រឹងភាពជាអ្នកដឹកនាំរបស់ខ្លួនក្នុងវិស័យហិរញ្ញវត្ថុប្រកបដោយក្រមសីលធម៌ និងការទទួលខុសត្រូវនៅក្នុងប្រទេសកម្ពុជា តាមរយៈការសម្រេចបាននូវសមិទ្ធផលសំខាន់ៗចំនួនពីរ៖ ការបន្តទទួលបានវិញ្ញាបនបត្រការពារអតិថិជនកម្រិតមាស និងការទទួលបានលទ្ធផលយ៉ាងល្អប្រសើរក្នុងការវាយតម្លៃក្រមសីលធម៌ប្រតិបត្តិ ជាលើកដំបូង។

នៅថ្ងៃទី ១២ ខែឧសភា ឆ្នាំ ២០២៥ ហ្វឹស ហ្វាយនែន ត្រូវបានផ្តល់វិញ្ញាបនបត្រការពារអតិថិជនកម្រិតមាស សម្រាប់អាណត្តិទីពីរជាប់ៗគ្នា ដោយទទួលបានពិន្ទុរហូតដល់ ៩៩,១%។ វិញ្ញាបនបត្រនេះត្រូវបានផ្តល់ដោយស្ថាប័ន M-CRIL បន្ទាប់ពីការវាយតម្លៃយ៉ាងតឹងរ៉ឹងលើអនុលោមភាពរបស់ ហ្វឹស ហ្វាយនែន ធៀបនឹងស្តង់ដារការពារអតិថិជនដែលត្រូវបានទទួលស្គាល់ជាសកល រួមមាន៖ ការការពារការជំពាក់បំណុលលើសលប់ ការកំណត់តម្លៃប្រកបដោយយុត្តិធម៌ និងតម្លាភាព ការរចនា និងការផ្តល់ផលិតផលប្រកបដោយការទទួលខុសត្រូវ ការការពារឯកជនភាពទិន្នន័យ ការដោះស្រាយបណ្តឹងតវ៉ាប្រកបដោយប្រសិទ្ធភាព និងក្រមសីលធម៌របស់បុគ្គលិក។ ការទទួលស្គាល់នេះឆ្លុះបញ្ចាំងពីការប្តេជ្ញាចិត្តឥតឈប់ឈររបស់ស្ថាប័ន ក្នុងការយកអតិថិជនជាចំណុចស្នូលនៃប្រតិបត្តិការរបស់ខ្លួន និងការប្រកាន់ខ្ជាប់នូវស្តង់ដារខ្ពស់នៃសុចរិតភាព និងតម្លាភាព។

ទន្ទឹមនឹងនេះ ហ្វឹស ហ្វាយនែន ក៏សម្រេចបានពិន្ទុ "ល្អណាស់" រហូតដល់ ៩៨,៨% ក្នុងការវាយតម្លៃក្រមសីលធម៌ប្រតិបត្តិជាលើកដំបូងបំផុត ដែលធ្វើឱ្យស្ថាប័ននេះក្លាយជាអ្នកចូលរួមដំបូងគេក្នុងគំនិតផ្តួចផ្តើមថ្នាក់ជាតិ ដែលគាំទ្រដោយធនាគារជាតិនៃកម្ពុជា (NBC) សមាគមធនាគារនៅកម្ពុជា (ABC) សមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា (CMA) និង Cerise+SPTF។ ការវាយតម្លៃដែលធ្វើឡើងដោយ M-CRIL នេះ បានពិនិត្យលើស្ថាប័ននានាធៀបនឹងស្តង់ដារជាក់លាក់សម្រាប់ប្រទេសកម្ពុជា ដែលផ្តោតលើការកំណត់តម្លៃដោយយុត្តិធម៌ ការរចនាផលិតផលប្រកបដោយការទទួលខុសត្រូវ ឯកជនភាពទិន្នន័យ ការដោះស្រាយបណ្តឹងតវ៉ា ការប្រព្រឹត្តចំពោះអតិថិជនប្រកបដោយក្រមសីលធម៌ អភិបាលកិច្ចល្អ និងក្រមសីលធម៌បុគ្គលិក។

សមិទ្ធផលទាំងនេះសបញ្ជាក់ជាថ្មីនូវការប្តេជ្ញាចិត្តយ៉ាងស៊ីជម្រៅរបស់ ហ្វឹស ហ្វាយនែន ចំពោះស្តង់ដារក្រមសីលធម៌ និងការអនុវត្តហិរញ្ញវត្ថុប្រកបដោយការទទួលខុសត្រូវ ដោយបង្កើតឱ្យមាននូវស្តង់ដារគំរូសម្រាប់ប្រតិបត្តិការស្ថាប័ន និងការការពារអតិថិជននៅក្នុងប្រទេសកម្ពុជា។ ក្នុងនាមជាគ្រឹះស្ថានឯកទេសផ្តល់ហិរញ្ញប្បទានលំនៅឋានតម្លៃសមរម្យដែលមានអាជ្ញាប័ណ្ណតែមួយគត់នៅកម្ពុជា ហ្វឹស ហ្វាយនែន នៅតែបន្តប្តេជ្ញាកសាងប្រព័ន្ធអេកូឡូស៊ីហិរញ្ញប្បទានលំនៅឋានប្រកបដោយចីរភាព និងបរិយាប័ន្ន ព្រមទាំងពង្រឹងទំនុកចិត្តក្នុងចំណោមអតិថិជន និយតករ ដៃគូ និងវិនិយោគិន។

## ហ្វឹស ហ្វាយនែន ទទួលបានវិញ្ញាបនបត្រអនុលោមភាពសារពើពន្ធកម្រិត “មាស” ដ៏មានកិត្យានុភាព

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ហ្វឹស ហ្វាយនែន ភីអិលស៊ី មានមោទនភាពដែលទទួលបាន "វិញ្ញាបនបត្រអនុលោមភាពសារពើពន្ធប្រភេទមាស (Gold)" ពីអគ្គនាយកដ្ឋានពន្ធដារ ដែលមានសុពលភាពសម្រាប់ឆ្នាំពន្ធ ២០២៥ និង ២០២៦។

ការទទួលស្គាល់ដ៏ខ្ពង់ខ្ពស់នេះ ឆ្លុះបញ្ចាំងពីការប្តេជ្ញាចិត្តឥតងាករេរបស់យើង ចំពោះតម្លាភាពនៃរបាយការណ៍ ការអនុវត្តយ៉ាងម៉ឺងម៉ាត់តាមបទប្បញ្ញត្តិច្បាប់ និងស្តង់ដារខ្ពស់បំផុតនៃទំនួលខុសត្រូវក្នុងនាមជាក្រុមហ៊ុនធុរកិច្ច។ វាក៏បានបញ្ជាក់យ៉ាងច្បាស់ពីការយកចិត្តទុកដាក់របស់យើងលើអភិបាលកិច្ចល្អ និងជួយពង្រឹងទំនុកចិត្តពីសំណាក់និយតករ ដៃគូពាក់ព័ន្ធ និងភាគីពាក់ព័ន្ធទាំងអស់មកលើ ហ្វឹស ហ្វាយនែន។



→ សូមស្វែងយល់បន្ថែមអំពីគោលការការពារអតិថិជនលើ www.m-cril.com

→ សូមស្វែងយល់បន្ថែមអំពីក្រមសីលធម៌របស់ស្ថាប័នធនាគារ និងហិរញ្ញវត្ថុនៅលើ www.firstfinance.com.kh/code-of-conduct







# ការគ្រប់គ្រងហានិភ័យរបស់យើងខ្ញុំ

# ទិដ្ឋភាពទូទៅនៃការគ្រប់គ្រងហានិភ័យ

នៅហ្វីស ហ្វាយនែន ការគ្រប់គ្រងហានិភ័យគឺជាសសរស្តម្ភស្នូលនៃយុទ្ធសាស្ត្រ និងការសម្រេចចិត្តរបស់យើង ដែលនឹងទ្រទ្រង់ទៅដល់និរន្តរភាពរយៈពេលវែង និងភាពធន់ផ្នែកហិរញ្ញវត្ថុរបស់ស្ថាប័ន។ ក្រៅពីការបំពេញតាមតម្រូវការបទប្បញ្ញត្តិ ក្របខណ្ឌគ្រប់គ្រងហានិភ័យរបស់យើង បានគាំទ្រដល់កំណើនប្រកបដោយវិន័យ ដោយធានាថាហានិភ័យដែលកើតចេញពីសកម្មភាពអាជីវកម្មត្រូវបានកំណត់អត្តសញ្ញាណ វាយតម្លៃ តាមដាន និងកាត់បន្ថយជាប្រព័ន្ធ។ វិធីសាស្ត្រដែលប្រកបដោយរចនាសម្ព័ន្ធនេះ អនុញ្ញាតឱ្យ ហ្វីស ហ្វាយនែន ធ្វើប្រតិបត្តិការដោយមានភាពទទួលខុសត្រូវ ព្រមទាំងបណ្ដុះវប្បធម៌ហានិភ័យយ៉ាងរឹងមាំនៅគ្រប់កម្រិតក្នុងស្ថាប័ន។

## គោលបំណង និងគោលការណ៍ណែនាំ

ក្របខណ្ឌគ្រប់គ្រងហានិភ័យរបស់យើងត្រូវបានរចនាឡើងដើម្បីរក្សាតុល្យភាពរវាងឱកាសអាជីវកម្ម និងកម្រិតហានិភ័យដែលយើងអាចទទួលយកបាន ដើម្បីគាំទ្រដល់កំណើនដែលមានស្ថិរភាព និងចីរភាព។ វាត្រូវបានដឹកនាំដោយគោលការណ៍សំខាន់ៗដូចខាងក្រោម៖

- **ការគ្រប់គ្រងហានិភ័យមានលក្ខណៈរួមបញ្ចូលគ្នា៖** ហានិភ័យត្រូវបានគ្រប់គ្រងទាំងលក្ខណៈមួយៗដាច់ដោយឡែក និងលក្ខណៈផលប័ត្រសរុប ដើម្បីធានាឱ្យមានទិដ្ឋភាពទូទៅគ្រប់ជ្រុងជ្រោយលើគ្រប់ប្រភេទហានិភ័យ។
- **ឯករាជ្យភាព និងការត្រួតពិនិត្យ៖** ការតាមដាន និងការរាយការណ៍ហានិភ័យត្រូវបានដាក់នៅដោយឯករាជ្យពីអង្គភាពអាជីវកម្ម ដើម្បីពង្រឹងការត្រួតពិនិត្យឱ្យបានហ្មត់ចត់។
- **តម្លាភាព និងគណនេយ្យភាព៖** ការសម្រេចចិត្តលើអាជីវកម្មត្រូវបានធ្វើឡើងដោយមានភាពច្បាស់លាស់អំពីហានិភ័យពាក់ព័ន្ធ ដើម្បីធានាបាននូវការសម្រេចចិត្តដែលមានព័ត៌មានគ្រប់គ្រាន់ និងមានការទទួលខុសត្រូវ។
- **ការកែលម្អជាបន្តបន្ទាប់៖** យើងពង្រឹងសមត្ថភាពគ្រប់គ្រងហានិភ័យរបស់យើងជាប្រចាំតាមរយៈការបណ្ដុះបណ្ដាល ការធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធ និងការរៀនសូត្របន្តបន្ទាប់នៅទូទាំងអង្គភាព។

តាមរយៈក្របខណ្ឌដែលមានវិន័យ និងការអភិវឌ្ឍជាបន្តបន្ទាប់នេះ ហ្វីស ហ្វាយនែន ធានាថាការគ្រប់គ្រងហានិភ័យនៅតែជាកាតាលីករយុទ្ធសាស្ត្រសម្រាប់កំណើនប្រកបដោយការទទួលខុសត្រូវ និងទំនុកចិត្តពីភាគីដែលពាក់ព័ន្ធ។

> ការគ្រប់គ្រងហានិភ័យប្រកបដោយប្រសិទ្ធភាព គឺជាការគាំទ្រដល់គោលបំណងរបស់យើងក្នុងការកសាងអនាគតដ៏ភ្លឺស្វាងសម្រាប់ទាំងអស់គ្នា។ ក្របខណ្ឌហានិភ័យដែលបានចងក្រងជាប្រព័ន្ធ និងវប្បធម៌ហានិភ័យដ៏រឹងមាំរបស់យើង ផ្ដល់អំណាចដល់បុគ្គលិកក្នុងការទទួលយកហានិភ័យដោយមានព័ត៌មានគ្រប់ជ្រុងជ្រោយ ដើម្បីបង្កើតលទ្ធផលវិជ្ជមានសម្រាប់អតិថិជន និងសហគមន៍របស់យើង។



**លោក នាង សុខឃីម**
នាយកប្រតិបត្តិគ្រប់គ្រងហានិភ័យ



## ប្រភេទហានិភ័យ និងការគ្រប់គ្រង

ហ្វីស ហ្វាយនែន កំណត់អត្តសញ្ញាណ និងគ្រប់គ្រងប្រភេទហានិភ័យចម្បងៗចំនួន ៥៖

| ប្រភេទហានិភ័យ | និយមន័យ និងវិធីសាស្ត្រគ្រប់គ្រង |
|---|---|
| ហានិភ័យឥណទាន | ការខាតបង់ដែលអាចកើតមានឡើងពីការខកខានបំពេញកាតព្វកិច្ចរបស់ដៃគូសន្យា។ គ្រប់គ្រងតាមរយៈការកំណត់កម្រិតផលិតផល ការធ្វើពិពិធកម្មផលប័ត្រ និងដំណើរការវាយតម្លៃកម្ចីយ៉ាងហ្មត់ចត់។ |
| ហានិភ័យហិរញ្ញវត្ថុ | រួមមានហានិភ័យលទ្ធភាពសង (អនុបាតដើមទុន) ហានិភ័យអត្រាការប្រាក់ និងហានិភ័យអត្រាប្ដូរប្រាក់បរទេស។ ត្រូវបានតាមដានយ៉ាងដិតដល់ដោយនាយកដ្ឋានហិរញ្ញវត្ថុ និងគណៈកម្មាធិការគ្រប់គ្រងទ្រព្យសកម្ម និងបំណុល (ALCO)។ |
| ហានិភ័យសាច់ប្រាក់ងាយស្រួល | ហានិភ័យនៃការមិនអាចបំពេញកាតព្វកិច្ចបំណុល។ យើងគ្រប់គ្រងហានិភ័យនេះតាមរយៈអនុបាតលទ្ធភាពបង់សងបំណុល (DSR) ដោយរក្សាកម្រិតសុវត្ថិភាព >120%។ |
| ហានិភ័យប្រតិបត្តិការ | ការខាតបង់អាចកើតមានឡើងពីនីតិវិធីផ្ទៃក្នុង បុគ្គលិក ប្រព័ន្ធ ឬព្រឹត្តិការណ៍ខាងក្រៅ។ កាត់បន្ថយតាមរយៈគោលការណ៍ "ត្រួតពិនិត្យទ្វេដង" (ភ្នែក ៤ គូ) និងការវាយតម្លៃដោយខ្លួនឯងលើការគ្រប់គ្រងហានិភ័យ (RCSA) ជាទៀងទាត់។ |
| ហានិភ័យអនុលោមភាព | ហានិភ័យនៃការខាតបង់ពីការរំលោភច្បាប់ ឬគោលនយោបាយផ្ទៃក្នុង។ ត្រួតពិនិត្យដោយអ្នកគ្រប់គ្រងអនុលោមភាពឯករាជ្យ ដើម្បីធានាបាននូវការអនុវត្តពេញលេញតាមស្តង់ដារបទប្បញ្ញត្តិ។ |

## អភិបាលកិច្ច និងការទទួលខុសត្រូវ៖ ខ្សែការពារបីជាន់

ដើម្បីធានាបាននូវគណនេយ្យភាពច្បាស់លាស់ ហ្វីស ហ្វាយនែន ប្រើប្រាស់គំរូអភិបាលកិច្ច "ខ្សែការពារបីជាន់"៖

| ខ្សែការពារ | មុខងារ / នាយកដ្ឋានសំខាន់ៗ | តួនាទី និងការទទួលខុសត្រូវចម្បង |
|---|---|---|
| ខ្សែការពារទី១<br>(អាជីវកម្ម និងប្រតិបត្តិការ) | • ប្រតិបត្តិការឥណទាន និងកម្ចី<br>• ប្រតិបត្តិការសាខា<br>• លក់<br>• ទីផ្សារ<br>• សេវាកម្មអតិថិជន<br>• ប្រតិបត្តិការរតនាគារ និងហិរញ្ញវត្ថុ<br>• ប្រតិបត្តិការ IT និងឌីជីថល<br>• ធនធានមនុស្ស<br>• រដ្ឋបាល និងបរិក្ខាផ្សេងៗ | • កាន់កាប់ និងគ្រប់គ្រងហានិភ័យដែលកើតចេញពីសកម្មភាពប្រចាំថ្ងៃ<br>• ធានាការអនុវត្តតាមគោលនយោបាយ នីតិវិធី និងការត្រួតពិនិត្យផ្ទៃក្នុង<br>• អនុវត្តការត្រួតពិនិត្យអតិថិជន និងការវាយតម្លៃកម្ចី<br>• តាមដានគុណភាពផលប័ត្រ និងសញ្ញាព្រមានជាមុន<br>• ការពារទ្រព្យសកម្ម និងសុចរិតភាពនៃទិន្នន័យ<br>• អនុវត្តប្រតិបត្តិការដោយត្រឹមត្រូវ និងមានសីលធម៌<br>• រាយការណ៍បញ្ហា និងបាតុភូតនានាទៅថ្នាក់លើឱ្យបានទាន់ពេលវេលា។ |

ទិដ្ឋភាពទូទៅ
សារទៅកាន់ភាគីពាក់ព័ន្ធ
បរិយាកាសអាជីវកម្ម
ការប្ដេជ្ញារបស់យើងចំពោះនិរន្តរភាព
ការគ្រប់គ្រងហានិភ័យ
របាយការណ៍ហិរញ្ញវត្ថុ

| | | |
|---|---|---|
| **ខ្សែការពារទី២**<br>(ការគ្រប់គ្រងហានិភ័យ និងអនុលោមភាព) | • នាយកដ្ឋានគ្រប់គ្រងហានិភ័យ<br>• មុខងារអនុលោមភាព<br>• ការត្រួតពិនិត្យហានិភ័យឥណទាន<br>• ការគ្រប់គ្រងហានិភ័យសហគ្រាស (ERM)<br>• អនុលោមភាព AML/CFT & ទណ្ឌកម្ម<br>• ហានិភ័យ ESG & និរន្តរភាព<br>• មុខងារច្បាប់ | • បង្កើត និងថែទាំក្របខណ្ឌ និងគោលនយោបាយគ្រប់គ្រងហានិភ័យ<br>• កំណត់កម្រិតហានិភ័យដែលទទួលយកបាន និងដែនកំណត់នានា<br>• តាមដានការអនុវត្តតាមតម្រូវការបទប្បញ្ញត្តិ និងផ្ទៃក្នុង<br>• ធ្វើការពិនិត្យហានិភ័យដោយឯករាជ្យ និងការធ្វើតេស្តភាពតានតឹង (Stress testing)<br>• ផ្តល់ការណែនាំ និងការពិនិត្យផ្ទៀងផ្ទាត់ដល់ខ្សែការពារទី១<br>• រាយការណ៍ពីស្ថានភាពហានិភ័យជូនថ្នាក់ដឹកនាំ និងក្រុមប្រឹក្សាភិបាល<br>• ធានាការអនុលោមតាមច្បាប់ បទប្បញ្ញត្តិ និងស្តង់ដាររបស់អ្នកផ្តល់ជំនួយ ឬវិនិយោគ |
| **ខ្សែការពារទី៣**<br>(ការផ្តល់ការធានាឯករាជ្យ) | • នាយកដ្ឋានសវនកម្មផ្ទៃក្នុង | • ផ្តល់ការធានាដោយឯករាជ្យលើប្រសិទ្ធភាពនៃអភិបាលកិច្ច ការគ្រប់គ្រងហានិភ័យ និងការត្រួតពិនិត្យផ្ទៃក្នុង<br>• វាយតម្លៃភាពគ្រប់គ្រាន់នៃគំរូខ្សែការពារបីជាន់<br>• ធ្វើសវនកម្មផ្អែកលើហានិភ័យនៅគ្រប់មុខងារទាំងអស់<br>• រាយការណ៍លទ្ធផលសវនកម្មដោយផ្ទាល់ជូនគណៈកម្មាធិការសវនកម្មនៃក្រុមប្រឹក្សាភិបាល<br>• តាមដានផែនការសកម្មភាពគ្រប់គ្រង និងវឌ្ឍនភាពនៃការកែលម្អ |

## គណៈកម្មាធិការគ្រប់គ្រងហានិភ័យនៃក្រុមប្រឹក្សាភិបាល

គណៈកម្មាធិការគ្រប់គ្រងហានិភ័យនៃក្រុមប្រឹក្សាភិបាល គឺជាគណៈកម្មាធិការកម្រិតក្រុមប្រឹក្សាភិបាលដែលត្រូវបានបង្កើតឡើងដើម្បីជួយដល់ក្រុមប្រឹក្សាភិបាលក្នុងការត្រួតពិនិត្យហានិភ័យ។

ការទទួលខុសត្រូវសំខាន់ៗ

- **ការគាំទ្រយុទ្ធសាស្ត្រ៖** ផ្តល់ការណែនាំដល់ក្រុមប្រឹក្សាភិបាលលើបញ្ហាគ្រប់គ្រងហានិភ័យកម្រិតខ្ពស់។
- **ការត្រួតពិនិត្យយុទ្ធសាស្ត្រ៖** ធ្វើការជាមួយនាយកប្រតិបត្តិគ្រប់គ្រងហានិភ័យ ដើម្បីកំណត់គោលដៅរយៈពេលវែង និងផែនការគ្រប់គ្រងហានិភ័យ។
- **ការពិនិត្យឡើងវិញលើគោលនយោបាយ៖** ទទួល និងពិនិត្យទទួលស្គាល់គោលនយោបាយគ្រប់គ្រងហានិភ័យ បន្ទាប់ពីការពិនិត្យដោយគណៈកម្មាធិការសវនកម្ម។
- **ការរាយការណ៍ហានិភ័យ៖** ទទួលរបាយការណ៍ពីអ្នកគ្រប់គ្រងអនុលោមភាព និង នាយកប្រតិបត្តិគ្រប់គ្រងហានិភ័យទាក់ទងនឹងហានិភ័យ និងបញ្ហាសំខាន់ៗ។
- **ការគ្រប់គ្រងវិបត្តិ៖** ពិនិត្យមើលការវិភាគនៃការធ្វើតេស្តភាពធន់ប្រចាំឆ្នាំ និងធ្វើការសម្រេចចិត្តលើការកំណត់កម្រិតហានិភ័យផ្អែកលើលទ្ធផលទាំងនោះ។
- **ការធ្វើវិសោធនកម្មគោលនយោបាយ៖** ផ្តល់អនុសាសន៍ដល់ក្រុមប្រឹក្សាភិបាលសម្រាប់ការពិនិត្យឡើងវិញឱ្យបានឆាប់ ឬការធ្វើវិសោធនកម្មលើគោលនយោបាយគ្រប់គ្រងហានិភ័យនៅពេលចាំបាច់។







# របាយការណ៍ហិរញ្ញវត្ថុ

# របាយការណ៍របស់ក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាល សូមដាក់ជូននូវរបាយការណ៍នេះព្រមជាមួយនឹងរបាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មរួចរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ហ្វីស ហ្វាយនែន ភីអិលស៊ី (ហៅកាត់ថា "ក្រុមហ៊ុន") នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2025 និងសម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់។

## សកម្មភាពអាជីវកម្មចម្បង

សកម្មភាពអាជីវកម្មចម្បងរបស់ក្រុមហ៊ុន គឺការផ្តល់សេវាមីក្រូហិរញ្ញវត្ថុដល់ម្ចាស់ផ្ទះជាលើកដំបូងសម្រាប់គ្រួសារដែលមានចំណូលមធ្យម និងចំណូលទាបនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ក្រុមហ៊ុនធ្វើប្រតិបត្តិការអាជីវកម្ម ចំនួន 20 សាខា ដែល 1 សាខា មានទីតាំងនៅក្នុងរាជធានីភ្នំពេញ និង 19 សាខាទៀត មានទីតាំងស្ថិតនៅបណ្តាខេត្តដូចជា ខេត្តសៀមរាប ខេត្តកំពង់ចាម ខេត្តបាត់ដំបង ខេត្តបន្ទាយមានជ័យ ខេត្តកំពង់ស្ពឺ ខេត្តតាកែវ ខេត្តកំពត និងខេត្តកណ្តាល ខេត្តព្រៃវែង ខេត្តស្វាយរៀង ខេត្តកំពង់ធំ ខេត្តពោធិ៍សាត់ និងខេត្តកំពង់ឆ្នាំង។
ពុំមានការផ្លាស់ប្តូរ ដែលគួរឲ្យកត់សម្គាល់ណាមួយកើតឡើងនៅក្នុងលក្ខណៈនៃសកម្មភាពអាជីវកម្មចម្បងក្នុងអំឡុងការិយបរិច្ឆេទនេះឡើយ។

## លទ្ធផលហិរញ្ញវត្ថុ

លទ្ធផលហិរញ្ញវត្ថុរបស់ក្រុមហ៊ុនសម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2025 មានដូចខាងក្រោម៖

| | | 2025 | 2024 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 6) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 6) |
| ប្រាក់ចំណេញមុនដកពន្ធ | 1,381,936 | 5,542,945 | 1,201,387 | 4,890,846 |
| ចំណាយពន្ធលើប្រាក់ចំណេញ | (320,688) | (1,286,280) | (181,685) | (739,640) |
| ប្រាក់ចំណេញសុទ្ធសម្រាប់ការិយបរិច្ឆេទ | 1,061,248 | 4,256,665 | 1,019,702 | 4,151,206 |

## ដើមទុន

ពុំមានការប្រែប្រួលរចនាសម្ព័ន្ធភាគហ៊ុន ក្នុងអំឡុងការិយបរិច្ឆេទហិរញ្ញវត្ថុនេះទេ។

## ភាគលាភ

នាកាលបរិច្ឆេទរាយការណ៍ ពុំមានការប្រកាស ឬបែងចែកភាគលាភឡើយ ហើយក្រុមប្រឹក្សាភិបាលក៏ពុំមានអនុសាសន៍ឲ្យមានការបែងចែកភាគលាភសម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2025 នោះដែរ។

## ទុនបម្រុង និងសំវិធានធន

ពុំមានការប្រែប្រួលជាសារវន្តនៃទុនបម្រុង និងសំវិធានធននៅក្នុងការិយបរិច្ឆេទហិរញ្ញវត្ថុនេះ ក្រៅពីការបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុនេះឡើយ។

## ឥណទានអាក្រក់ និងសង្ស័យ

នៅមុនពេលដែលរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនត្រូវបានរៀបចំឡើង ក្រុមប្រឹក្សាភិបាលបានចាត់វិធានការសមស្របនានា ដើម្បីឈានដល់ការអះអាងថា នីតិវិធីពាក់ព័ន្ធជាមួយនឹងការលុបចោលឥណទានអាក្រក់ និងការធ្វើសំវិធានធនលើឥណទានជាប់សង្ស័យ ត្រូវបានយកមកអនុវត្ត ហើយក្រុមប្រឹក្សាភិបាលជឿជាក់ថារាល់ឥណទានអាក្រក់ដែលបានដឹងថាមិនអាចទារបាន ត្រូវបានលុបចោល ហើយសំវិធានធនត្រូវបាន ប៉ាន់ស្មានសមស្របសម្រាប់ឥណទានអាក្រក់ និងជាប់សង្ស័យ។
គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីព្រឹត្តិការណ៍ណាមួយដែលអាចបណ្តាលឲ្យចំនួនទឹកប្រាក់នៃឥណទានអាក្រក់ដែលបានលុបចោល ឬចំនួនទឹកប្រាក់សំវិធានធនលើឥណទានជាប់សង្ស័យនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន មានចំនួនមិនគ្រប់គ្រាន់ជាសារវន្តនោះទេ។

## ទ្រព្យសកម្ម

នៅមុនពេលដែលរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនត្រូវបានរៀបចំឡើង ក្រុមប្រឹក្សាភិបាលបានចាត់វិធានការ សមស្របនានា ដើម្បីបញ្ជាក់ថាបណ្តាទ្រព្យសកម្មរយៈពេលខ្លីទាំងអស់ក្រៅពីឥណទាន ដែលទំនងជាមិនអាចទទួលស្គាល់បាននៅក្នុងប្រតិបត្តិការអាជីវកម្មធម្មតាក្នុងតម្លៃរបស់វាដែលបានកត់ត្រានៅក្នុងបញ្ជីគណនេយ្យ ត្រូវបានបន្ថយនៅស្មើនឹងតម្លៃដែលគិតថានឹងអាចទទួលស្គាល់បានជាក់ស្តែង។
គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយ ដែលអាចបណ្តាលឲ្យការកំណត់តម្លៃទ្រព្យសកម្មរយៈពេលខ្លីនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន មានភាពមិនត្រឹមត្រូវនោះទេ។

## វិធីសាស្ត្រកំណត់តម្លៃ

គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយដែលបានកើតឡើង ហើយនឹងធ្វើឲ្យប៉ះពាល់ដល់ការអនុវត្តវិធីសាស្ត្រដែលមានកន្លងមកក្នុងការវាយតម្លៃទ្រព្យសកម្ម និងបំណុលនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន មានភាពមិនត្រឹមត្រូវ និងមិនសមស្របនោះទេ។

## បំណុលយថាហេតុ និងបំណុលផ្សេងៗ

គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ ពុំមាន៖

a. ការដាក់បញ្ចាំទ្រព្យសកម្មណាមួយរបស់ក្រុមហ៊ុន ចាប់តាំងពីថ្ងៃចុងការិយបរិច្ឆេទហិរញ្ញវត្ថុមក ក្នុងការធានាចំពោះបំណុលរបស់បុគ្គលណាម្នាក់ឡើយ និង
b. បំណុលយថាហេតុណាមួយដែលកើតមានឡើងចំពោះក្រុមហ៊ុន ចាប់តាំងពីចុងការិយបរិច្ឆេទហិរញ្ញវត្ថុមក ក្រៅអំពីប្រតិបត្តិការអាជីវកម្មធម្មតារបស់ក្រុមហ៊ុនឡើយ។

ក្រុមប្រឹក្សាភិបាលមានមតិថា ពុំមានបំណុលយថាហេតុ ឬបំណុលផ្សេងទៀតរបស់ក្រុមហ៊ុនដែលត្រូវបំពេញ ឬអាចនឹងត្រូវ

បំពេញក្នុងរយៈពេល 12ខែ បន្ទាប់ពីចុងការិយបរិច្ឆេទហិរញ្ញវត្ថុ ដែលនឹងធ្វើឲ្យមានផលប៉ះពាល់ ឬអាចនឹង ប៉ះពាល់ជាសារវន្ត ដល់លទ្ធភាពរបស់ក្រុមហ៊ុនក្នុងការបំពេញកាតព្វកិច្ចរបស់ខ្លួនដូចដែលបានកំណត់ និងនៅពេលដែលដល់ថ្ងៃកំណត់។

## ប្រតិបត្តិការមិនប្រក្រតី

ក្រុមប្រឹក្សាភិបាលមានមតិថា លទ្ធផលនៃការធ្វើប្រតិបត្តិការរបស់ក្រុមហ៊ុនក្នុងការិយបរិច្ឆេទហិរញ្ញវត្ថុនេះ មិនមានផលប៉ះពាល់ជាសារវន្តដោយសកម្មភាពប្រតិបត្តិការ ឬព្រឹត្តិការណ៍ណាមួយដែលមានលក្ខណៈជាសារវន្ត និងមិនប្រក្រតីនោះទេ។ ក្រុមប្រឹក្សាភិបាលក៏មានមតិផងដែរថា នៅក្នុងចន្លោះពេលចាប់ពីថ្ងៃចុងការិយបរិច្ឆេទហិរញ្ញវត្ថុដល់ថ្ងៃចេញរបាយការណ៍នេះ ពុំមានចំណាត់ថ្នាក់សកម្មភាពប្រតិបត្តិការ ឬព្រឹត្តិការណ៍ណាមួយដែលមានលក្ខណៈជាសារវន្ត និងមិនប្រក្រតីកើតមានឡើង ដែលអាចនាំឲ្យប៉ះពាល់ជាសារវន្តដល់លទ្ធផលនៃប្រតិបត្តិការរបស់ក្រុមហ៊ុនក្នុងកាលបរិច្ឆេទហិរញ្ញវត្ថុ ដែលរបាយការណ៍នេះបានរៀបចំឡើងនោះទេ។

## ក្រុមប្រឹក្សាភិបាល

សមាជិកក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុន ក្នុងអំឡុងការិយបរិច្ឆេទ និងរហូតដល់កាលបរិច្ឆេទនៃរបាយការណ៍នេះ រួមមាន៖

| **ឈ្មោះ** | **មុខតំណែង** | **កាលបរិច្ឆេទតែងតាំង** |
|---|---|---|
| លោក Klaas Hanco Halbertsma | ប្រធានក្រុមប្រឹក្សាភិបាល | ថ្ងៃទី29 ខែមិថុនា ឆ្នាំ2018 |
| លោក អ៊ុំ សូផន | អភិបាល | ថ្ងៃទី9 ខែមិថុនា ឆ្នាំ2022 |
| លោក ស៊ីម សេនាជាតិ | អភិបាល | ថ្ងៃទី9 ខែមិថុនា ឆ្នាំ2022 |
| លោក ជា ហាង | អភិបាល | ថ្ងៃទី9 ខែមិថុនា ឆ្នាំ2022 |
| លោក ស៊ូ វណ្ណថន | អភិបាលឯករាជ្យ | ថ្ងៃទី9 ខែមិថុនា ឆ្នាំ2022 |

## ភាគកម្មរបស់ក្រុមប្រឹក្សាភិបាលនៅក្នុងក្រុមហ៊ុន

ភាគកម្មរបស់ក្រុមប្រឹក្សាភិបាល ដែលកាន់តំណែងនាចុងការិយបរិច្ឆេទនៅក្នុងភាគហ៊ុនធម្មតារបស់ក្រុមហ៊ុន មានដូចខាងក្រោម៖

| **ឈ្មោះ** | **ថ្ងៃទី31 ខែធ្នូ ឆ្នាំ2025 % កម្មសិទ្ធិ** | **ចំនួនភាគហ៊ុន** |
|---|---|---|
| លោក ជា ហាង | 0.000067% | 1 |

## អត្ថប្រយោជន៍របស់ក្រុមប្រឹក្សាភិបាល

នៅក្នុងអំឡុងការិយបរិច្ឆេទ និងនៅចុងការិយបរិច្ឆេទហិរញ្ញវត្ថុនេះ ពុំមានកិច្ចព្រមព្រៀងណាមួយដែលក្រុមហ៊ុនជា ភាគីម្ខាងដែលកម្មវត្ថុនៃកិច្ចព្រមព្រៀងនោះបានផ្តល់លទ្ធភាពដល់ក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុន ឲ្យទទួលបាននូវអត្ថប្រយោជន៍តាមមធ្យោបាយនៃការទិញភាគហ៊ុននោះឡើយ។
ចាប់តាំងពីចុងការិយបរិច្ឆេទហិរញ្ញវត្ថុមុន ពុំមានក្រុមប្រឹក្សាភិបាលណាម្នាក់បានទទួល ឬមានសិទ្ធិទទួលបាននូវអត្ថប្រយោជន៍ណាមួយ (ក្រៅពីអត្ថប្រយោជន៍ដែលបានរួមបញ្ចូលនៅក្នុងបរិលោភសរុបទទួលបាន ឬដល់កំណត់ទទួលបានដោយអ្នកគ្រប់គ្រង ដូចដែលបានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ) តាមរយៈការចុះកិច្ចសន្យាធ្វើឡើងដោយក្រុមហ៊ុន ឬដោយសាជីវកម្មពាក់ព័ន្ធណាមួយ ជាមួយនឹងក្រុមហ៊ុនណាមួយ ដែលក្រុមប្រឹក្សាភិបាលនោះជាសមាជិកនៃក្រុមហ៊ុននោះ ឬដែលអភិបាលនោះមានភាគកម្មផ្នែកហិរញ្ញវត្ថុជាសារវន្តនោះទេ លើកលែងតែអ្វីដែលបានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុនេះ។

## ការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាលក្នុងការរៀបចំលើរបាយការណ៍ហិរញ្ញវត្ថុ

ក្រុមប្រឹក្សាភិបាលមានភារៈធ្វើការអះអាងបញ្ជាក់ថា របាយការណ៍ហិរញ្ញវត្ថុបានបង្ហាញនូវភាពត្រឹមត្រូវលើរាល់ទិដ្ឋភាពជាសារវន្ត នៃស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុន នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2025 ព្រមទាំងលទ្ធផលហិរញ្ញវត្ថុ និងលំហូរទឹកប្រាក់របស់ក្រុមហ៊ុន សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ ដោយអនុលោមតាម ស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា សម្រាប់សហគ្រាសធុនតូច និងមធ្យម ("ស.រ.ទ.ហ.អ.ក សម្រាប់ ស.ត.ម") ដែលបានបង្ហាញ។ នៅក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុនេះ ក្រុមប្រឹក្សាភិបាលចាំបាច់ត្រូវ៖

- អនុម័តនូវគោលនយោបាយគណនេយ្យដែលសមស្រប ដោយផ្អែកលើការវិនិច្ឆ័យ និងការប៉ាន់ប្រមាណយ៉ាងសមហេតុផល និងប្រុងប្រយ័ត្ន ហើយធ្វើការអនុវត្តប្រកបដោយសង្គតិភាព
- អនុលោមទៅតាម ស.រ.ទ.ហ.អ.ក សម្រាប់ ស.ត.ម ឬប្រសិនបើមានការផ្លាស់ប្តូរពីនេះ គឺត្រូវតែបង្ហាញ ពន្យល់ និងកំណត់បរិមាណឲ្យបានច្បាស់លាស់នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ដើម្បីបង្ហាញនូវភាពពិត និងត្រឹមត្រូវ
- ត្រួតពិនិត្យប្រព័ន្ធដំណើរការនៃរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន និងរក្សាទុកនូវបញ្ជីគណនេយ្យឲ្យបានគ្រប់គ្រាន់ និងប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុងឲ្យមានប្រសិទ្ធភាព
- វាយតម្លៃនូវលទ្ធភាពរបស់ក្រុមហ៊ុន ក្នុងការបន្តនិរន្តរភាពអាជីវកម្ម ទទួលខុសត្រូវលើការលាតត្រដាងព័ត៌មាន ប្រសិនបើពាក់ព័ន្ធនូវបញ្ហាទាំងឡាយដែលទាក់ទងទៅនឹងនិរន្តរភាពអាជីវកម្ម និងប្រើប្រាស់មូលដ្ឋាននិរន្តរភាពនៃគណនេយ្យ លើកលែងតែអ្នកគ្រប់គ្រងមានបំណងចង់ជម្រះបញ្ជី ផ្អាកដំណើរការក្រុមហ៊ុន ឬគ្មានជម្រើសសមរម្យដទៃទៀតក្រៅពីធ្វើបែបនេះ និង
- ត្រួតពិនិត្យ និងដឹកនាំក្រុមហ៊ុនឲ្យមានប្រសិទ្ធភាពលើរាល់សេចក្តីសម្រេចដែលមានសារៈសំខាន់ទាំងអស់ដែល ប៉ះពាល់ដល់សកម្មភាពប្រតិបត្តិការ និងដំណើរការរបស់ក្រុមហ៊ុន ហើយត្រូវប្រាកដថា កិច្ចការនេះត្រូវបានឆ្លុះបញ្ចាំងយ៉ាងត្រឹមត្រូវនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

ក្រុមប្រឹក្សាភិបាល មានទំនួលខុសត្រូវក្នុងការការពារទ្រព្យសម្បត្តិរបស់ក្រុមហ៊ុន ក៏ដូចជាចាត់វិធានការសមហេតុផលសម្រាប់ការបង្ការ និងរកឃើញការក្លែងបន្លំ និងភាពមិនប្រក្រតីផ្សេងៗទៀត។
ក្រុមប្រឹក្សាភិបាលធានាអះអាងថា ក្រុមប្រឹក្សាភិបាលបានអនុវត្តនូវរាល់តម្រូវការ ដូចមានរាយការណ៍ខាងលើ ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ។

## សេចក្តីបញ្ជាក់របស់ក្រុមប្រឹក្សាភិបាល

ជាមតិរបស់ក្រុមប្រឹក្សាភិបាល របាយការណ៍ស្ថានភាពហិរញ្ញវត្ថុដែលបានភ្ជាប់មកជាមួយ រួមមានរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ របាយការណ៍លទ្ធផលលម្អិត របាយការណ៍ស្តីពីបម្រែបម្រួលមូលធន និងរបាយការណ៍លំហូរទឹកប្រាក់ ព្រមទាំងកំណត់សម្គាល់នានា ដូចបានបង្ហាញនៅទំព័រទី10 ដល់ទី63 ត្រូវបានរៀបចំឡើងយ៉ាងសមស្របដោយផ្តល់នូវទិដ្ឋភាពពិត និងត្រឹមត្រូវ ពីស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុន នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2025 ព្រមទាំងលទ្ធផលហិរញ្ញវត្ថុ និងលំហូរទឹកប្រាក់សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ ដោយអនុលោមតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជាសម្រាប់សហគ្រាសធុនតូច និងមធ្យម។

ចុះហត្ថលេខាតំណាងឲ្យក្រុមប្រឹក្សាភិបាលដោយយោងទៅតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល៖

ស៊ីម សេនាជាតិ
ប្រធាននាយកប្រតិបត្តិ
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ថ្ងៃទី18 ខែមីនា ឆ្នាំ2026



# របាយការណ៍សវនករឯករាជ្យ

ជូនចំពោះភាគហ៊ុនិកនៃ

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ហ្វឺស ហ្វាយនែន ភីអិលស៊ី

## មតិសវនកម្ម

យើងខ្ញុំ បានធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុរបស់ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ហ្វឺស ហ្វាយនែន ភីអិលស៊ី (ហៅកាត់ថា "ក្រុមហ៊ុន") ដែលរួមមានរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2025 របាយការណ៍លទ្ធផលលម្អិតរបាយការណ៍ស្តីពីបម្រែបម្រួលមូលធន និងរបាយការណ៍លំហូរទឹកប្រាក់ សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ និងកំណត់សម្គាល់ ដែលរួមមានគោលនយោបាយគណនេយ្យសំខាន់ៗ ព្រមទាំងព័ត៌មានពន្យល់ផ្សេងៗទៀត ដូចបានបង្ហាញនៅទំព័រទី10 ដល់ទី63 (ដែលតទៅហៅកាត់ថា "របាយការណ៍ហិរញ្ញវត្ថុ")។

ជាមតិរបស់យើងខ្ញុំ របាយការណ៍ហិរញ្ញវត្ថុដែលបានភ្ជាប់មកជាមួយ បានបង្ហាញនូវភាពត្រឹមត្រូវលើរាល់ទិដ្ឋភាពជាសារវន្ត នៃស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុន នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2025 ព្រមទាំងលទ្ធផលហិរញ្ញវត្ថុ និងលំហូរទឹកប្រាក់របស់ក្រុមហ៊ុន សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ ដោយអនុលោមទៅតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា សម្រាប់សហគ្រាសធុនតូច និងមធ្យម ("ស.រ.ទ.ហ.អ.ក សម្រាប់ ស.ត.ម")។

## មូលដ្ឋាននៃមតិសវនកម្ម

យើងខ្ញុំ បានធ្វើសវនកម្មដោយអនុលោមទៅតាមស្តង់ដាសវនកម្មអន្តរជាតិនៃកម្ពុជា។ ការទទួលខុសត្រូវរបស់យើងខ្ញុំដែលស្របតាមស្តង់ដាទាំងនោះ ត្រូវបានពណ៌នាបន្ថែមទៀតនៅក្នុងកថាខណ្ឌស្តីពី ការទទួលខុសត្រូវរបស់សវនករចំពោះការធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ ដែលមាននៅក្នុងរបាយការណ៍របស់យើងខ្ញុំ។ យើងខ្ញុំ មានភាពឯករាជ្យពីក្រុមហ៊ុន ដោយស្របទៅតាមលក្ខខណ្ឌតម្រូវនៃក្រមសីលធម៌វិជ្ជាជីវៈនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលពាក់ព័ន្ធនឹងសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ ហើយយើងខ្ញុំបានបំពេញនូវទំនួលខុសត្រូវក្រមសីលធម៌វិជ្ជាជីវៈផ្សេងៗទៀតស្របតាមលក្ខខណ្ឌតម្រូវទាំងនេះ។ យើងខ្ញុំជឿជាក់ថាភស្តុតាងសវនកម្មដែលយើងខ្ញុំប្រមូលបាន មានលក្ខណៈគ្រប់គ្រាន់ និងសមស្រប សម្រាប់ជាមូលដ្ឋានក្នុងការបញ្ចេញមតិសវនកម្មរបស់យើងខ្ញុំ។

## ព័ត៌មានផ្សេងៗ

អ្នកគ្រប់គ្រង មានភារៈទទួលខុសត្រូវលើព័ត៌មានផ្សេងៗ។ ព័ត៌មានផ្សេងៗ រួមមានរបាយការណ៍របស់ក្រុមប្រឹក្សាភិបាល ដែលបានបង្ហាញនៅទំព័រទី1 ដល់ទី5។ មតិសវនកម្មរបស់យើងខ្ញុំ ទៅលើរបាយការណ៍ហិរញ្ញវត្ថុ មិនបានគ្របដណ្តប់លើព័ត៌មានផ្សេងៗឡើយ ហើយយើងខ្ញុំមិនធ្វើការផ្តល់នូវអំណះអំណាងណាមួយទៅលើព័ត៌មានផ្សេងៗនេះដែរ។

ពាក់ព័ន្ធនឹងការធ្វើសវនកម្មរបស់យើងខ្ញុំលើរបាយការណ៍ហិរញ្ញវត្ថុ ការទទួលខុសត្រូវរបស់យើងខ្ញុំ គឺត្រូវអានព័ត៌មានផ្សេងៗ ហើយពិចារណាថាតើព័ត៌មានផ្សេងៗនោះ មានភាពមិនស្របគ្នាជាសារវន្តជាមួយរបាយការណ៍ហិរញ្ញវត្ថុ ឬការយល់ដឹងរបស់យើងខ្ញុំនៅក្នុងការធ្វើសវនកម្ម ឬមានបង្ហាញនូវកំហុងឆ្គងជាសារវន្ត។

ប្រសិនបើការអានព័ត៌មានផ្សេងៗ ដែលបានទទួលមុនកាលបរិច្ឆេទនៃរបាយការណ៍សវនកម្មនេះ អាចឲ្យយើងខ្ញុំសន្និដ្ឋានថា មានកំហុសឆ្គងជាសារវន្តកើតឡើងលើព័ត៌មានផ្សេងៗនេះ យើងខ្ញុំត្រូវរាយការណ៍ទៅតាមស្ថានភាពជាក់ស្តែង។ យើងខ្ញុំពុំមានអ្វីដែលត្រូវរាយការណ៍ពាក់ព័ន្ធនឹងព័ត៌មានផ្សេងៗ នេះទេ។

## ការទទួលខុសត្រូវរបស់អ្នកគ្រប់គ្រង និងអ្នកទទួលខុសត្រូវលើអភិបាលកិច្ចលើរបាយការណ៍ហិរញ្ញវត្ថុ

អ្នកគ្រប់គ្រងមានភារៈទទួលខុសត្រូវលើការរៀបចំ និងការបង្ហាញនូវភាពត្រឹមត្រូវនៃរបាយការណ៍ហិរញ្ញវត្ថុ ដោយអនុលោមទៅតាមស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា សម្រាប់សហគ្រាសធុនតូច និងមធ្យម ហើយទទួលខុសត្រូវលើប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ដែលអ្នកគ្រប់គ្រងកំណត់ថាមានភាពចាំបាច់សម្រាប់ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ ឲ្យជៀសផុតពីការបង្ហាញខុសជាសារវន្តដោយសារតែការក្លែងបន្លំ ឬកំហុសឆ្គង។

នៅក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ អ្នកគ្រប់គ្រងមានភារៈទទួលខុសត្រូវលើការវាយតម្លៃនូវលទ្ធភាពរបស់ក្រុមហ៊ុនក្នុងការបន្តនិរន្តរភាពអាជីវកម្ម ទទួលខុសត្រូវលើការលាតត្រដាងព័ត៌មាន ប្រសិនបើពាក់ព័ន្ធ នូវបញ្ហាទាំងឡាយដែលទាក់ទិនទៅនឹងនិរន្តរភាពអាជីវកម្ម និងប្រើប្រាស់មូលដ្ឋាននិរន្តរភាពនៃគណនេយ្យ លើកលែងតែអ្នកគ្រប់គ្រងមានបំណងចង់ជម្រះបញ្ជី ផ្អាកដំណើរការក្រុមហ៊ុន ឬគ្មានជម្រើសសមរម្យដទៃទៀត ក្រៅពីធ្វើបែបនេះ។

អ្នកទទួលខុសត្រូវលើអភិបាលកិច្ច មានភារៈទទួលខុសត្រូវក្នុងការត្រួតពិនិត្យដំណើរការនៃការរាយការណ៍ព័ត៌មានហិរញ្ញវត្ថុរបស់ក្រុមហ៊ុន។

## ការទទួលខុសត្រូវរបស់សវនករចំពោះការធ្វើសវនកម្មរបាយការណ៍ហិរញ្ញវត្ថុ

គោលដៅរបស់យើងខ្ញុំ គឺទទួលបាននូវអំណះអំណាងសមហេតុផលថារបាយការណ៍ហិរញ្ញវត្ថុទាំងមូល មិនមានការ បង្ហាញខុសជាសារវន្តដោយសារតែការក្លែងបន្លំ ឬកំហុសឆ្គង និងផ្តល់នូវរបាយការណ៍របស់សវនករ ដែលរួមបញ្ចូលទាំងមតិសវនកម្មរបស់យើងខ្ញុំ។ អំណះអំណាងសមហេតុផល គឺជាអំណះអំណាងមួយដែលមានកម្រិតខ្ពស់ ប៉ុន្តែវាមិនអាចធានាថា គ្រប់ពេលនៃការធ្វើសវនកម្មដោយអនុលោមទៅតាមស្តង់ដាសវនកម្មអន្តរជាតិនៃកម្ពុជា អាចរកឃើញនូវការបង្ហាញខុសជាសារវន្តដែលបានកើតឡើងនោះទេ។ ការបង្ហាញខុស អាចកើតឡើងដោយសារការក្លែងបន្លំ ឬកំហុសឆ្គង ហើយត្រូវបានចាត់ទុកថាមានលក្ខណៈសារវន្ត នៅពេលដែលការក្លែងបន្លំ ឬកំហុសឆ្គងដោយឡែក ឬក៏រួមបញ្ចូលគ្នាអាចត្រូវបានរំពឹងទុកយ៉ាងសមហេតុផលថា នឹងជះឥទ្ធិពលដល់ការសម្រេចចិត្តផ្នែកសេដ្ឋកិច្ចរបស់អ្នកប្រើប្រាស់ ដោយយោងលើរបាយការណ៍ហិរញ្ញវត្ថុនេះ។

ជាផ្នែកមួយនៃការធ្វើសវនកម្ម ដោយអនុលោមទៅតាមស្តង់ដាសវនកម្មអន្តរជាតិនៃកម្ពុជា យើងខ្ញុំអនុវត្តនូវការវិនិច្ឆ័យដែលប្រកបទៅដោយវិជ្ជាជីវៈ និងរក្សានូវមជ្ឈដ្ឋានិយមក្នុងអំឡុងពេលធ្វើសវនកម្ម។ យើងខ្ញុំក៏៖

- ធ្វើការកំណត់ និងវាយតម្លៃនូវហានិភ័យនៃការបង្ហាញខុសជាសារវន្តនៃរបាយការណ៍ហិរញ្ញវត្ថុ ដោយសារតែការក្លែងបន្លំ ឬកំហុសឆ្គង និងទទួលខុសត្រូវលើការតាក់តែង និងអនុវត្តនូវនីតិវិធីសវនកម្ម ដើម្បីឆ្លើយតបទៅនឹងហានិភ័យទាំងនោះ និងប្រមូលនូវភស្តុតាងដែលមានលក្ខណៈគ្រប់គ្រាន់ និងសមស្របសម្រាប់ជាមូលដ្ឋានក្នុងការបញ្ចេញមតិសវនកម្មរបស់យើងខ្ញុំ។ ហានិភ័យនៃការរកមិនឃើញនូវការបង្ហាញខុសជាសារវន្ត ដែលបណ្តាលមកពីការក្លែងបន្លំ មានលក្ខណៈខ្ពស់ជាងការបង្ហាញខុសដែលបណ្តាលមកពីកំហុសឆ្គង ដោយសារតែការក្លែងបន្លំអាចទាក់ទិននឹងការឃុបឃិតគ្នា ការលួចបន្លំ ការលុបចោលដោយចេតនា ការបកស្រាយមិនពិត ឬមិនអនុវត្តតាម នីតិវិធីនៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង។
- ធ្វើការស្វែងយល់អំពីប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ដែលពាក់ព័ន្ធនឹងការធ្វើសវនកម្ម ក្នុងគោលបំណងដើម្បីតាក់តែងនូវនីតិវិធីសវនកម្មដែលសមស្របទៅតាមកាលៈទេសៈ ប៉ុន្តែមិនមែនក្នុងគោលបំណងដើម្បីបញ្ចេញមតិលើប្រសិទ្ធភាពនៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងរបស់ក្រុមហ៊ុនឡើយ។
- ធ្វើការវាយតម្លៃលើភាពសមស្របនៃគោលនយោបាយគណនេយ្យដែលក្រុមហ៊ុនបានអនុវត្ត និងភាពសមហេតុផលនៃការប៉ាន់ស្មានគណនេយ្យ ព្រមទាំងការលាតត្រដាងព័ត៌មានពាក់ព័ន្ធនានា ដែលបានធ្វើឡើងដោយអ្នកគ្រប់គ្រង។
- ធ្វើការសន្និដ្ឋានលើ ភាពសមស្របនៃការប្រើប្រាស់មូលដ្ឋាននិរន្តរភាពនៃគណនេយ្យរបស់អ្នកគ្រប់គ្រង ហើយដោយផ្អែកទៅលើភស្តុតាងសវនកម្មដែលទទួលបាន ធ្វើការសន្និដ្ឋានថាតើភាពមិនប្រាកដប្រជាជាសារវន្តបានកើតមានឡើងពាក់ព័ន្ធទៅនឹងព្រឹត្តិការណ៍ ឬលក្ខខណ្ឌដែលអាចបង្កឲ្យមានមន្ទិលជាសារវន្តលើលទ្ធភាពរបស់ក្រុមហ៊ុន ដើម្បីបន្តនិរន្តរភាពអាជីវកម្មដែរ ឬទេ។ ប្រសិនបើយើងខ្ញុំ ធ្វើការសន្និដ្ឋានថា មានអត្ថិភាពនៃភាពមិនប្រាកដប្រជាជាសារវន្ត យើងខ្ញុំចាំបាច់ត្រូវទាញចំណាប់អារម្មណ៍នៅក្នុងរបាយការណ៍សវនកម្មរបស់យើងខ្ញុំ លើការលាតត្រដាងព័ត៌មានពាក់ព័ន្ធនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ឬប្រសិនបើការលាតត្រដាងព័ត៌មានមានលក្ខណៈមិនគ្រប់គ្រាន់ យើងខ្ញុំចាំបាច់ត្រូវផ្តល់មតិសវនកម្មដែលមានបញ្ហា។ ការសន្និដ្ឋានរបស់យើងខ្ញុំ គឺផ្អែកតាមភស្តុតាងសវនកម្មដែលប្រមូលបានត្រឹមកាលបរិច្ឆេទនៃរបាយការណ៍សវនកម្មរបស់យើងខ្ញុំ។ ទោះជាយ៉ាងណាក៏ដោយ ព្រឹត្តិការណ៍ ឬលក្ខខណ្ឌនាពេលអនាគតអាចបណ្តាលឲ្យក្រុមហ៊ុនបញ្ឈប់និរន្តរភាពនៃអាជីវកម្ម។
- ធ្វើការវាយតម្លៃលើការបង្ហាញ ទម្រង់ និងខ្លឹមសារនៃរបាយការណ៍ហិរញ្ញវត្ថុទាំងមូល ដោយរួមបញ្ចូលទាំងការ លាតត្រដាងព័ត៌មាន និងវាយតម្លៃថាតើរបាយការណ៍ហិរញ្ញវត្ថុបានបង្ហាញពីប្រតិបត្តិការ និងព្រឹត្តិការណ៍ពាក់ព័ន្ធ ក្នុងអត្ថន័យដែលអាចសម្រេចបាននូវការបង្ហាញរបាយការណ៍ហិរញ្ញវត្ថុដ៏ត្រឹមត្រូវ។

យើងខ្ញុំ ផ្តល់ព័ត៌មាន ក្នុងចំណោមបញ្ហាផ្សេងៗ ជូនអ្នកទទួលខុសត្រូវលើអភិបាលកិច្ចស្តីពីវិសាលភាព និងពេលវេលាដែលបានគ្រោងទុកសម្រាប់ការធ្វើសវនកម្ម និងការរកឃើញបញ្ហាជាសារវន្ត ដោយរួមបញ្ចូលទាំងចំណុចខ្វះខាតជាសារវន្តក្នុងប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ដែលយើងខ្ញុំបានរកឃើញក្នុងអំឡុងពេលធ្វើសវនកម្ម។

តំណាងក្រុមហ៊ុន **ខេភីអឹមជី ខេមបូឌា**




**ខៃ ហ៊ុយ**

*Senior Partner*

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ថ្ងៃទី18 ខែមីនា ឆ្នាំ2026

# របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ

នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2025

| | កំណត់សម្គាល់ | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2025 | | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2024 | |
|---|---|---|---|---|---|
| | | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 6) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 6) |
| **ទ្រព្យសកម្ម** | | | | | |
| សាច់ប្រាក់ក្នុងដៃ | 7 | 201,238 | 807,568 | 76,996 | 309,909 |
| សមតុល្យជាមួយធនាគារជាតិ នៃកម្ពុជា | 8 | 768,363 | 3,083,441 | 760,825 | 3,062,321 |
| សមតុល្យជាមួយធនាគារនានា | 9 | 5,784,291 | 23,212,360 | 3,010,502 | 12,117,271 |
| ឥណទានផ្ដល់ជូនអតិថិជនសុទ្ធ | 10 | 99,765,776 | 400,360,059 | 88,470,894 | 356,095,348 |
| ទ្រព្យ និងបរិក្ខារ | 11 | 330,522 | 1,326,385 | 323,129 | 1,300,594 |
| ទ្រព្យសកម្មអរូបី | 12 | 21,098 | 84,666 | 17,981 | 72,374 |
| ឥណទានពន្ធលើប្រាក់ចំណេញ | 13គ | 60,788 | 243,942 | - | - |
| ទ្រព្យសកម្មផ្សេងៗ | 14 | 448,233 | 1,798,759 | 550,160 | 2,214,394 |
| ទ្រព្យសកម្មសរុប | | 107,380,309 | 430,917,180 | 93,210,487 | 375,172,211 |
| **បំណុល និងមូលធន** | | | | | |
| **បំណុល** | | | | | |
| អត្ថប្រយោជន៍និយោជិត | 15 | 25,251 | 101,332 | 26,596 | 107,049 |
| ប្រាក់កម្ចី | 16 | 71,711,951 | 287,780,059 | 58,697,245 | 236,256,411 |
| បំណុលបន្ទាប់បន្សំ | 17 | 15,638,681 | 62,758,027 | 15,592,056 | 62,758,025 |
| បំណុលពន្ធលើប្រាក់ចំណេញ | 13គ | - | - | 12,172 | 48,992 |
| ពន្ធពន្យារសុទ្ធជាបំណុល | 13ឃ | 562,175 | 2,256,008 | 373,042 | 1,501,494 |
| បំណុលផ្សេងៗ | 18 | 1,395,003 | 5,598,148 | 1,523,376 | 6,131,590 |
| **បំណុលសរុប** | | 89,333,061 | 358,493,574 | 76,224,487 | 306,803,561 |
| **មូលធន** | | | | | |
| ដើមទុន | 19 | 15,000,000 | 60,000,000 | 15,000,000 | 60,000,000 |
| ប្រាក់ខាតបង្គរ | | (1,365,293) | (5,517,857) | (1,652,631) | (6,670,369) |
| ទុនបម្រុងតាមបទប្បញ្ញត្តិ | 20 | 4,412,541 | 17,862,977 | 3,638,631 | 14,758,824 |
| ទុនបម្រុងពីការប្តូររូបិយប័ណ្ណបង្គរ | | - | 78,486 | - | 280,195 |
| **មូលធនសរុប** | | 18,047,248 | 72,423,606 | 16,986,000 | 68,368,650 |
| **បំណុល និងមូលធនសរុប** | | 107,380,309 | 430,917,180 | 93,210,487 | 375,172,211 |

កំណត់សម្គាល់ដែលភ្ជាប់មកជាមួយ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុដូចដែលមាននៅក្នុងរបាយការណ៍សវនកម្មរបស់យើងខ្ញុំ



# របាយការណ៍លទ្ធផលលម្អិត

សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2025

| | កំណត់សម្គាល់ | 2025 | | 2024 | |
|---|---|---|---|---|---|
| | | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់6) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់6) |
| **ចំណូលពីប្រតិបត្តិការ** | | | | | |
| ចំណូលការប្រាក់ | 21 | 14,380,885 | 57,681,730 | 13,621,324 | 55,452,410 |
| ចំណាយការប្រាក់ | 22 | (7,766,978) | (31,153,349) | (7,657,084) | (31,171,989) |
| **ចំណូលការប្រាក់សុទ្ធ** | | 6,613,907 | 26,528,381 | 5,964,240 | 24,280,421 |
| ចំណូលកម្រៃសេវា និងកម្រៃជើងសា | 23 | 404,845 | 1,623,833 | 337,417 | 1,373,625 |
| ចំណូលផ្សេងៗ | 24 | 68,620 | 275,235 | 113,307 | 461,272 |
| **ប្រាក់ចំណេញពីប្រតិបត្តិការសុទ្ធ** | | 7,087,372 | 28,427,449 | 6,414,964 | 26,115,318 |
| ការខាតបង់ឱនភាពនៃតម្លៃលើ ទ្រព្យសកម្មហិរញ្ញវត្ថុសុទ្ធ | 10 | (615,681) | (2,469,496) | (956,605) | (3,894,339) |
| រំលស់ | 11&12 | (113,878) | (456,765) | (110,133) | (448,351) |
| ចំណាយបុគ្គលិក | 25 | (3,379,613) | (13,555,628) | (2,854,339) | (11,620,014) |
| ចំណាយទូទៅ និងរដ្ឋបាល | 26 | (1,596,264) | (6,402,615) | (1,151,430) | (4,687,472) |
| ចំណាយពន្ធអប្បបរមា | 13ខ | - | - | (141,070) | (574,296) |
| **ប្រាក់ចំណេញមុនដកពន្ធ** | | 1,381,936 | 5,542,945 | 1,201,387 | 4,890,846 |
| ចំណាយពន្ធលើប្រាក់ចំណេញ | 13ខ | (320,688) | (1,286,280) | (181,685) | (739,640) |
| **ប្រាក់ចំណេញសុទ្ធ សម្រាប់ការិយបរិច្ឆេទ** | | 1,061,248 | 4,256,665 | 1,019,702 | 4,151,206 |
| *ធាតុដែលនឹងមិនត្រូវបានចាត់ថ្នាក់ឡើងវិញក្នុង របាយការណ៍ចំណេញ ឬខាត* | | | | | |
| លទ្ធផលលម្អិតផ្សេងៗ លម្អៀងពីការប្តូររូបិយប័ណ្ណ | | - | (201,709) | - | (1,004,883) |
| **លទ្ធផលលម្អិតសរុប សម្រាប់ការិយបរិច្ឆេទ** | | 1,061,248 | 4,054,956 | 1,019,702 | 3,146,323 |

កំណត់សម្គាល់ដែលភ្ជាប់មកជាមួយ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុដូចដែលមាននៅក្នុងរបាយការណ៍សវនកម្មរបស់យើងខ្ញុំ

# របាយការណ៍បម្រែបម្រួលមូលធន

## សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2025

| | កំណត់សម្គាល់ | ដើមទុន US$ ដុល្លារអាមេរិក | ដើមទុន KHR-000 ពាន់រៀល (កំណត់សម្គាល់6) | ទុនបម្រុងតាមបទប្បញ្ញត្តិ US$ ដុល្លារអាមេរិក | ទុនបម្រុងតាមបទប្បញ្ញត្តិ KHR-000 ពាន់រៀល (កំណត់សម្គាល់6) | (ប្រាក់ខាតបង្គរ)/ ប្រាក់ចំណេញរក្សាទុក US$ ដុល្លារអាមេរិក | (ប្រាក់ខាតបង្គរ)/ ប្រាក់ចំណេញរក្សាទុក KHR-000 ពាន់រៀល (កំណត់សម្គាល់6) | ទុនបម្រុងពីការ ប្តូររូបិយប័ណ្ណបង្គរ KHR-000 ពាន់រៀល (កំណត់សម្គាល់6) | សរុប US$ ដុល្លារអាមេរិក | សរុប KHR-000 ពាន់រៀល (កំណត់សម្គាល់6) |
|---|---|---|---|---|---|---|---|---|---|---|
| នាថ្ងៃទី1 ខែមករា ឆ្នាំ2025 | | 15,000,000 | 60,000,000 | 3,638,631 | 14,758,824 | (1,652,631) | (6,670,369) | 280,195 | 16,986,000 | 68,368,650 |
| ***ប្រតិបត្តិការដែលបានទទួលស្គាល់ដោយផ្ទាល់ក្នុងមូលធន*** | | | | | | | | | | |
| បម្រែបម្រួលក្នុងទុនបម្រុងតាមបទប្បញ្ញត្តិ | 20 | - | - | 773,910 | 3,104,153 | (773,910) | (3,104,153) | - | - | - |
| ***លទ្ធផលលម្អិតសរុប៖*** | | | | | | | | | | |
| ប្រាក់ចំណេញសុទ្ធសម្រាប់ការិយបរិច្ឆេទ | | - | - | - | - | 1,061,248 | 4,256,665 | - | 1,061,248 | 4,256,665 |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | | - | - | - | - | - | - | (201,709) | - | (201,709) |
| | | - | - | - | - | 1,061,248 | 4,256,665 | (201,709) | 1,061,248 | 4,054,956 |
| នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2025 | | 15,000,000 | 60,000,000 | 4,412,541 | 17,862,977 | (1,365,293) | (5,517,857) | 78,486 | 18,047,248 | 72,423,606 |
| នាថ្ងៃទី1 ខែមករា ឆ្នាំ2024 | | 15,000,000 | 60,000,000 | 1,715,373 | 7,017,711 | (749,075) | (3,080,462) | 1,285,078 | 15,966,298 | 65,222,327 |
| ***ប្រតិបត្តិការដែលបានទទួលស្គាល់ដោយផ្ទាល់ក្នុងមូលធន*** | | | | | | | | | | - |
| បម្រែបម្រួលក្នុងទុនបម្រុងតាមបទប្បញ្ញត្តិ | 20 | - | - | 1,923,258 | 7,741,113 | (1,923,258) | (7,741,113) | - | - | - |
| ***លទ្ធផលលម្អិតសរុប៖*** | | | | | | | | | | |
| ប្រាក់ចំណេញសុទ្ធសម្រាប់ការិយបរិច្ឆេទ | | - | - | - | - | 1,019,702 | 4,151,206 | - | 1,019,702 | 4,151,206 |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | | - | - | - | - | - | - | (1,004,883) | - | (1,004,883) |
| | | - | - | - | - | 1,019,702 | 4,151,206 | (1,004,883) | 1,019,702 | 3,146,323 |
| នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2024 | | 15,000,000 | 60,000,000 | 3,638,631 | 14,758,824 | (1,652,631) | (6,670,369) | 280,195 | 16,986,000 | 68,368,650 |

កំណត់សម្គាល់ដែលភ្ជាប់មកជាមួយ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុដូចដែលមាននៅក្នុងរបាយការណ៍សវនកម្មរបស់យើងខ្ញុំ



# របាយការណ៍លំហូរទឹកប្រាក់

## សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2025

| | កំណត់សម្គាល់ | 2025 ដុល្លារអាមេរិក | 2025 ពាន់រៀល (កំណត់សម្គាល់ 6) | 2024 ដុល្លារអាមេរិក | 2024 ពាន់រៀល (កំណត់សម្គាល់ 6) |
|---|---|---|---|---|---|
| **លំហូរទឹកប្រាក់ពីសកម្មភាពប្រតិបត្តិការ** | | | | | |
| ប្រាក់ចំណេញមុនដកពន្ធ | | 1,381,936 | 5,542,945 | 1,201,387 | 4,890,846 |
| *និយ័តកម្មលើ៖* | | | | | |
| ចំណាយពន្ធអប្បបរមា | | - | - | 141,070 | 574,296 |
| ចំណូលការប្រាក់សុទ្ធ | | (6,613,907) | (26,528,381) | (5,964,240) | (24,280,421) |
| សំវិធានធនលើបំណុលអាក្រក់ និងជាប់សង្ស័យ | | 615,681 | 2,469,496 | 956,605 | 3,894,339 |
| រំលស់ | 11&12 | 113,878 | 456,764 | 110,133 | 448,351 |
| ប្រាក់ខាតពីការលក់ ទ្រព្យ និងបរិក្ខារ | 11 | (57) | (228) | 46 | 187 |
| ប្រាក់ខាតពីការប្តូររូបិយប័ណ្ណ ដែលមិនបានទទួលស្គាល់ | | - | - | 16,721 | 68,071 |
| ឥណទានប្រមូលបានមកវិញ | | (56,814) | (227,881) | (92,489) | (376,523) |
| | | (4,559,283) | (18,287,285) | (3,630,767) | (14,780,854) |
| *បម្រែបម្រួលនូវ៖* | | | | | |
| ឥណទានផ្តល់ជូនអតិថិជន | | (11,241,957) | (45,091,490) | (14,537,568) | (59,182,439) |
| ទ្រព្យសកម្មផ្សេងៗ | | 159,073 | 638,042 | (109,544) | (445,954) |
| បំណុលផ្សេងៗ | | (128,373) | (514,904) | (536,779) | (2,185,227) |
| សាច់ប្រាក់ប្រើប្រាស់ក្នុងប្រតិបត្តិការ | | (15,770,540) | (63,255,637) | (18,814,658) | (76,594,474) |
| ការប្រាក់បានទទួល | | 13,762,243 | 55,200,357 | 13,723,339 | 55,867,713 |
| ការប្រាក់បានទូទាត់ | | (7,735,249) | (31,026,083) | (6,696,240) | (27,260,393) |
| ពន្ធលើប្រាក់ចំណេញបានបង់ | 13គ | (204,515) | (820,310) | (137,078) | (558,045) |
| ការទូទាត់អត្ថប្រយោជន៍និយោជិត | 15 | (1,345) | (5,395) | (1,429) | (5,817) |
| **សាច់ប្រាក់សុទ្ធប្រើប្រាស់ក្នុង សកម្មភាពប្រតិបត្តិការ** | | (9,949,406) | (39,907,068) | (11,926,066) | (48,551,016) |

# របាយការណ៍លំហូរទឹកប្រាក់ (ត)

## សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2025

| | កំណត់សម្គាល់ | 2025 | | 2024 | |
|---|---|---|---|---|---|
| | | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 6) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 6) |
| **លំហូរទឹកប្រាក់ពីសកម្មភាពវិនិយោគ** | | | | | |
| ការទិញទ្រព្យ និងបរិក្ខារ | 11 | (118,726) | (476,210) | (70,507) | (287,034) |
| សាច់ប្រាក់ទទួលបានពី ការលក់ទ្រព្យ និងបរិក្ខារ | | 445 | 1,785 | - | - |
| ការទិញទ្រព្យសកម្មអរូបី | 12 | (6,050) | (24,267) | (9,141) | (37,213) |
| សាច់ប្រាក់សុទ្ធប្រើប្រាស់ក្នុងសកម្មភាពវិនិយោគ | | (124,331) | (498,692) | (79,648) | (324,247) |
| **លំហូរទឹកប្រាក់ពីសកម្មភាពហិរញ្ញប្បទាន** | | | | | |
| សាច់ប្រាក់ទទួលបានពីប្រាក់កម្ចី | | 50,220,650 | 201,435,027 | 18,041,804 | 73,448,184 |
| ការទូទាត់សងប្រាក់កម្ចី | | (37,245,217) | (149,390,565) | (13,527,533) | (55,070,587) |
| សាច់ប្រាក់សុទ្ធទទួលបានពី សកម្មភាពហិរញ្ញប្បទាន | | 12,975,433 | 52,044,462 | 4,514,271 | 18,377,597 |
| **ការកើនឡើង/(ថយចុះ) នៃសាច់ប្រាក់ និងសាច់ប្រាក់សមមូល** | | 2,901,696 | 11,638,702 | (7,491,443) | (30,497,666) |
| **សាច់ប្រាក់ និងសាច់ប្រាក់សមមូលនាថ្ងៃទី1 ខែមករា** | | 3,098,323 | 12,470,751 | 10,589,766 | 43,259,194 |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | | - | (31,376) | - | (290,777) |
| **សាច់ប្រាក់ និងសាច់ប្រាក់សមមូល នាថ្ងៃទី31 ខែធ្នូ** | 7 | 6,000,019 | 24,078,077 | 3,098,323 | 12,470,751 |

កំណត់សម្គាល់ដែលភ្ជាប់មកជាមួយ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុដូចដែលមាននៅក្នុងរបាយការណ៍សវនកម្មរបស់យើងខ្ញុំ




“ កម្ចីរយៈពេលវែងពី ហ្វីស ហ្វាយនែន បានអនុញ្ញាតឱ្យពួកយើងរីករាយជាមួយការបង់ប្រាក់ប្រចាំខែដែលមានតម្លៃសមរម្យ ក្នុងពេលដែលកំពុងធ្វើឱ្យក្ដីស្រមៃនៃការមានផ្ទះជាកម្មសិទ្ធិរបស់ពួកយើងក្លាយជាការពិត។

**អ្នកស្រី ហុង ស្រីម៉ៅ**
កម្មការនីរោងចក្រ

## ការិយាល័យកណ្តាល

អគារលេខ ២៩៥ ផ្លូវ ២៧១
សង្កាត់ ទួលទំពូង II ខណ្ឌចំការមន
រាជធានី ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

(+855) 93 666 635
info@firstfinance.com.kh
firstfinance
firstfinance plc
firstfinance.com.kh